ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត




- កញ្ញា ប៊ូ សំណាង គឺជាការសន្យា និងសេចក្តីសង្ឃឹមថ្មីសម្រាប់កម្ពុជា
- ប្រជាជនអន្លង់វែងទស្សនាការផ្សាយបន្តផ្ទាល់ព្រឹត្តិការណ៍ កីឡាអាស៊ីអាគ្នេយ៍លើកទី៣២

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៨១ ខែឧសភា ឆ្នាំ២០២៣

ស្វែងរកការពិត

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៨១ ខែឧសភា ឆ្នាំ២០២៣



កញ្ញា ប៊ូ សំណាង គឺជាអត្តពលិកក្នុងវិញ្ញាសារត់ចម្ងាយ ៥០០០ម៉ែត្រ កីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះកាលពីថ្ងៃទី ៨ ខែឧសភា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា

### សំបុត្រ


- កញ្ញា ប៊ូ សំណាង គឺជាការសន្យា និងសេចក្តីសង្ឃឹមថ្មីសម្រាប់កម្ពុជា........................១
- ប្រជាជនអន្លង់វែងទស្សនាការផ្សាយបន្តផ្ទាល់ព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍លើកទី៣២.. ២


### ផ្នែកឯកសារ


- ចាយ បេវ ៖ អនុប្រធានវរសេនាធំ ៣១ ..... ៤


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមរៀបចំពិធីបង្សុកូលឧទ្ទិសកុសលដល់ជនរងគ្រោះ .... ៧
- ហួន សាវង្ស៖ ស្វាមីរបស់ខ្ញុំស្លាប់........... ៩
- ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមចុះជួប និងសម្ភាសន៍អ្នករស់រានមាន ...... ១២
- ជីវិតក្នុងរបបខ្មែរក្រហមនៅភូមិបុស្ស .... ១៥
- អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតំបន់ដាច់ស្រយាលនៃភូមិបាក់នឹម មកទស្សនកិច្ចព្រះបរមរាជវាំង បណ្ណាល័យសម្តេចម៉ែ និង... ១៧
- ង៉ែត យុន ៖ មេភូមិស្នើសុំកង់របស់ខ្ញុំ...... ២១


### ផ្នែកវេទិកាពិភាក្សាសាធារណៈ


- សិស្សវិទ្យាល័យមកពីស្រុកមេមត់ចូលរួមវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម... ២៣
- សិស្សវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី........ ២៣
- សិស្សវិទ្យាល័យសម្តេច ហ៊ុនសែន សង្កើប ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី......... ៣១
- វេទិកាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-៧៩) ចុងសប្តាហ៍នៅ ..... ៣៤
- វេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅអន្លង់វែង....... ៣៨
- វេទិកាអប់រំស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅសហគមន៍ជនជាតិដើម... ៤០
- វេទិកាអប់រំសហគមន៍ស្តីពី «ការចងចាំនៃការបាត់បង់ជីវិតសមាជិកគ្រួសារ.............. ៤៤
- វេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នៅវត្តពន្លៃ ...... ៤៨
- វេទិកាថ្នាក់រៀនរំឮកអំពីទិវាជាតិនៃការចងចាំ ២០ឧសភា ................................៥២


### ផ្នែកស្រាវជ្រាវរកគ្រួសារ


- ពុំ រី ៖ បែកបាក់ឪពុកម្តាយ និងប្អូនៗ ....... ៥៦
- **«ទួលពិឃាដ»** (ត) ......................... ៦១


**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ ៖** ឆាំង យុ, លី សុខឃាង, ទូច វណ្ណេត, ពុំ វណ្ណឌី, ហេង ឡៃហៀន, ឈុំ រ៉ា, រី ស៊ីថា, សាង ចាន់ធូ, លី ដេវីត, ភា រស្មី, ថុន ស្រីពេជ្រ, ឈួន សុគង់, ឡុង ដានី, ស៊ាង ចិន្តា, និង ឡុង វង្សសមិទ្ធ
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ដាត ចាន់សុនិតា **អ្នកបកប្រែ៖** លីម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន
**ជំនួយការនិពន្ធនាយក៖** ដារ៉ា វឌ្ឍ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiasri.org

# កញ្ញា ប៊ូ សំណាង គឺជាការសន្យា និង សេចក្តីសង្ឃឹមថ្មីសម្រាប់កម្ពុជា

**ឆាំង យុ**





កញ្ញា ប៊ូ សំណាង គឺជាអត្តពលិកក្នុងវិញ្ញាសារត់ចម្ងាយ ៥០០០ម៉ែត្រ កីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះកាលពីថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

"ស្ថិតនៅក្រោមភ្លៀងធ្លាក់ជោគជាំ កញ្ញានៅតែរត់បន្ត ថ្វីត្បិតតែមកដល់ទីចុងក្រោយគេបង្អស់យ៉ាងណាក្តី នាងក្តោបបានការចាប់អារម្មណ៍យ៉ាងខ្លាំងដោយមនុស្សម្នាជាច្រើនងឿងឆ្ងល់ថាតើនាងកំពុងគិតអំពីអ្វីៗ តាមរយៈទឹកភ្នែករបស់នាង ក្រោមភ្លៀងមូសុងដែលកំពុងបង្អុរចុះជោគជាំ យើងចាប់ផ្តើមមើលឃើញកាន់តែច្បាស់នូវរូបភាពប្រជាជាតិកម្ពុជាមួយសម្រាប់ប្រជាជនកម្ពុជាគ្រប់រូបៗ នោះគឺជាប្រជាជាតិមួយ ដែលយើងចែករំលែកសេចក្តីស្រឡាញ់ស្មើៗគ្នា។ ខ្ញុំមិនបានយំតាមនាងទេ ក៏ប៉ុន្តែបេះដូងខ្ញុំៗ មើលឃើញអំពីការរត់របស់នាង អមជាមួយនឹងទឹកភ្នែកស្រក់ចុះលើផ្ទៃមុខ នេះគឺអាចចាត់ទុកថាជាខណៈពេលបន្ទូរអារម្មណ៍មួយសម្រាប់ប្រជាជនកម្ពុជាទាំងអស់ ក្នុងការរំសាយចោលនូវរាល់សោកនាដកម្មនៃសង្គ្រាម និងអំពើប្រល័យពូជសាសន៍ដែលបានស្ថិតនៅអន្ទោលតាមយើងអស់រយៈកាលរាប់ទសវត្សរ៍កន្លងមកហើយ។ អារម្មណ៍របស់នាង គួបផ្សំជាមួយនឹងភ្លៀងមូសុង អាចចាត់ទុកថាជាការបង្កើតការសន្យានិងសេចក្តីសង្ឃឹមថ្មីមួយសម្រាប់កម្ពុជា ដែលបន្ទាប់ពីភាពសោកសៅ អត្តពលិករត់ប្រណាំងមាឌតូចមួយរូបនេះ ប្រៀបដូចទៅនឹងប្រទេសកម្ពុជាដ៏តូចមួយនេះដែរ អាចកសាងសេចក្តីសង្ឃឹមជាថ្មីឈានទៅកាន់ថ្ងៃស្អែកដ៏ប្រសើរ និងត្រចះត្រចង់"។

**ឆាំង យុ**

អ្នករស់រានមានជីវិតម្នាក់ពីរបបខ្មែរក្រហម និងជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

# ប្រជាជនអន្លង់វែងទស្សនាការផ្សាយបន្តផ្ទាល់ព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍លើកទី៣២

*លី សុខឃាង*




ប្រជាជននៅក្នុងស្រុកអន្លង់វែងជួបជុំគ្នា ដើម្បីទស្សនាការផ្សាយបន្តផ្ទាល់នៃព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១២ នៅក្នុងសារមន្ទីរអតីតផ្ទះតាម៉ុក ចាប់ពីថ្ងៃទី២៩ ខែមេសា រហូតដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ រៀបចំឡើងដោយរដ្ឋបាលស្រុកអន្លង់វែង សហការជាមួយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ប្រជាជននៅក្នុងស្រុកអន្លង់វែងមានឱកាសជួបជុំគ្នា ដើម្បីទស្សនាការផ្សាយបន្តផ្ទាល់នៃព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១២ នៅក្នុងសារមន្ទីរអតីតផ្ទះតាម៉ុក ចាប់ពីថ្ងៃទី២៩ ខែមេសា រហូតដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ខណៈដែលប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះក្នុងការប្រកួតកីឡានេះ។ អតីតសមាជិកខ្មែរក្រហមជាច្រើននាក់បានចាត់ទុកថាជាពេលវេលាដ៏សប្បាយរីករាយបំផុតរបស់ខ្លួន។ ការជួបជុំទស្សនាការផ្សាយបន្តផ្ទាល់នេះ បានញ៉ាំងជំរុញឲ្យមានបរិយាកាសមួយដែលជារឿយៗមានភ្ញៀវទេសចរណ៍មកពីតាមបណ្តាខេត្តផ្សេងៗមកចូលរួមអង្គុយជាមួយគ្នាដែរ។ នៅពេលដែលការប្រកួតកីឡានេះបានចាប់ផ្តើមនៅលើអេក្រង់ អ្នកទស្សនា

ទាំងអស់បានមានឱកាសក្នុងការសន្ទនាគ្នា និងបង្កើតអារម្មណ៍សប្បាយរីករាយ។

ដោយស្ថិតនៅក្នុងរយៈចម្ងាយប្រមាណជា ៤៥០គីឡូម៉ែត្រពីពហុកីឡាដ្ឋានជាតិមរតកតេជោ ដែលព្រឹត្តិការណ៍នេះកំពុងរៀបចំឡើងរដ្ឋបាលស្រុកអន្លង់វែងដែលជាស្រុកស្ថិតនៅភាគខាងជើងនៃប្រទេសកម្ពុជា តាមបណ្តោយព្រំដែនកម្ពុជា - ថៃ សហការជាមួយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានដាក់តម្លើងអេក្រង់ផ្សាយបន្តផ្ទាល់ចំនួនពីរ ដែលអាចទទួលរូបភាពពីឧបករណ៍ទូរទស្សន៍ប្រព័ន្ធឌីជីថល។ អ្នកទស្សនាទាំងឡាយអាចពិសាទឹក នៅក្នុងកម្មវិធីនោះដែរ។

ការផ្សាយបន្តផ្ទាល់ព្រឹត្តិការណ៍ប្រកួតកីឡាបែបនេះ ប្រាកដជាមិនអាចធ្វើទៅបានទេនៅមុនឆ្នាំ១៩៩៨ ដោយសារតែអន្លង់វែង គឺជាតំបន់សង្គ្រាមរវាងកងទ័ពរបស់រាជរដ្ឋាភិបាលកម្ពុជា និងខ្មែរក្រហម។ បន្ទាប់ពីការធ្វើសមាហរណកម្មនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨ ក្រោមគោលនយោបាយឈ្នះ ឈ្នះ របស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី សង្គ្រាមបានចប់ជាស្ថាពរ ឥឡូវនេះយើងបាននិយាយពាក្យសន្តិភាពទាំងអស់គ្នា ដែលយើងត្រូវតែលើកស្ទួយ និងថែរក្សា ដើម្បីធានាឲ្យបាននូវវិបុលភាព និងការរីកចម្រើនដ៏យូរអង្វែងនៅគ្រប់សហគមន៍ទាំងអស់ក្នុងប្រទេសកម្ពុជា។

ហួន ផាត វ័យ៥២ឆ្នាំ និង ឡុង លឿ វ័យ ៤៤ឆ្នាំ បានចូលរួមទស្សនាព្រឹត្តិការណ៍នេះនៅឯសារមន្ទីរផ្ទះតាម៉ុក បានសម្តែងនូវទឹកចិត្តសប្បាយរីករាយដូចគ្នាជាមួយនឹងការផ្សាយបន្តផ្ទាល់នេះដែរ។ ផាត ដែលជាអតីតទាហានខ្មែរក្រហមបាននិយាយថា «ខ្ញុំមានអារម្មណ៍សប្បាយរីករាយណាស់ក្នុងការមកមើលការផ្សាយបន្តផ្ទាល់ព្រឹត្តិការណ៍កីឡាដែលប្រទេសកម្ពុជាយើងធ្វើជាម្ចាស់ផ្ទះ ប្រសិនបើយើងប្រៀបធៀបទៅនឹងមុនឆ្នាំ១៩៩៨វិញ សង្គ្រាមកំពុងបន្តនៅឡើយ»។

លឿ ដែលអង្គុយក្បែរនោះបានបន្ថែមថា «បើនិយាយពីកាលណោះវិញ យើងប្រហែលជាគ្មានឱកាសមកអង្គុយមើល និងសប្បាយរីករាយជាមួយព្រឹត្តិការណ៍កីឡាដូចសព្វថ្ងៃនេះទេ»។

មជ្ឈមណ្ឌលឯកសារកម្ពុជាប្រើប្រាស់គ្រប់មធ្យោបាយ មិនមែនត្រឹមតែកម្មវិធីសិក្សាប្រវត្តិសាស្ត្រខ្មែរក្រហមផ្លូវការនោះទេ ដើម្បីនាំយកនូវរាល់បំណែកនៃសង្គមកម្ពុជាដែលបែកបាក់មករួបរួមគ្នាវិញ ដូច្នេះសន្តិភាពអាចត្រូវបានការពារ និងយុត្តិធម៌អាចកើតមានឡើង។

មជ្ឈមណ្ឌលឯកសារកម្ពុជាជឿជាក់ថា កីឡាអាចជាទម្រង់មួយសម្រាប់ការផ្សះផ្សាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ យើងចូលរួមការប្រកួតដើម្បីការដោតជ័យ មិនមែនការកាប់សម្លាប់គ្នានោះទេ។





ប្រជាជននៅក្នុងស្រុកអន្លង់វែងជួបជុំគ្នា ដើម្បីទស្សនាការផ្សាយបន្តផ្ទាល់នៃព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១២ នៅក្នុងសារមន្ទីរអតីតផ្ទះតាម៉ុក ចាប់ពីថ្ងៃទី២៩ ខែមេសា រហូតដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ រៀបចំឡើងដោយរដ្ឋបាលស្រុកអន្លង់វែង សហការជាមួយមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ចាយ ចេវ ៖ អនុប្រធានវរសេនាធំ ៣១ កងពល ៧០៣

*ដារ៉ារដ្ឋ មេត្តា*



កងទ័ពបដិវត្តន៍ខ្មែរក្រហមនៅមុខប្រាសាទបាយ័ន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ចាយ ចេវ អាយុ៣០ឆ្នាំ (នៅក្នុងឆ្នាំ១៩៧៧)។ ខ្ញុំរស់នៅភូមិថ្មី ឃុំពោធិ៍បាន ស្រុកកោះធំ ខេត្តកណ្តាល។ បន្ទាប់ពីខ្ញុំធំដឹងក្តីបានបន្តិច ម្តាយខ្ញុំបានទៅរកស៊ីនៅផ្សារព្រែកតូច ស្ថិតនៅឃុំព្រែកគយ ស្រុកស្អាង ខេត្តកណ្តាល។ ក្រោយមកគ្រួសារខ្ញុំនាំគ្នាទៅរកស៊ីនៅបាត់ដំបង ហើយយើងក៏ត្រឡប់មកវិញ។ តមកឪពុករបស់ខ្ញុំធ្លាក់ខ្លួនឈឺហើយស្លាប់ ដូច្នេះខ្ញុំក៏ចេញទៅស៊ីឈ្នួលគេនៅក្នុងភូមិដើម្បីបានប្រាក់ខ្លះមកចាយ។ ដោយសារជីវភាពខ្វះខាតខ្ញុំក៏ឈប់រៀនមួយរយៈ ក្រោយមកខ្ញុំបានចូលរៀនវិញនៅសាលាវត្តកំពង់គ ស្ថិតនៅឃុំពោធិបាន ស្រុកកោះធំ ខេត្តកណ្តាល។ នៅដើមឆ្នាំ១៩៦៨ ខ្ញុំក៏ឈប់រៀន។ បន្ទាប់ពីឈប់រៀន ខ្ញុំបានទៅរកស៊ីធាក់ស៊ីក្លូនៅរាជធានីភ្នំពេញដោយទៅស្នាក់នៅផ្ទះថៅកែស៊ីក្លូឈ្មោះ ផាន ដែលត្រូវជាបងជីដូនមួយរបស់ខ្ញុំ។ អ្នកធាក់ស៊ីក្លូជាមួយខ្ញុំម្នាក់ ឈ្មោះ យី ក៏ត្រូវជាបងប្អូនជីដូនមួយរបស់ខ្ញុំដែរ។ បន្ទាប់ពីខ្ញុំរកស៊ីធាក់ស៊ីក្លូបានរយៈពេល៥ថ្ងៃ យី បានអូសទាញខ្ញុំដោយឃើញពីចំណុចខ្សោយរបស់ខ្ញុំដែលគ្មានប្រាក់។ យី បានឲ្យលុយខ្ញុំចំនួន២០០០រៀល ឲ្យខ្ញុំធ្វើគិញដោយមានភារកិច្ចរកជនបដិវត្តន៍ហើយពេលឃើញជនទាំងនោះត្រូវរាយការណ៍ឲ្យគាត់។ នៅចុងឆ្នាំ១៩៦៨ ខ្ញុំត្រឡប់

មកស្រុកកំណើរវិញ ពេលនោះ យី បានប្រាប់ខ្ញុំឲ្យទៅជួបឈ្មោះ សែ គឺជាគិញនៅព្រែកជ្រៃ។ ខ្ញុំបានទៅជួបឈ្មោះ សែ ហើយសែបានឧទ្ទេសនាម ខ្ញុំឲ្យស្គាល់ខ្សែគិញឈ្មោះ គង់ ចែម គឺជាចៅហ្វាយតំបន់ជ្រៃធំទទួលខុសត្រូវលើប៉ូលិសទាំងអស់នៅទល់ដែននេះ។

នៅក្នុងឆ្នាំ១៩៧០ កែវ៉ានឲ្យខ្ញុំធ្វើជាយុទ្ធជនកងការពារមន្ទីរឃុំឃាំងរបស់គាត់នៅម្តុំព្រែកតាជន់បាន រយៈពេលប្រហែលជា២ខែ។ ក្រោយមកខ្ញុំក៏ត្រូវបានឧទ្ទេសនាមជាមេក្រុម នៅអង្គភាពទ័ពស្រុកស្អាង ហើយខ្ញុំក៏ត្រូវបានបញ្ចូលជា សេ.អុី.អា នៅពេលនោះដែរ។ កែ វ៉ាន បានចាត់តាំងខ្ញុំទៅបង្កប់ខ្លួននៅអង្គភាពកងទ័ពបដិវត្តន៍កម្ពុជាវិញ។ តាមការឧទ្ទេសនាមរបស់ កែវ៉ានបានឲ្យខ្ញុំមកជួប សុខ គឺជាសមាជិកគណៈឃុំពោធិ៍បាន។ បន្ទាប់មកទៀត សុខ បានឧទ្ទេសនាមខ្ញុំជួបជាមួយ តេង បន្តទៀត។ តេង បានទទួលស្គាល់ខ្ញុំនៅកន្លែងរបស់គាត់គឺនៅមន្ទីរសន្តិសុខស្រុកកោះធំ ហើយខ្ញុំក៏បានចូលធ្វើការនៅក្នុងឆ្នាំ១៩៧១។ ខ្ញុំធ្វើការមិនទាន់បានពាក់កណ្តាលឆ្នាំផង តេង បានឧទ្ទេសនាមខ្ញុំឲ្យមកនៅមន្ទីរសន្តិសុខតំបន់២៥ វិញ។ ក្រោយពីខ្ញុំឡើងមកនៅមន្ទីរតំបន់២៥បានរយៈពេលកន្លះខែ តេងឡើងមកតាមក្រោយនៅមន្ទីរសន្តិសុខតំបន់២៥ ដែរគឺនៅក្នុងឆ្នាំ១៩៧២។

នៅដើមឆ្នាំ១៩៧៣ ខ្ញុំត្រូវរបួសនិងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យ។ នៅទីនោះឈ្មោះ ប៉ាង បានបំផុសខ្ញុំឲ្យធ្វើសកម្មភាពបង្កទំនាស់រវាងអ្នកជំងឺនិងគ្រូពេទ្យក្នុងឃុំក្រាំងយ៉ូវ ស្រុកស្អាង តំបន់ ២៥។

នៅឆ្នាំ១៩៧៤ ខ្ញុំចេញពីមន្ទីរពេទ្យទៅនៅកងវរសេនាតូចលេខ១១២ កងវរសេនាធំ២១ កងពល ១២ ហើយនៅទីនោះខ្ញុំបានជួប ប៉ាង។ ប៉ាង មាននាទីជាប្រធានវរសេនាតូចគ្រប់គ្រងលើខ្ញុំ ហើយប្រាប់ខ្ញុំឲ្យទៅកាន់វរសេនាតូច១០៥ ស្ថិតនៅក្នុងវរសេនាធំ២៦៨ កងពល១២។ ប៉ាងឧទ្ទេសនាមខ្ញុំឲ្យទៅជួប លាត គឺជាលេខាវរសេនាធំ២៦៨ របស់កងពល១២ ដើម្បីដឹងពីសភាពនៅក្នុងកង។ ក្រោយពីប៉ាង ប្រាប់សព្វគ្រប់ ហើយ ខ្ញុំក៏បានទៅជួប លាត ហើយ លាត ប្រាប់ខ្ញុំអំពីគណៈ១៣០មាន ចាន់ គឺជាលេខាវរសេនាតូច១៣០, សាមិត គឺជាអនុលេខាវរសេនាតូច១៣០ និង ផា គឺជាសមាជិក។ ក្រោយមកខ្ញុំបានចេញពី លាត ទៅនៅកងជាមួយ ចាន់។ ចាន់ លើកឡើងពីស្ថានភាពនៅអង្គភាពប្រាប់ខ្ញុំ និងកម្លាំងឃោសនាអូសទាញបាន។ កម្លាំងដែល ចាន់ អប់រំបានមានឈ្មោះ តុំ គឺជាស្នងការអនុសេនាធំវរសេនាតូច៣១១, ជឿន នៅស្នងការនយោបាយអនុសេនាធំ វរសេនាតូច១២៧, ខន គឺជាស្នងការអនុសេនាធំ វរសេនាតូច១៣០ កងពល១២, អ៊ុយ ធី គឺជាស្នងការអនុសេនាតូច ស្ថិតនៅក្នុងវរសេនាតូច៣២១ វរសេនាធំ៣២ កងពល ៧០៣។

នៅរដូវវស្សានៅក្នុងឆ្នាំ១៩៧៤ ពេលនោះកងទ័ពបោះទីតាំងនៅស្រុកកៀនស្វាយ តំបន់២៥។ រហូតដល់ដាច់ឆ្នាំ១៩៧៤ អង្គភាពត្រូវផ្លាស់ទៅកាន់ទន្លេមេគង្គវិញ។ នៅពេលនោះមានឈ្មោះ អ៊ុក តែម ដែលត្រូវរបួសតាំងពីឆ្នាំ១៩៧២ ហើយដេកសម្រាកព្យាបាលនៅមន្ទីរពេទ្យបានចូលមកនៅ និងឡើងជាសមាជិកកង២៦៩ ដែលមាន ប៉ាង គឺជាលេខា និង លាត គឺជាអនុ។ នៅពេលខ្ញុំចូលវាយនៅសមរភូមិមេគង្គ ខ្ញុំបានជួប សន គឺជាសមាជិកកងពល៣១០, លាត និង ប៉ាង ដែរ។ ការងារនៅក្នុងសមរភូមិ គឺខ្ញុំទប់ចលនាសម្រុករបស់ទ័ពមិនឲ្យទៅមុខតាមផែនការ និងបាញ់កប៉ាល់ខ្មាំងមិនឲ្យត្រូវ។ សកម្មភាពមួយទៀតគឺធ្វើឲ្យដាច់ខ្សែត្រៀមនៅកណ្តាលថ្ងៃត្រង់នៅសមរភូមិខ្ពបពាមរាំង ហើយប្រាប់ឈ្មោះ ផល់ ឲ្យបាញ់ផ្លោងចំណុចខ្មាំងកុំឲ្យត្រូវចំគោលដៅ។ អ៊ុក តែម មានបញ្ហាមួយទៀតគឺបង្កទំនាស់ឲ្យប្របូកប្របល់នៅក្នុងគណៈ២៦៩ និងឃើញតែទំនាស់គ្នារាល់ថ្ងៃ។ បន្ទាប់មកអង្គភាពរបស់ខ្ញុំផ្លាស់ទៅនៅសមរភូមិក្អមសំណ ប៉ុន្តែនៅទីនោះយើងក៏បានបើកឲ្យកងទ័ពធីវគីប្លវៀតណាមខាងត្បូងចូលមកអុកឡុកដែរ។ បន្ទាប់មកយើងឡើងមកដល់ជង់ទន្លេបាសាក់ និងវាយសម្រុកទៅមុខរហូតវាយឈ្នះភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

នៅចុងឆ្នាំ១៩៧៦ ខ្ញុំជួបអ៊ុកតែមម្តងទៀតពេលមករៀនវគ្គនៅសេនាធិការ។ ខ្ញុំបានអង្គុយជជែកលេង

ជាមួយ អ៊ុក តែម, សន, សឿន និង ផល់។ ពេលនោះ អ៊ុក តែម វិភាគសភាពការណ៍តឹងតែង និងការធ្វើសកម្មភាព។ ពេលនោះខ្ញុំនៅក្រុងភ្នំពេញ ដូច្នេះខ្ញុំបានជួបបង សុខ នៅអង្គភាព១៧០, ផល់ នៅក្បាលថ្នល់។ ក្រោយមកមានសកម្មភាពរត់បោលអង្គភាពដោយដំបូង ហ៊ិន មីសារី ក្រោយមក ផល់ រត់ទៀត ប៉ុន្តែត្រូវអង្គការចាប់បាន។

ក្រោយមកខ្ញុំបានជួប អ៊ុក តែម ម្តងទៀតនៅកងពល៧០៣ ដោយពេលនោះគាត់យកប្រវត្តិរូបនិងបញ្ជីផ្សេងៗមកកន្លែងកងពល។ អ៊ុក តែម និយាយថារឿង ផល់ គឺជារឿងសំខាន់ត្រូវរកវិធីសាស្ត្រដោះឲ្យចេញផុតពីមន្ទីរឃុំឃាំង។ បើ ផល់ នៅជាប់គឺនឹងប៉ះពាល់ដល់គាត់, ខ្ញុំ និងអ្នកផ្សេងទៀត ដែលនៅជាមួយ សុខ នៅតំបន់២៥។ ខ្ញុំបានលើកឡើងវិធីដោះស្រាយដោយត្រូវចាត់តាំងមនុស្សរបស់យើងត្រូវឆាប់ផ្តាច់សោហើយបន្ទំសួរចម្លើយ ផល់ កុំឲ្យអ្នកយាមចាប់អារម្មណ៍។ យក ផល់ ទៅទុកស្រួលបួលហើយ ហើយឲ្យរាយការណ៍ថា ផល់ លោតផ្លោះរបងសាលាពញា ហុក ឬ ផល់ រត់ទៅក្បាលថ្នល់។ ខ្ញុំបានឃើញឯកសារ ផល់ ឆ្លើយដាក់ធ្វើឲ្យអារម្មណ៍របស់ខ្ញុំកាន់តែព្រួយ។ សេចក្តីរាយការណ៍របស់ខ្ញុំអំពីប្រវត្តិសកម្មភាព និង ប្រវត្តិទាក់ទងខ្ញុំមានតែប៉ុណ្ណឹង។

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីចម្លើយសារភាពឯកសារJ០០៣៩០។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ ចាយ ចេវ ពិតប្រាកដយ៉ាងណានោះទេ?***



*កងទ័ពបដិវត្តន៍ខ្មែរក្រហមនៅសមរភូមិ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

# មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមរៀបចំពិធីបង្សុកូលឧទ្ទិសកុសលដល់ជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម

ទូច វណ្ណោត



ស្តូបរំឭកដល់អ្នកដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហមក្នុងសហគមន៍គគរ។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៣ សមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅឃុំគគរ គាំទ្រដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ចូលរួមប្រារព្ធទិវាជាតិនៃការចងចាំ ដោយបានរៀបចំពិធីបង្សុកូលឧទ្ទិសកុសលដល់ជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហមនៅចេតិយរំឭកសម្រាប់សហគមន៍ និងដើម្បីរំឭកដល់អ្នកដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហមក្នុងសហគមន៍គគរ និងបង្កើនស្មារតីចងចាំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាក្នុងកម្រិតមូលដ្ឋាន។









ប្រជាជនចូលរួមរៀបចំពិធីបង្សុកូលឧទ្ទិសកុសលដល់ជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហមនៅឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាមៗ ( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# ហួន សាវង្ស៖ ស្វាមីរបស់ខ្ញុំស្លាប់ដោយសារគ្រាប់មីនបង្កប់ជុំវិញភូមិ

*ហេង ឡៃហៀន*



ហួន សាវង្ស អាយុ៧២ឆ្នាំ រស់នៅភូមិដុងអារញ្ញ សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ហួន សាវង្ស អាយុ៧២ឆ្នាំ មានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ។ បច្ចុប្បន្នខ្ញុំរស់នៅភូមិដុងអារញ្ញ សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ ខ្ញុំមានឪពុកឈ្មោះ ហៀរ។ ម្តាយឈ្មោះ វៀន។ ក្នុងចំណោមបងប្អូនបង្កើតរបស់ខ្ញុំចំនួន៧ នាក់ បាត់បង់ជីវិតអស់២នាក់។ កាលពីកុមារខ្ញុំធ្លាប់រៀនអក្ខរកម្មតិចតួច។ បន្ទាប់ពីឈប់រៀន ខ្ញុំរៀបការជាមួយស្វាមីរបស់ខ្ញុំឈ្មោះ សៀន ថនស៊ី។ ក្រោយពី រៀបការរួចខ្ញុំមានកូនម្នាក់ឈ្មោះ សរ ។ នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាចចូលមកដល់ភូមិអារញ្ញ ខ្ញុំកំពុងមានផ្ទៃពោះកូនទី២ រយៈពេល ៧ខែ។ ខ្មែរក្រហមបង្ខំក្រុមគ្រួសារខ្ញុំឲ្យចាកចេញពីផ្ទះ ប្រសិនបើមិនព្រមចាកចេញទេនឹងបាញ់សម្លាប់ចោល។ ស្របពេលនោះ ប្តីរបស់ខ្ញុំទើបតែបររទេះគោមកពីធ្វើស្រែនៅក្រៅភូមិ។ ដោយសារ ខ្ញុំកំពុងពរពោះជិតគ្រប់ខែប្តីរបស់ខ្ញុំបានស្នើសុំខ្មែរក្រហមយករទេះគោទៅជាមួយ ប៉ុន្តែខ្មែរក្រហមមិនអនុញ្ញាត។ ខ្ញុំនិងប្តីយកអង្ករទៅផ្ញើលើរទេះគោបងប្អូនអ្នកជិតខាង។ ចំណែកខ្ញុំនិងក្រុមគ្រួសារនាំគ្នាបណ្តើរកង់ធ្វើដំណើរអស់រយៈពេលជាច្រើនថ្ងៃ ទើបទៅដល់ភូមិរូងជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង។ ពេលទៅដល់ទីនោះខ្មែរក្រហមចាត់ឲ្យខ្ញុំរស់នៅតាមរោងប្រក់ស័ង្កសី ដោយចែកអង្ករម្នាក់មួយកំប៉ុងមៀវតូចយកទៅដាំបាយហូប។ ដោយសារអង្ករតិចពេកខ្ញុំនាំគ្នាបេះផ្កាស្មោបេះក្តិបចេក លាយជាមួយអង្ករដាំបបរហូប។ បន្ទាប់ពី ខ្ញុំរស់នៅ ទីនោះបានពីរទៅបីខែ កូនច្បងរបស់ខ្ញុំស្គមមានតែស្បែកដណ្តប់ឆ្អឹង ឈឺរាករូសគ្មានថ្នាំព្យាបាលរហូតដល់បាត់បង់ជីវិត។

ក្រោយមកទៀតខ្មែរក្រហមក៏ចាប់ផ្តើមបង្កើតជាសហករណ៍រស់នៅរួមនិងហូបរួម។ ពេលនោះ ខ្ញុំរស់នៅសហករណ៍លេខ១៦។ ប្រធានសហករណ៍ឈ្មោះ តាខាវ និង យាយដាំ។ គាត់ឲ្យក្រុមគ្រួសារខ្ញុំទៅរស់នៅក្នុងខ្ទមធ្វើពីឫស្សី ធាងដូង ប្រក់ស្បូវ ខ្ពស់ពីដីត្រឹមទ្រូង ដែលសង់នៅលើដីមួយឡូតិ៍ៗ សម្រាប់ប្រជាជន

រស់នៅក្នុងខុមដាំបេក ដំឡូង និងដំណាំផ្សេងៗទៀត ប៉ុន្តែមិនអនុញ្ញាតឲ្យបេះដំណាំទាំងនោះហូបឡើយ។ ដោយសារតែពេលនោះ ខ្ញុំមានផ្ទៃពោះមិនអាចទៅដកដំឡូងកើត ខ្មែរក្រហមប្រើខ្ញុំឲ្យកាត់ដើមដំឡូងប្រវែងមួយហត្ថៗ សម្រាប់ធ្វើពូជ។ ខ្ញុំទទួលបានរបបអាហារពីរពេលក្នុងមួយថ្ងៃគឺពេលព្រឹកហូបបបរបីវែក និងពេលល្ងាចហូបបាយលាយសម្លព្រលិតនិងត្រកួនចំនួនបីវែក។ ពេលធ្វើការងាររួច ខ្ញុំដើររកត្រីក្តាម ខ្យងតាមស្រះទឹកបុ ថ្កុកមកប្រឡាក់អំបិលអាំងហូប ដោយលាក់មិនឲ្យអង្គការឃើញ។ ក្រោយមកខ្ញុំដល់ថ្ងៃសម្រាលកូន នៅក្នុងរបបខ្មែរក្រហមគ្មានពេទ្យឬឆ្មបជួយសម្រាលទេ គឺមានតែឪពុកក្មេករបស់ខ្ញុំគាត់ជួយសម្រាលដល់ខ្ញុំ។ ពេលនោះ ខ្ញុំត្រូវកាត់ទងសុកកូនដោយខ្លួនឯងពិបាកណាស់។ ប្តីរបស់ខ្ញុំបានរកពន្លៃទុកឲ្យខ្ញុំដាំផឹកមុនពេលគាត់ទៅធ្វើការនៅកន្លែងឆ្ងាយ។ បន្ទាប់ពី សម្រាលកូនបានមួយខែ ខ្មែរក្រហមចាត់ឲ្យខ្ញុំទៅកិនស្រូវ។ ក្នុងមួយក្រុមមានសមាជិក១០នាក់ ដោយមានត្បាល់កិនចំនួន ៣ ក្នុងត្បាល់កិនមួយ មានគ្នាចំនួន៣នាក់។ នៅសល់៤នាក់ទៀតជាអ្នករែងអង្កាម។ ខ្មែរក្រហមកំណត់ក្នុងមួយថ្ងៃត្រូវកិនស្រូវឲ្យរួចបីបាវ ថ្ងៃខ្លះមានសមាជិកក្នុងក្រុមឈឺសុំច្បាប់នៅសល់តែ៣នាក់ក៏មាន ដោយខ្ញុំត្រូវកិនស្រូវរហូតដល់យប់ជ្រៅទើបរួច។ ខ្ញុំយកកូនទៅផ្ញើជាមួយម្តាយក្មេករបស់ខ្ញុំ។ គាត់ជាអ្នកមើលក្មេង ដោយសារគាត់មានអាយុច្រើនមិនអាចធ្វើការងារផ្សេងកើត។ ពេលព្រឹកឡើងគាត់ដើរប្រមូលក្មេងៗពីតាមផ្ទះទៅដាក់នៅរោងបាយ ដើម្បីបញ្ចុកបបរដល់ក្មេង។ ពេលសម្រាកពីការងារ ខ្ញុំតែងតែឡើងមកបំបៅដោះកូន ពេលបៅរួចទើបត្រឡប់ទៅធ្វើការងារវិញ។ ដោយសារខ្ញុំទើបសម្រាលកូនហើយត្រូវកិនស្រូវពេញមួយថ្ងៃៗ ពេលខ្លះភ្នែកខ្ញុំស្រវាំងមើលអ្វីលែងច្បាស់។ ស្ថានភាពភ្នែកខាងឆ្វេងរបស់ខ្ញុំកាន់តែធ្ងន់ធ្ងរពីមួយថ្ងៃទៅមួយថ្ងៃ ហើយក៏ពិការមើលលែងឃើញរហូតមកដល់សព្វថ្ងៃ។

បំណែកប្តីរបស់ខ្ញុំ ត្រូវខ្មែរក្រហមចាត់ឲ្យទៅធ្វើស្រែប្រាំងស្រែវស្សាមួយឆ្នាំបីដង។ ក្រៅពីការងារភ្ជួររាស់ គាត់ត្រូវកាប់ស្មៅក្នុងស្រែ រយៈពេលបីខែទើបបានមកជួបប្រពន្ធកូនម្តង។ ពេលកូនរបស់ខ្ញុំមានអាយុបីខែ ខ្មែរក្រហមផ្លាស់ខ្ញុំឲ្យទៅកិនស្រូវនៅសហករណ៍។ នៅទីនោះបែងចែកជាប្រាំបីក្រុមមកពីសហករណ៍ផ្សេងៗគ្នា។ នៅពេលកូនរបស់ខ្ញុំមានអាយុ២ឆ្នាំ អង្គការចាត់ខ្ញុំឲ្យទៅលើកភ្លឺស្រែ ក្នុងមួយក្រុមមានសមាជិក១០នាក់ ដោយខ្មែរក្រហមកំណត់ឲ្យលើកភ្លឺស្រែក្នុងមួយថ្ងៃប្រវែង២០ម៉ែត្រ, កម្ពស់១ម៉ែត្រ, កំពូលលើ០៦ម៉ែត្រ។ អំឡុងពេល ខ្ញុំធ្វើការនៅទីនោះ យាយ ងៀម គឺជាអ្នករែកបាយម្ហូបឲ្យអ្នកធ្វើការងារនៅសហករណ៍។ គាត់គឺជាកូនកាត់ខ្មែរកម្ពុជាក្រោម ប្តីរបស់គាត់គឺជាគ្រូបង្រៀន។ ថ្ងៃមួយ ខ្ញុំនិងអ្នកនៅសហករណ៍រង់ចាំមើលផ្លូវគាត់យកបាយមកឲ្យហូបដូចរាល់ដង ប៉ុន្តែមិនឃើញ ពេលនោះមេកងដើរមកប្រាប់ថា មិនបាច់ចាំមើលផ្លូវយាយងៀមទេ គាត់ត្រូវអង្គការយកទៅសម្លាប់បាត់ហើយ។ ពេលឮដូចច្នេះ ខ្ញុំនិងអ្នកនៅទីនោះមានការតក់ស្លុត។ ក្រោយមកទៀត ខ្ញុំកំពុងតែធ្វើការងារស្រាប់តែឃើញកងឈ្លបខ្មែរក្រហមស្ពាយកាំភ្លើងបណ្តើរ តាចាន់ឌី ស្វាមីរបស់យាយសុខយកទៅ ទុកក្នុងសហករណ៍រង់ចាំពេលយប់យកទៅសម្លាប់។ តាំងពីថ្ងៃនោះមកខ្ញុំពុំដែលឃើញគាត់ និង ក្រុមគ្រួសាររបស់គាត់ទៀតនោះទេមិនដឹងថាខ្មែរក្រហមយកគាត់ទៅសម្លាប់នៅទីណាទេ។ ក្រោយមកទៀត ខាងក្រុមនិរតីបានចូលមកគ្រប់គ្រងជំនួសក្រុមពាយ័ព្យ។ បន្ទាប់ពីលើកភ្លឺស្រែរួចខ្ញុំត្រូវដើរដំដុំដីធំៗឲ្យម៉ត់មិនមានពេលសម្រាកទេ។

នៅក្នុងរបបខ្មែរក្រហម ខ្ញុំឈឺក្តៅរងារញាក់រហូតដល់បីខែទើបជាសះស្បើយ។ បើទោះបីជាខ្ញុំឈឺយ៉ាងណាក៏ខ្មែរក្រហមមិនអនុញ្ញាតឲ្យសម្រាកដែរ ខ្ញុំត្រូវត្បាញកន្ទេលកក់យ៉ាងតិចឲ្យបានបីកន្ទេលក្នុងមួយថ្ងៃ។ នៅពេលខ្មែរក្រហមបើកអង្គមេទ្ទិញ ខ្ញុំមិនដែលហ៊ានទៅមើលទេ ព្រោះខ្លាចខ្មែរក្រហមសម្លាប់មនុស្ស។ នៅពេលដែលកងទ័ពវៀតណាមចូលមករំដោះ ខ្ញុំរត់ចេញពីសហករណ៍មកដេកនៅ

ភូមិបឹងព្រីង និងភូមិព្រះពន្លា។ ខ្ញុំស្នាក់នៅវត្តខាងកើតមង្គលបុរី បានមួយយប់ព្រឹកឡើងក៏ចេញដំណើរបន្តទៀត។ គ្រាន់តែខ្ញុំចេញផុតក៏ទទួលដំណឹងថា ខ្មែរក្រហមចូលបាញ់សម្លាប់ប្រជាជននៅក្នុងវត្តនោះស្លាប់ទាំងអស់។ ខ្ញុំធ្វើដំណើរមកដល់ភ្នំស្វាយ ភូមិអូរអំបិល ក៏ស្នាក់នៅទីនោះមួយរយៈ រហូតដល់ស្ថានភាពស្ងប់ស្ងាត់ទើបត្រឡប់ចូលភូមិដុងអារញ្ញវិញ។ ជាអកុសលប្ដីរបស់ខ្ញុំទៅឃ្វាលគោនៅតាមវាលស្រែដើរជាន់មីនដែលខ្មែរក្រហមដាក់ពង្រាយជុំវិញភូមិ ស្លាប់ចោលកូននិងខ្ញុំ។ ខ្មែរក្រហមបានលួចចូលមកក្នុងភូមិពេលយប់ពីរទៅបីដងដោយបានដុតផ្ទះប្រជាជន និងសម្លាប់ប្រុសៗ។ ពេលខ្មែរក្រហមចូលមកម្ដងៗប្រជាជននាំគ្នារត់ចូលព្រៃចូលត្រង់សេចោលផ្ទះសម្បែង។ រយៈពេលជាច្រើនឆ្នាំកន្លងផុតទៅ ក៏លែងមានខ្មែរក្រហមចូលមកធ្វើបាបប្រជាជនទៀត។ ខ្ញុំបន្តរស់នៅភូមិដុងអារញ្ញរហូតមកដល់សព្វថ្ងៃ។



ផ្ទះរបស់ ហួន សាវង្ស នៅភូមិដុងអារញ្ញ សង្កាត់និមិត្ត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចុះជួបនិងសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅស្រុកកោះសូទិន

**ទូច វណ្ណេត**

ចាប់ពីថ្ងៃទី៣ដល់ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដឹកនាំដោយ លី ដេវីត, ទូចវណ្ណេត និង សាង ចាន់ធូបាន ចុះជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលកំពុងរស់នៅភូមិទី១៣ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម និងសាកសួរអំពីបទពិសោធន៍ក្នុងរបបខ្មែរក្រហម។ ក្នុងអំឡុងពេលនៃការចុះទៅមកកាន់មូលដ្ឋានកោះសូទិននេះ ក្រុមការងារជួបសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៤នាក់ និងថ្តិតយករូបភាពក្នុងស្រុកកោះសូទិននៅរដូវប្រាំងដែរ ៖

## ១) កូប មែសំ រំឭកអំពីបទពិសោធន៍ជម្លៀសទៅបាត់ដំបងក្នុងរបបខ្មែរក្រហម



ខ្ញុំឈ្មោះ កូប មែសំ អាយុ៦៦ ឆ្នាំ រស់នៅភូមិទី១៣ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំប្រកបរបរធ្វើស្រែចម្ការ និងនេសាទ។ ខ្ញុំរៀបការប្តីឈ្មោះ ស្មេះ ហ៊ូសាន់ និងមានកូនសរុបចំនួន៤នាក់។ ឪពុកខ្ញុំឈ្មោះ កូប និងម្តាយឈ្មោះ អំ ណាស់។ នៅពីក្មេង ខ្ញុំចូលរៀននៅសាលាបឋមសិក្សាចុងកោះ និងឈប់រៀនត្រឹមថ្នាក់ទី១។ នៅឆ្នាំ១៩៧០ ខ្ញុំឃើញមានបាតុកម្មដង្ហែចេញពីភូមិទៅទីរួមខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧១ និងឆ្នាំ១៩៧២ ខ្ញុំបន្តរស់នៅក្នុងភូមិដដែល ប៉ុន្តែនៅពេលនោះមានការប្រយុទ្ធគ្នារវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហមផ្ទុះឡើងយ៉ាងខ្លាំង។ នៅឆ្នាំ១៩៧៣ កងទ័ពរំដោះខ្មែរក្រហមបើកការប្រយុទ្ធទ្រង់ទ្រាយធំដែលមានការបាញ់តតាំងគ្នាអស់រយៈពេល៧យប់៧ថ្ងៃនៅក្នុងភូមិសាស្ត្រកោះសូទិននេះ។ បន្ទាប់មក ឪពុកម្តាយនាំខ្ញុំនិងប្អូនៗរត់ទៅនៅម្តុំមហាលាភដើម្បីសុវត្ថិភាព។ ក្រោយមក គ្រួសាររបស់ខ្ញុំវិលត្រឡប់មករស់នៅភូមិ។ នៅឆ្នាំ១៩៧៥ ឪពុកម្តាយខ្ញុំត្រូវបានបែងចែកឲ្យធ្វើការងារនៅកងប្រវាស់ដៃ ដើម្បីជួយប្រូតស្រូវ និងប្រមូលផលដំណាំផ្សេងៗចែកគ្នាហូប។ នៅឆ្នាំ១៩៧៦ គ្រួសារខ្ញុំត្រូវបានជម្លៀសទៅខេត្តបាត់ដំបង ដោយបានជិះកាណូតជាមួយអ្នកភូមិជម្លៀសជាច្រើនផ្សេងទៀត។ បន្ទាប់មក គ្រួសារខ្ញុំត្រូវបានដឹកមកដល់ព្រែកក្តាម និងបន្តជិះរទេះភ្លើងទៅខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង។ បន្ទាប់មក គ្រួសារខ្ញុំត្រូវបានដឹកតាមរទេះគោទៅដល់ស្រះកែវ។ នៅពេលដែលទៅដល់ទីនោះភ្លាម គ្រួសារខ្ញុំត្រូវបានបញ្ជូនទៅកង

ចល័តផ្សេងៗគ្នា ចំណែកខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅកងកុមារដែលមានទិសដៅឲ្យដក និងរែកសំណាបយកមកឲ្យកងចល័តដើម្បីស្ទូង។ ខ្ញុំត្រូវបានប្រាប់ឲ្យទៅរែកសំណាប និងទទួលរងការវាយធ្វើបាប។ ខ្ញុំត្រូវក្រោកទៅធ្វើការចាប់ពីម៉ោង៦ព្រឹក រហូតដល់ម៉ោង១១ ទើបបានឈប់សម្រាក និងបន្តធ្វើការទៀតចាប់ពីម៉ោង១ ដល់ម៉ោង៥ល្ងាច។ ខ្ញុំធ្វើការនៅការដ្ឋានបឹងពើតស្ថិតនៅខេត្តបាត់ដំបង។ បឹងពើត គឺធំណាស់ និងមានតែវាលស្រែ។ នៅឆ្នាំ១៩៧៩ ខ្ញុំបានរួចផុតពីសេចក្តីស្លាប់ និងវិលត្រឡប់មករស់នៅភូមិកំណើតវិញ។

## ២) កូប ស៊ីយ៉ាស់ ចែករំលែកអំពីបទពិសោធន៍ក្នុងកងចល័តនារី និងការបាត់បង់បងប្រុសស្រីក្នុងរបបខ្មែរក្រហម



ខ្ញុំឈ្មោះ កូប ស៊ីយ៉ាស់ អាយុ៧២ ឆ្នាំ រស់នៅភូមិទី១៣ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំរៀបការប្តីឈ្មោះ សេន សីម និងមានកូនសរុបចំនួន៥នាក់។ ខ្ញុំប្រកបរបរធ្វើស្រែចម្ការ និងនេសាទ។ ឪពុកខ្ញុំឈ្មោះ ស្លាយ ម៉ាន និងម្តាយឈ្មោះ ស៊ិះ អំណាស់។ ខ្ញុំគឺជាកូនទី៣ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៩ នាក់។ ខ្ញុំកើតនៅភូមិទី១៣ ឃុំកោះសូទិន ស្រុកកោះសូទិន នេះតែម្តង។ កាលពីក្មេង ខ្ញុំមិនបានរៀនសូត្រទេ ដោយសារជីវភាពគ្រួសារមានការលំបាក។ នៅឆ្នាំ១៩៧០ មានរដ្ឋប្រហារទម្លាក់សម្តេចឪកើតឡើង។ ក្រោយមកមានបាតុកម្មកើតឡើង និងបាតុករបានដង្ហែទៅកាន់ទីរួមខេត្តកំពង់ចាម។ នៅពេលនោះគ្រួសារខ្ញុំរត់ទៅរស់នៅម្តុំរកាកោង។ នៅឆ្នាំ១៩៧៦ គ្រួសារខ្ញុំត្រូវបានជម្លៀសទៅខេត្តបាត់ដំបងតាមផ្លូវទឹក (ស្រឡាង) និងផ្លូវគោក (រទេះភ្លើង)។ ខ្ញុំត្រូវបានដាក់ឲ្យធ្វើការនៅកងចល័តនារីដើម្បីដើរដកស្ទូង រែកដី និងលើកទំនប់។ ខ្ញុំត្រូវទៅធ្វើការចាប់ពីម៉ោង៦ព្រឹកដល់ម៉ោង១១ទើបបានឈប់សម្រាកថ្ងៃត្រង់ និងបន្តទៅធ្វើការងារទៀតចាប់ពីម៉ោង១ដល់ម៉ោង៥ល្ងាច។ នៅពេលនោះ ខ្ញុំត្រូវស្ទូងស្រូវ។ ប្រសិនបើមានអ្នកស្ទូងស្រូវអណ្តែតមួយដើម អ្នកនោះនឹងត្រូវបានឈ្លបចាប់វាយដៃ ឬសម្លាប់ចោល។ បងស្រីរបស់ខ្ញុំបានដួលដោយសារតែភ្លៀងធ្លាក់ខ្លាំង និងត្រូវបានចាប់យកទៅធ្វើទារុណកម្មដោយការក្របួចសក់ឡើងលើ និងវាយធ្វើបាប។ ខ្ញុំធ្វើការនៅការដ្ឋានរាំងក្រោល ដែលប្រធានកងចល័តឈ្មោះ (តា) ណុច និងប្រពន្ធឈ្មោះ (យាយ) ចាន់។ ប្រធានកងចល័ត និងប្រពន្ធមានចរិតកាចសាហាវខ្លាំងណាស់។ បងប្រុសស្រីរបស់ខ្ញុំចំនួន៣នាក់បានស្លាប់នៅការដ្ឋានដោយសារតែអត់បាយ ហូបគ្រប់គ្រាន់។ ខ្ញុំរួចផុតពីការកាប់សម្លាប់ និងការអត់ឃ្លាននៅពេលនោះ។ ខ្ញុំនៅតែចងចាំបងប្រុសស្រីរបស់ខ្ញុំដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម។

## ៣) ណូ យ៉ាន រំឭកអំពីបទពិសោធន៍ជម្លៀសក្នុងរបបខ្មែរក្រហម



ខ្ញុំឈ្មោះ ណូ យ៉ាន អាយុ៥៨ឆ្នាំ រស់នៅភូមិទី១៣ក្រោម ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំមានស្រុកកំណើត នៅភូមិឃុំនេះតែម្តង។ ខ្ញុំរៀបការប្រពន្ធឈ្មោះ គាត សារ៉ស់ និងមានកូន៥នាក់ប្រុសទាំង៥។ បច្ចុប្បន្ន ខ្ញុំប្រកបរបរជា

កសិករ។ ឪពុកខ្ញុំឈ្មោះ ណូ ឡែម៉ាន និងម្តាយឈ្មោះ ស៊ីប ភ័ស្តុ បងប្អូន៥នាក់ប្រុស៣ស្រី២ ខ្ញុំជាកូនទី៤។ នៅឆ្នាំ១៩៧០ មានបាតុកម្មកើត ឡើងក្រោយរដ្ឋប្រហារទម្លាក់សម្តេចឪ ខ្ញុំឃើញអ្នកស្រុកនាំគ្នាធ្វើបាតុកម្មដង្ហែរទៅ ទីរួមខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧១ដល់ឆ្នាំ១៩៧២ កងរំដោះខ្មែរក្រហមត្រូវបានបញ្ជូនមកឈរជើងនៅក្នុងភូមិ។ បន្ទាប់មកទាហានលន់ នល់ ទាំងផ្លូវអាកាស និងផ្លូវគោកត្រូវបានបញ្ជូនមកប្រយុទ្ធជាមួយកងទ័ពរំដោះខ្មែរក្រហម។ នៅពេលនោះ ម្តាយខ្ញុំនាំកូនៗរត់ចូលរណ្តៅត្រង់សេ រហូតដល់ពេលស្ថានភាពស្ងប់ស្ងាត់ទៅវិញ ទើបនាំកូនចៅចេញពីរណ្តៅវិញ។ នៅឆ្នាំ១៩៧៥ គ្រួសារខ្ញុំត្រូវបានជម្លៀសទៅខេត្តបាត់ដំបង ដោយជិះកាណូតទៅដល់ភ្នំពេញ និងបន្ទាប់មកឡើងជិះរទេះភ្លើងបន្ត។ នៅពេលដល់ខេត្តបាត់ដំបង គ្រួសារខ្ញុំត្រូវជិះរទេះគោ ទៅរស់នៅក្នុងភូមិបញ្ញា ឪពុកម្តាយខ្ញុំត្រូវបានឲ្យធ្វើការនៅក្នុងកងវ័យកណ្តាល។ បងទី១របស់ខ្ញុំ ត្រូវបានឲ្យធ្វើការកងចល័តតំបន់ និងបងទី២ ត្រូវបានដាក់ក្នុងកងចល័ត។ ចំណែកឯខ្ញុំវិញត្រូវដាក់ក្នុងកងកុមារដើរកាត់ស្មៅ និងលើកអាចម៍គោ នៅក្រោមផ្ទះរបស់អ្នកភូមិដែលចញ្ចឹមគោ។ ខ្ញុំត្រូវក្រោកពីម៉ោង៥ទៀបភ្លឺទៅកើបអាចម៍គោ។ កុមារីគឺជាអ្នកកាន់បង្គី ចំណែកឯកុមារាគឺជាអ្នកកើបអាចម៍ដាក់បង្គី និងយកទៅចាក់ចូលនៅក្នុងរណ្តៅជី។ ការហូបចុករបស់ខ្ញុំនៅពេលនោះគឺហូបបបររាវក្នុងមួយថ្ងៃ២ពេល គឺពេលថ្ងៃត្រង់ និងពេលល្ងាច។

## ៤) ឡិប អេល ចែករំលែកអំពីបទពិសោធន៍នៅកងភ្ជួររាស់ក្នុងរបបខ្មែរក្រហម

ខ្ញុំឈ្មោះ ឡិប អេល អាយុ៧២ឆ្នាំ រស់នៅភូមិទី១៣ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម។ ខ្ញុំមានស្រុកកំណើតឃុំស្រុកនេះតែម្តង។ ខ្ញុំរៀបការប្រពន្ធឈ្មោះ ស្មាន សារ៉ស់ និងមានកូន៦នាក់ស្រី២ ប្រុស៤។ បច្ចុប្បន្ន ខ្ញុំប្រកបរបរជាកសិករ។



ឪពុកខ្ញុំឈ្មោះ ឡិប និងម្តាយឈ្មោះ យ៉ុ។ ខ្ញុំមានបងប្អូន៤នាក់ប្រុស២ស្រី២ ហើយខ្ញុំគឺជាកូនទី១។ នៅពីក្មេងខ្ញុំរៀននៅសាលាបឋមសិក្សាចុងកោះ ខ្ញុំរៀនបានថ្នាក់ទី១២សង្គមចាស់។ ខ្ញុំបានឈប់រៀនដោយសារជីវភាពគ្រួសាររបស់ខ្ញុំមានការលំបាក។ នៅឆ្នាំ១៩៧០ មានរដ្ឋប្រហារទម្លាក់សម្តេចឪ ហើយមានការបាញ់គ្នា និងការទម្លាក់គ្រាប់បែកខ្ទាំងផ្ទះសម្បែងនៅទឹកដីកោះសូទិន ផ្តើមចេញពីសមរភូមិប្រយុទ្ធរវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម។ នៅឆ្នាំ១៩៧២ គ្រួសារខ្ញុំរត់ទៅនៅកោះកំពង់ត្រុំជិតជាយខេត្តកំពង់ចាម។ នៅឆ្នាំ១៩៧៣ ខ្ញុំបានមករស់នៅ ខាងកោះសូទិនវិញ។ នៅឆ្នាំ១៩៧៥ គ្រួសារខ្ញុំត្រូវបានជម្លៀសទៅខេត្តបាត់ដំបង ដោយជិះកាណូតទៅដល់ភ្នំពេញ បន្ទាប់មកឡើងជិះរទេះភ្លើងបន្ត។ នៅឆ្នាំ១៩៧៦ ខ្មែរក្រហមឲ្យខ្ញុំកាន់គោភ្ជួររាស់ ធ្វើស្រែដែលមានផ្ទៃដី៥០០ហិចតា។ ខ្ញុំក្រោកពីម៉ោង៤ទៀបភ្លឺទៅប្រជុំជួររួចទឹមគោមកភ្ជួរដី ១ហិចតាគោ៥នឹមភ្ជួររួចរាល់នៅម៉ោង១០ព្រឹក ទើបមកហូបបបរ និងយកគោទៅឲ្យស៊ីស្មៅរហូតដល់ម៉ោង៤រសៀល ទើបដឹកគោត្រឡប់មកវិញ។ នៅដើមឆ្នាំ១៩៧៩ ខ្ញុំរួចផុតពីសេចក្តីស្លាប់នៅពេលនោះ និងវិលត្រឡប់មករស់នៅជួបជុំគ្រួសារវិញ។

# ជីវិតក្នុងរបបខ្មែរក្រហមនៅភូមិបុស្សតាអឹម

**ឈុំ រ៉ា និង ទ៊ី ស៊ីថា**

នៅព្រឹកថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៣ ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកោះថ្ម រួមមាន ឈុំ រ៉ា និង ទី ស៊ីថា បានធ្វើដំណើរទៅកាន់ភូមិបុស្សតាអឹម ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដើម្បីទំនាក់ទំនងជាមួយអាជ្ញាធរ និង ប្រជាពលរដ្ឋក្នុងភូមិបុស្សតាអ៊ឹម ក្នុងគោលបំណងរៀបចំវេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាប្រជាធិប-តេយ្យ (១៩៧៥-១៩៧៩) នៅពេលខាងមុខៗ ឆ្លៀតឱកាសនោះ យើងបានជួបសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន៣រូប ហើយអ្នកទាំងនោះបានរៀបរាប់អំពីប្រវត្តិភូមិ និងរឿងរ៉ាវជីវិតឆ្លងកាត់របបខ្មែរក្រហមដូចខាងក្រោម ៖

## កង យីន



កង យីន គឺជាមេភូមិបុស្សតាអឹម រៀបរាប់អំពីប្រវត្តិរបស់ភូមិនេះដូចតទៅ៖ កាលពីដើមខ្ញុំឮប្រជាជនក្នុងភូមិបុស្សតាអឹមដំណាលតគ្នាថា មានក្រុមគ្រួសារមួយមានកូនបីនាក់ឈ្មោះអឹម, ពេជ្រ និងម៉ៅ។ ពេលកូនៗទាំងបីនាក់ធំឡើងមានប្រពន្ធកូនរៀងៗខ្លួន ក៏នាំគ្នាទៅធ្វើស្រែចម្ការនៅកន្លែងផ្សេងៗគ្នា។ ក្រុមគ្រួសារពេជ្របានទៅកាប់ឆ្ការដីបុស្សហើយរស់នៅត្រង់នោះ សព្វថ្ងៃទីនោះមានឈ្មោះថាភូមិស្រែតាពេជ្រ។ ចំពោះគ្រួសារម៉ៅវិញបានទៅរស់នៅទីតាំងមួយ ដែលបច្ចុប្បន្នប្រជាជនហៅថាភូមិជាំតាម៉ៅ។ ចំណែកក្រុមគ្រួសារឈ្មោះអឹម គឺបាននៅធ្វើស្រែចម្ការ កាប់ឆ្ការដីបុស្សនៅត្រង់ភូមិបុស្សតាអឹមនេះមុនគេ ហើយគាត់មានសណ្តានចិត្តល្អ ធ្វើឲ្យអ្នកភូមិស្រឡាញ់ចូលចិត្ត កោតសរសើរ រីឯតាអឹមក៏ធ្វើអំពើល្អទៅលើប្រជាពលរដ្ឋនៅក្នុងភូមិដែរ។ នៅពេលគាត់ស្លាប់ទៅអ្នកភូមិបាននាំគ្នាហៅឈ្មោះភូមិនេះថា ភូមិបុស្សតាអឹមរហូតមកដល់សព្វថ្ងៃនេះ ដើម្បីជាការនឹករឭកដល់ តាអឹម ដែលបានកាប់ឆ្ការដីបុស្សនៅក្នុងភូមិនេះ។ សព្វថ្ងៃនេះភូមិបុស្សតាអឹមមានប្រជាជនរស់នៅចំនួន១០៦២នាក់ ស្រី៥៤៩នាក់ ក្នុងនោះចាប់ពីអាយុ១៨ឡើងមានចំនួន៧០៥នាក់ បើគិតជាគ្រួសារមានចំនួន ២៨៥គ្រួសារ។

## ស្ងួន សុធី



លោក ស្ងួន សុធី ភេទប្រុស អាយុ៦៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិបុស្សតាអឹម ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ ស្ងួន ធី មានប្រពន្ធឈ្មោះ លឿង សុខឡេង មានកូនចំនួន៣នាក់ ស្រី២នាក់បានរៀបរាប់

ថា ៖ កាលពីកុមារ ខ្ញុំទៅរស់នៅជាមួយឪពុកធ្វើជាទាហាននៅទីក្រុងភ្នំពេញ។ ថ្វីត្បិតតែខ្ញុំរស់នៅជាមួយឪពុកមែនប៉ុន្តែ ខ្ញុំមិនបានជួបគាត់ទេ ព្រោះគាត់មិនសូវនៅផ្ទះ។ ព្រឹកឡើងខ្ញុំដឹងតែទៅរៀននៅសាលាសន្ធរម៉ុក។ ពេលនោះខ្ញុំជិតប្រឡងចូលអនុវិទ្យាល័យ ប៉ុន្តែមិនទាន់បានប្រឡងនៅឡើយ។ ក្រោយពេលដែលខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ឪពុករបស់ខ្ញុំត្រូវខ្មែរក្រហមចាប់ទៅសម្លាប់ ព្រោះឪពុកខ្ញុំជាទាហាន លន់ នល់។ ខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ ខ្មែរក្រហមបាននិយាយថានៅទីក្រុងខ្វះស្បៀងសម្រាប់ហូប ណាមួយខ្លាចអាមេរិកទម្លាក់គ្រាប់បែក។ ខ្ញុំត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញមករស់នៅភូមិជើងព្រៃ ឃុំជើងព្រៃ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ ទម្រាំមកដល់ខេត្តកំពង់ចាម ខ្ញុំធ្វើដំណើរអស់រយៈពេល១សប្តាហ៍។ ខ្ញុំបានមករស់នៅជាមួយម្តាយធំដែលជាសាច់ញាតិខាងម្តាយ។ ដំបូងខ្ញុំចូលជាកងកុមារនៅក្នុងភូមិជើងព្រៃ។ បន្ទាប់មកនៅក្នុងភូមិជើងព្រៃមានការបែងចែកប្រជាជនចំនួន៣ប្រភេទគឺប្រជាជនចាស់ ប្រជាជន៧៣ និងប្រជាជនថ្មី។ ខ្ញុំត្រូវខ្មែរក្រហមចាត់ទុកជាប្រជាជនថ្មី។ នៅក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀសប្រជាជនថ្មីចេញពីភូមិ ដោយប្រាប់ថាឲ្យទៅរស់នៅភូមិថ្មីមួយទៀត។ ប្រជាជនដែលត្រូវបានខ្មែរក្រហមជម្លៀសចេញពីដំបូងគឺមិនដែលឃើញត្រឡប់មកវិញទេ។ នៅឆ្នាំ១៩៧៨ ខ្ញុំចូលក្នុងក្រុមកងចល័តលើកប្រព័ន្ធភ្លឺស្រែ លើកទំនប់រហូតដល់ខេត្តកំពង់ធំ។ នៅក្នុងកងចល័ត គឺពិបាកខ្លាំងណាស់ ព្រោះការហូបចុកមិនដែលបានគ្រប់គ្រាន់នោះទេ។ ប្រជាជននៅក្នុងកងស្លាប់ជារៀងរាល់ថ្ងៃដោយសារតែអត់មានអាហារ។ ចំណែកខ្ញុំក៏ជិតស្លាប់ដែរ ប៉ុន្តែបានចាកចេញពីកងចល័តខេត្តកំពង់ធំទាន់ពេលវេលា។ ចូលដល់ឆ្នាំ១៩៧៩ ខ្ញុំចូលបម្រើនៅក្នុងកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា វាយជាមួយខ្មែរក្រហម នៅខេត្តកំពង់ធំ។ នៅឆ្នាំ១៩៨៥ ខ្ញុំត្រូវរបួសដៃនៅក្នុងសមរភូមិស្ទាយចេក និងពិការរហូតមកដល់សព្វថ្ងៃ។

## ស៊ិន ញិប



ខ្ញុំឈ្មោះ ស៊ិន ញិប ភេទស្រី អាយុ៦៨ឆ្នាំ មានទីកន្លែងកំណើតនៅភូមិតាម៉ៅ ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម បច្ចុប្បន្នខេត្តត្បូងឃ្មុំ។ ខ្ញុំមានឪពុកឈ្មោះ ស៊ិន និង ម្តាយឈ្មោះ ឆេង។ ឪពុករបស់ខ្ញុំស្លាប់នៅក្នុងជំនាន់ខ្មែរក្រហម ពេលនោះគាត់គឺជា កម្មាភិបាលនៅសហករណ៍។ កាលពីសម័យខ្មែរក្រហម ខ្ញុំមិនបានរស់នៅក្បែរឪពុកម្តាយទេ។ កម្មាភិបាលខ្មែរក្រហមចាត់ខ្ញុំឲ្យទៅលើកទំនប់នៅបឹងក្រចាប់ ដោយធ្វើការទាំងយប់ទាំងថ្ងៃ។ នរណាមិនទៅធ្វើការងារគឺខ្មែរក្រហមមិនចែករបបបាយឬបបរឲ្យហូបទេ។ មុនពេលទៅធ្វើការ ខ្មែរក្រហមតែងតែប្រជុំដាស់តឿនឲ្យប្រជាជនស្មោះត្រង់ជាមួយអង្គការ និងខិតខំធ្វើការងារឲ្យអស់ពីកម្លាំងកាយចិត្ត កុំលាក់កម្លាំង កុំធ្វើខុសច្បាប់ និងវិន័យរបស់អង្គការ។ សព្វថ្ងៃខ្ញុំគឺជាស្ត្រីមេម៉ាយរស់នៅពឹងផ្អែកទៅលើការត្បាញកន្ទេលលក់ដើម្បីចិញ្ចឹមកូន៩នាក់។ ខ្ញុំកាប់ដើមរុនមកធ្វើជាកន្ទេល និងក្រង់ស្បូវលក់។ ការកាប់ដើមរុនប្រើរយៈពេលយូរ ព្រោះដើមរុនពិបាករក ហើយពេលដែលកាប់បានត្រូវយកមកពុះមួយដើមជាបួនចម្រៀក រួចដាក់ហាលឲ្យស្ងួត។ បន្ទាប់មក ត្រូវយកមកសិតឲ្យស្អាត រួចយកទៅត្បាញ និងដេរជាកន្ទេល។ នៅពេលដែលធ្វើកន្ទេលរួចរាល់ គឺមានឈ្មួញមកទិញដល់ផ្ទះមិនដែលសល់ឡើយ។

# អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតំបន់ដាច់ស្រយាលនៃភូមិបាក់នឹម

## មកទស្សនកិច្ចព្រះបរមរាជវាំង បណ្ណាល័យសម្តេចម៉ែ និងស្ថានទូតហ្វីលីពីន

ផាត ចាន់សុនិតា



អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រួមជាមួយកូន និងចៅចំនួន១៥នាក់ មកពីតំបន់ដាច់ស្រយាលនៃភូមិបាក់នឹម មកធ្វើទស្សនកិច្ចព្រះបរមរាជវាំង, បណ្ណាល័យសម្តេចម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងក្រុងភ្នំពេញ, ស្ថានទូតហ្វីលីពីន ព្រមទាំងទីតាំងវប្បធម៌ និងប្រវត្តិសាស្ត្រមួយចំនួនទៀតក្នុងទីក្រុងភ្នំពេញរយៈពេលពីរថ្ងៃ គឺចាប់ពីថ្ងៃទី០៨ ដល់០៩ ខែឧសភា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រួមជាមួយកូន និងចៅចំនួន១៥នាក់ មកពីតំបន់ដាច់ស្រយាលនៃភូមិបាក់នឹម ត្រូវបានអញ្ជើញឲ្យមកធ្វើទស្សនកិច្ចព្រះបរមរាជវាំង, បណ្ណាល័យសម្តេចម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងក្រុងភ្នំពេញ, ស្ថានទូតហ្វីលីពីន ព្រមទាំងទីតាំងវប្បធម៌ និងប្រវត្តិសាស្ត្រមួយចំនួនទៀតក្នុងទីក្រុងភ្នំពេញរយៈពេលពីរថ្ងៃ





អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រួមជាមួយកូន និងចៅចំនួន១៥នាក់ មកពីតំបន់ដាច់ស្រយាលនៃភូមិបាក់នីម មកធ្វើទស្សនកិច្ចព្រះបរមរាជវាំង, បណ្ណាល័យសម្តេចម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងក្រុងភ្នំពេញ, ស្ថានទូតហ្វីលីពីន ព្រមទាំងទីតាំងវប្បធម៌ និងប្រវត្តិសាស្ត្រមួយចំនួនទៀតក្នុងទីក្រុងភ្នំពេញរយៈពេលពីរថ្ងៃ គឺចាប់ពីថ្ងៃទី០៨ ដល់០៩ ខែឧសភា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

គឺចាប់ពីថ្ងៃទី០៨ ដល់០៩ ខែឧសភា ឆ្នាំ២០២៣។ ដំណើរទស្សនកិច្ចនេះរៀបចំឡើងដោយ ក្រុមការងារគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» នៃមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងគោលបំណងដើម្បីឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរស់នៅតំបន់ដាច់ស្រយាលបានសិក្សាឈ្វេងយល់បន្ថែមពីចំណេះដឹងប្រវត្តិសាស្ត្រសង្គម វប្បធម៌ ខាងក្រៅឲ្យកាន់តែទូលំទូលាយ។

នៅថ្ងៃទីមួយ នៃដំណើរទស្សនកិច្ច ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានដឹកអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីតំបន់ដាច់ស្រយាលនៃភូមិបាក់នីម តាមរថយន្តឆ្ពោះមកកាន់ទីក្រុងភ្នំពេញ។



នៅថ្ងៃនេះ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមពីតំបន់ដាច់ស្រយាលនៃភូមិបាក់នីមអញ្ជើញទៅទស្សនកិច្ចព្រះបរមរាជវាំង។ បន្ទាប់មក អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីតំបន់ដាច់ស្រយាលនៃភូមិបាក់នីម ទាំងនេះបន្តដំណើរ មកទស្សនកិច្ចបណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានចម្ងាយប្រមាណ ១,០០០ម៉ែត្រ ពីព្រះបរមរាជវាំង។

លោកឆាំងយុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលស្វាគមន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទាំងនេះយ៉ាងកក់ក្តៅ។ លោក ឆាំង យុ បានសួរសុខទុក្ខអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីតំបន់ដាច់ស្រយាលនៃភូមិបាក់នីម និងកូនចៅ ហើយបានរៀបរាប់លើកឡើងអំពីគោលបំណងនៃការបង្កើតបណ្ណាល័យសម្តេចម៉ែ និងអំពីឱកាសឲ្យអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពិនិត្យសុខភាពជាមួយក្រុមគ្រូពេទ្យជំនាញជនជាតិហ្វីលីពីននៅការិយាល័យមជ្ឈមណ្ឌលឯកសារកម្ពុជាចល័ត

ក្នុងសហគមន៍ បាក់នឹម ដោយឥតគិតថ្លៃ និងផ្តល់ឱកាសឲ្យមានការជជែកពិភាក្សាអំពីរឿងរ៉ាវដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។

នៅវេលាម៉ោង១:៣០នាទីរសៀល អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតំបន់ដាច់ស្រយាលនៃភូមិបាក់នឹម រួមទាំងកូនចៅ បានបន្តដំណើរទស្សនកិច្ចទៅកាន់ស្ថានទូតហ្វីលីពីន ដើម្បីជួបជាមួយឯកអគ្គរដ្ឋទូតហ្វីលីពីនលោកស្រី MARIA AMELITA C.AQUINO។ នៅក្នុងជំនួបនេះ ឯកអគ្គរដ្ឋទូតហ្វីលីពីនលោកស្រី MARIA AMELITA C.AQUINO បានសួរសុខទុក្ខអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទាំងនេះ និងអរគុណដែលបានផ្តល់កិត្តិយសមកទស្សនកិច្ចនៅស្ថានទូតហ្វីលីពីនផ្ទាល់។ ឯកអគ្គរដ្ឋទូតហ្វីលីពីន ក៏បានរៀបរាប់ពីប្រវត្តិប្រទេសហ្វីលីពីន ព្រមទាំងទំនាក់ទំនងល្អរវាងប្រទេសកម្ពុជា និងហ្វីលីពីនតាំងពីយូរមកហើយ។ ឯកអគ្គរដ្ឋទូតហ្វីលីពីនបានបន្ថែមថា មានសហគមន៍ជនជាតិហ្វីលីពីនមួយបានមករស់នៅក្បែរព្រះបរមរាជវាំងក្នុងក្រុងភ្នំពេញ ហើយជនជាតិហ្វីលីពីនខ្លះបានចូលបម្រើការងារនៅព្រះបរមរាជវាំង ប៉ុន្តែបច្ចុប្បន្នសហគមន៍នោះលែងមានទៀតហើយ។ នៅឱកាសនោះ ឯកអគ្គរដ្ឋទូតហ្វីលីពីនលោកស្រី MARIA AMELITA C.AQUINO បានសាកសួរទៅអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមថា តើការកាត់ទោសមេដឹកនាំខ្មែរក្រហមពីសាលាក្តីខ្មែរក្រហមកន្លងមកពួមីង ទទួលបានយុត្តិធម៌គ្រប់គ្រាន់ហើយឬនៅ? អ្នកភូមិម្នាក់ក្នុងចំណោមអ្នកភូមិដែលមកចូលរួមបានឆ្លើយថា គឺមិនគ្រប់គ្រាន់ទេ គឺទាល់តែយកមេដឹកនាំខ្មែរក្រហមទាំងនោះមកសម្លាប់ ឬមកធ្វើការងារធ្ងន់ធ្ងរដូចគាត់ដែរទើបមានយុត្តិធម៌។

នៅចុងបញ្ចប់នៃការជួបពិភាក្សាជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ឯកអគ្គរដ្ឋទូតហ្វីលីពីនក៏បង្ហាញពីការចាប់អារម្មណ៍និងចង់ចូលរួមចំណែកជួយ

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រួមជាមួយកូន និងចៅចំនួន១៥នាក់ មកពីតំបន់ដាច់ស្រយាលនៃភូមិបាក់នឹម មកធ្វើទស្សនកិច្ចព្រះបរមរាជវាំង, បណ្ណាល័យសម្តេចម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងក្រុងភ្នំពេញ, ស្ថានទូតហ្វីលីពីន ព្រមទាំងទីតាំងវប្បធម៌ និងប្រវត្តិសាស្ត្រមួយចំនួនទៀតក្នុងទីក្រុងភ្នំពេញរយៈពេលពីរថ្ងៃ គឺចាប់ពីថ្ងៃទី០៨ ដល់០៩ ខែឧសភា ឆ្នាំ២០២៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ដល់ការងារមនុស្សធម៌មួយចំនួននៅក្នុងសហគមន៍បាក់នឹម ដូចជាការជួយសាងសង់អគារជួបប្រជុំដើម្បីបម្រើផលប្រយោជន៍ដល់សាធារណជនក្នុងសហគមន៍នៅពេលខាងមុខដែរ។

បន្ទាប់ពីជួប ឯកអគ្គរដ្ឋទូតហ្វីលីពីនលោកស្រី MARIA AMELITA C.AQUINO រួចមក ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបន្តជូនដំណើរអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅភូមិបាក់នឹម ទស្សនាទិដ្ឋភាពនៅជុំវិញទីក្រុងភ្នំពេញ។

នៅព្រឹកថ្ងៃទីពីរ នៃដំណើរទស្សនកិច្ច ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា នឹងជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទៅពិនិត្យសុខភាពនៅមន្ទីរសម្រាកព្យាបាលឯកជន។ សូមបញ្ជាក់ថា កន្លងមកក្រុមការងារ «គម្រោងការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ធ្លាប់បានចុះទៅពិនិត្យសុខភាពបឋមជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅភូមិបាក់នឹមបានចំនួន៨៤នាក់រួចមកហើយ ដោយវេជ្ជបណ្ឌិតជនជាតិហ្វីលីពីន ដេមី រៃយ៍។ បន្ទាប់ពីពិនិត្យសុខភាពនៅមន្ទីរពេទ្យរួច ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា នឹងជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទៅទស្សនកិច្ចវត្តលង្កា ដែលមានទីតាំងស្ថិតនៅក្បែរវិមានឯករាជ្យ និងពហុកីឡដ្ឋានជាតិមរតកតេជោ ដែលទើបនឹងសាងសង់ថ្មីសម្រាប់ការប្រកួតស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេម លើកទី១២ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ មុននឹងវិលត្រឡប់ទៅផ្ទះវិញ។

នៅក្នុងដំណើរទស្សនកិច្ចនេះ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមមកពីភូមិបាក់នឹមបានបង្ហាញចំណាប់អារម្មណ៍ដូចខាងក្រោម ៖

ពយ អ៊ួច អាយុ៦៤ឆ្នាំ មេភូមិបាក់នឹម ឃុំប្រេស ស្រុកជុំគិរី ខេត្តកំពត សម្តែងនូវការរីករាយដែលបានមកទស្សនាបណ្ណាល័យសម្តេចម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជាដោយផ្ទាល់។ ពយ អ៊ួច បានលើកឡើងថា «នេះគឺជាលើកទីមួយហើយ ដែលខ្ញុំបានមកទស្សនកិច្ចនៅទីនេះ និងធ្វើឲ្យខ្ញុំយល់ដឹងអំពីរឿងរ៉ាវប្រវត្តិសាស្ត្រថែមទៀត។ ខ្ញុំអរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានយកចិត្តទុកដាក់លើបញ្ហាសុខរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិ ព្រមទាំងបានផ្តល់ម៉ូតូកង់បីមួយគ្រឿងដល់ឃុំបាក់នឹមសម្រាប់ដឹកអ្នកជំងឺដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិទៅកាន់មន្ទីរពេទ្យដោយឥតគិតថ្លៃថែមទៀត»។

ទូច ទ្រី អាយុ៦០ឆ្នាំ រស់នៅភូមិបាក់នឹម ឃុំប្រេស ស្រុកជុំគិរី ខេត្តកំពត បានរៀបរាប់ថា «ខ្ញុំមកនេះ គឺគ្មានបំណងអ្វីក្រៅពីបានមកស្គាល់ព្រះបរមរាជវាំង បណ្ណាល័យសម្តេចម៉ែនៃមជ្ឈមណ្ឌលឯកសារកម្ពុជា និងមកពិនិត្យសុខភាពទេ ហើយនេះគឺជាលើកទីមួយរបស់ខ្ញុំ។ ដំណើរទស្សនកិច្ចនេះធ្វើខ្ញុំសប្បាយរីករាយ។ ខ្ញុំឃើញទីក្រុងភ្នំពេញមានការអភិវឌ្ឍន៍ និងរីកចម្រើនខុសពីពេលមុន»។





អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម រួមជាមួយកូន និងចៅចំនួន១៥នាក់ មកពីតំបន់ដាច់ស្រយាលនៃភូមិបាក់នឹម មកធ្វើទស្សនកិច្ចព្រះបរមរាជវាំង, បណ្ណាល័យសម្តេចម៉ែ នៃមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងក្រុងភ្នំពេញ, ស្ថានទូតហ្វីលីពីន ព្រមទាំងទីតាំងវប្បធម៌ និងប្រវត្តិសាស្ត្រមួយចំនួនទៀតក្នុងទីក្រុងភ្នំពេញរយៈពេលពីរថ្ងៃ គឺចាប់ពីថ្ងៃទី០៨ ដល់០៩ ខែឧសភា ឆ្នាំ២០២៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ង៉ែត យុន ៖ មេភូមិស្នើសុំកង់របស់ខ្ញុំដាក់ជារបស់រួម

**ដារ៉ារដ្ឋ មេត្តា**



ង៉ែត យុន អាយុ៨០ឆ្នាំ សព្វថ្ងៃរស់នៅឃុំក្រាំងស្នាយ ស្រុកឈូក ខេត្តកំពត។ ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២។ (ដាត ពន្ទក/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ង៉ែត យុន ភេទស្រី អាយុ៨០ឆ្នាំ មានស្រុកកំណើតនៅភូមិទុល្ហភ៍ ឃុំមានជ័យ ស្រុកឈូក ខេត្តកំពត ប៉ុន្តែសព្វថ្ងៃខ្ញុំរស់នៅឃុំក្រាំងស្នាយ ស្រុកឈូក ខេត្តកំពត។ ខ្ញុំរៀនបានត្រឹមថ្នាក់មធ្យមដ្ឋាន ដោយដំបូងឡើយខ្ញុំរៀននៅវត្ត ក្រោយមករៀននៅសាលានរាយណ៍ ស្ថិតនៅ ស្រុកឈូក ខេត្តកំពត។ បន្ទាប់មក ខ្ញុំឈប់រៀន ហើយមកជួយមើលគោ និងធ្វើការងារឪពុកម្តាយ។ ខ្ញុំរៀបការនៅក្នុងរបប លន់ នល់។ ប្តីរបស់ខ្ញុំមកពីខេត្តតាកែវ។ អំឡុងឆ្នាំ១៩៧០ មានការទម្លាក់គ្រាប់បែកជាច្រើនគ្រាប់ ប៉ុន្តែមិនមានគ្រោះថ្នាក់ដល់អាយុជីវិតមនុស្សទេ។ នៅក្នុងរបប លន់ នល់ ខ្ញុំសន្សំប្រាក់ទិញបានកង់មួយគ្រឿង ហើយពេលទៅណាមកណាខ្ញុំបានជិះកង់នោះ។ កង់របស់ខ្ញុំធ្វើពីដែក ដោយកាលនោះខ្ញុំទិញក្នុងតម្លៃ៣៥០រៀល។ ខ្ញុំស្រឡាញ់កង់នោះ និងចាត់ទុកជាទ្រព្យសម្បត្តិមានតម្លៃសម្រាប់ខ្ញុំ។

ពេលខ្មែរក្រហមចូលមកគ្រប់គ្រងក្នុងភូមិ មេភូមិបានរឹបអូសកង់ខ្ញុំដាក់ជារបស់រួម។ ខ្ញុំត្រូវតែយល់ព្រមតាមការស្នើសុំ។ កាលនោះគ្រួសារខ្ញុំមានជីវភាពមធ្យម ព្រោះមានបាយហូបគ្រប់គ្រាន់ ដូច្នេះអង្គការបានចាត់ទុកគ្រួសារខ្ញុំជាវណ្ណៈកណ្តាល។ ឪពុករបស់ខ្ញុំត្រូវបានអង្គការចាត់តាំងឲ្យធ្វើការងារខាងសង្គមកិច្ច ប៉ុន្តែគាត់មិនទទួលបានរបបខោអាវ ដែលអង្គការបើកឲ្យនោះទេ។ ចំណែកខ្ញុំ អង្គការចាត់តាំងឲ្យទៅកងចល័តរែកដី និងលើកទំនប់។ អង្គការសង្កេតមើលនរណាដែលមានកម្លាំងមាំមួនមាឌធំ ដើម្បីបែកបង្គីធំៗឲ្យសម្រាប់រែកដី និងចាត់ចូលទៅក្នុងកងពិសេស។ ទំនប់ដែលខ្ញុំចូលរួមលើកកាលនោះរួមមាន ទំនប់អូរខ្លី, ទំនប់ម្លេច និងស្ទឹងភេ។ ខ្ញុំធ្វើការងារបានទាំងអស់តាមការចាត់តាំងរបស់អង្គការ។

ថ្ងៃមួយអង្គការបានធ្វើបាបឪពុកខ្ញុំ ដោយឲ្យគាត់ហូបពោតលីងដែលរឹង ទោះបីជាដឹងថា ធ្មេញរបស់

គាត់ពុកបាក់អស់នៅសល់តែអញ្ចាញប៉ុណ្ណោះ បន្ទាប់ពីអង្គការបង្អត់បាយគាត់អស់រយៈពេល៣ថ្ងៃ។ ខ្ញុំឃើញមានប្រជាជនថ្មី ឬប្រជាជន១៧ មេសា ដែលទើបជម្លៀសមកដល់ ត្រូវបានអង្គការយកទៅវាយចោលទាំងអស់។

ខ្ញុំដើរលើផ្លូវដែលខ្ញុំតែងតែដើររាល់លើកពេលចេញទៅ និងមកពីធ្វើការ ពេលនោះខ្ញុំឃើញសាកសពមនុស្សដែលខ្មែរក្រហមវាយចោល ហើយមិនបានយកទៅកប់។ ពេលខ្លះ ខ្ញុំឃើញឡានដឹកសាកសពមកទម្លាក់ចោលនៅទីនោះទៀតៗ ខ្ញុំបានឃើញហេតុការណ៍នោះនៅម៉ោង៨៥ ល្ងាចពេលខ្ញុំត្រឡប់មកពីធ្វើការវិញ។ ខ្ញុំមានសំណាងល្អបាននៅរស់ជីវិតមកដល់សព្វថ្ងៃ។





ទេសភាព និងដំណាំនៅផ្ទះ ង៉ែត យុន ថ្ងៃទី២ ខែឧសភា ឆ្នាំ២០២២។ (ផាត ពន្ទក/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សវិទ្យាល័យមកពីស្រុកមេមត់ចូលរួម វេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម

## និងធ្វើទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦

*ឈុំ រ៉ា*



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦ ដល់សិស្សវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន មេមត់ និងវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ដារ ចំនួន៥០នាក់ នៅព្រឹកថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦ ដល់សិស្សវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន មេមត់ និងវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ដារ ចំនួន៥០នាក់។

វេទិកាថ្នាក់រៀននេះផ្តោតសំខាន់លើការបង្កើតកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជានៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ ដើម្បីវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត សង្គ្រោះអាយុជីវិតប្រជាជនកម្ពុជា៥លាននាក់ឲ្យរួចផុតពីសេចក្តីស្លាប់។

លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្មបានដឹកនាំសិស្សានុសិស្សទស្សនាពិព័រណ៍

រូបថតអំពីសង្គ្រាមកាលពីចុងទសវត្សរ៍ឆ្នាំ១៩៦០ រូបថតអំពីរបបខ្មែរក្រហម (១៩៧៥-១៩៧៩) រូបថតអំពីជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ រូបថតអំពីភ័ស្តុតាងឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយរបបខ្មែរក្រហម (១៩៧៥-១៩៧៩) រូបគំនូរ និងផែនទីបង្ហាញផ្លូវនៃដំណើររបស់សម្តេចតេជោ ហ៊ុន សែន និងយុទ្ធមិត្ត៨រូបទៀតធ្វើដំណើរទៅប្រទេសវៀតណាមកាលថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដើម្បីសុំការអន្តរាគមន៍កសាងកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា វាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត។

ជាកិច្ចបន្តលោក ឡុង ដានី បានមានប្រសាសន៍ថា កាលពីថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣ កន្លងមកនេះ គឺជាខួបលើកទី៤៥ឆ្នាំ នៃការបង្កើតកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា (ថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ ដល់ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣)។ កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាបុ (អង្គភាព១២៥) គឺជាកងកម្លាំងប្រដាប់អាវុធដំបូងដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៨ នៅប្រទេសវៀតណាម ដើម្បីវាយផ្តួលរំលំរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-ឆ្នាំ១៩៧៩) និងសង្គ្រោះអាយុជីវិតប្រជាជនកម្ពុជាប្រមាណ៥លាននាក់ឲ្យរួចផុតពីសេចក្តីស្លាប់។ កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា មានជនជាតិខ្មែរប្រមាណជាង២០០នាក់ បានចូលរួមនៅដំណាក់កាលដំបូង។ ស្ថាបនិកនៃកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា គឺសមមិត្ត ហ៊ុន សែន អតីតប្រធានសេនាធិការ និងជាមេបញ្ជាការកងវរសេនាធំពិសេសនៃតំបន់២១ភូមិភាគបូព៌ានៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ប្រចាំនៅភូមិកោះថ្ម ឃុំទន្លូង។ បច្ចុប្បន្នសមមិត្ត ហ៊ុន សែន គឺជាសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

ការកកើតកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា គឺផ្តើមចេញពីការសម្រេចចិត្តរបស់សមមិត្ត ហ៊ុន សែន ជ្រើសរើសយកការតស៊ូប្រដាប់អាវុធប្រឆាំងនឹងរបបប្រល័យពូជសាសន៍ ប៉ុល ពត ដោយបានយកអាយុជីវិតធ្វើជាដើមទុនគឺនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ សមមិត្ត ហ៊ុន សែន និងយុទ្ធមិត្ត៨រូបទៀតរួមមាន៖ (ញឹក ហួន, ស៊ូ គីម ស្រ៊ាង ហៅ សន សាញ់, នុត ថន និង វ៉ា ប៉ោអ៊ាន) បានសម្រេចចិត្តធ្វើដំណើរចាកចេញពីបន្ទាយកងវរសេនាធំតំបន់២១នៅភូមិកោះថ្មឆ្ពោះទៅប្រទេសវៀតណាមដើម្បីកសាងកម្លាំងប្រដាប់អាវុធវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ការសម្រេចចិត្តធ្វើដំណើរទៅប្រទេសវៀតណាមរបស់សមមិត្ត ហ៊ុន សែន និងយុទ្ធមិត្ត៨រូបត្រូវប្រឈមនឹងគ្រោះថ្នាក់ធំៗដល់អាយុជីវិតមួយចំនួនដូចជា ៖

ទី១) អាចត្រូវស្លាប់ បុរបួសដោយសារជាន់មីន ពីព្រោះនៅពេលសមមិត្ត ហ៊ុន សែន និងយុទ្ធមិត្ត៨រូបធ្វើដំណើរមកដល់តំបន់ព្រំដែនត្រង់ដើមទ្រយឹងចំណុចអាងដាច់ អ៊ិច-១៦ (X-16) និងឆ្លងចូលទៅក្នុងទឹកដីវៀតណាមនោះ គឺជាតំបន់ចម្ការមីន។

ទី២) អាចត្រូវបានបាញ់សម្លាប់ពីសំណាក់កងទ័ពវៀតណាមនៅខណៈពេលឆ្លងចូលក្នុងទឹកដីវៀតណាមដោយខុសច្បាប់។

ទី៣) អាចត្រូវបានកងទ័ពនិងអាជ្ញាធរវៀតណាមចាប់ខ្លួនបញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញ និងត្រូវខ្មែរក្រហមសម្លាប់។

ទី៤) អាចប្រឈមនឹងការធ្វើទារុណកម្ម និងចាប់ដាក់ពន្ធនាគារពីសំណាក់កងទ័ព និងអាជ្ញាធរវៀតណាម។

កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាបានកើតមុន ទើបអង្គការចាត់តាំងនយោបាយ គឺរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាត្រូវបានបង្កើតឡើងតាមក្រោយក្នុងថ្ងៃ២ធ្នូ ឆ្នាំ១៩៧៨ នៅឃុំដើងឃ្មូ (ឃុំ២ធ្នូ) ស្រុកស្នួល ខេត្តក្រចេះ។ ចាប់ពីខែ



ក្រុមការងាររមជ្ឈមណ្ឌលឯកសារកោះថ្មនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦ ដល់សិស្សវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន មេមត់ និងវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ដារ ចំនួន៥០នាក់ នៅព្រឹកថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣។ (បណ្ណសាររមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឧសភា ដល់ចុងខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាបានរីកធំធាត់ និងកើនចំនួនរហូតដល់២៣កងវរសេនាតូច និងប្រមាណ១០០ក្រុមប្រតិបត្តិការប្រដាប់អាវុធ ដែលមានកងកម្លាំងសរុបប្រមាណជាង១ម៉ឺននាក់។ បន្ទាប់មកកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជាបានសហការជាមួយកងទ័ពស្ម័គ្រចិត្តវៀតណាម វាយផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត រំដោះប្រជាជនកម្ពុជាប្រមាណ៥លាននាក់ឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

កងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា បានក្លាយជាកងទ័ពប្រជាជនបដិវត្តន៍នៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងរដ្ឋកម្ពុជា (១៩៧៩-១៩៩៣)។ ថ្នាក់ដឹកនាំកងយោធពលខេមរភូមិន្ទភាគច្រើនបានប្រសូតចេញពីកងកម្លាំងប្រដាប់អាវុធសាមគ្គីសង្គ្រោះជាតិកម្ពុជា និងជាកងកម្លាំងស្នូលមានតួនាទីជាប្រតិបត្តិករក្នុងការអនុវត្តគោលនយោបាយ ឈ្នះ ឈ្នះ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ដែលនាំឲ្យប្រទេសកម្ពុជាទទួលបានសន្តិភាពទាំងស្រុងនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៨។

វេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហមបានបញ្ចប់នៅវេលាម៉ោង១១ព្រឹក។ បន្ទាប់មកលោក ឡុង ដានី បានដឹកនាំសិស្សានុសិស្សទៅទស្សនកិច្ចសិក្សានៅតំបន់ប្រវត្តិសាស្ត្រយោធា កោះថ្ម អ៊ិច-១៦ គឺជាទីតាំងដែល សម្តេច ហ៊ុន សែន និងយុទ្ធមិត្តទាំង៤រូបបានធ្វើដំណើរឆ្ពោះទៅកាន់ប្រទេសវៀតណាម ដើម្បីសុំការអន្តរាគមន៍កសាងកងកម្លាំងប្រដាប់អាវុធវាយផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត សង្គ្រោះអាយុជីវិតប្រជាជនកម្ពុជាប្រមាណ៥លាននាក់។













ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំវេទិកាថ្នាក់រៀនស្តីអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដំណើរទស្សនកិច្ចសិក្សាទៅកាន់តំបន់ប្រវត្តិសាស្ត្រយោធាកោះថ្ម អ៊ិច-១៦ ដល់សិស្សវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន មេមត់ និងវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ដារ ចំនួន៥០នាក់ នៅព្រឹកថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ស្ពឺ

## ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

*សាង ចាន់ធូ*



នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្តោតលើប្រធានបទ៖ «ការចងចាំជនរងគ្រោះស្លាប់ក្នុងរបបខ្មែរក្រហម និងបទពិសោធន៍មិនអាចបំភ្លេចបានរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន៥៥នាក់មកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ស្ពឺ ក្នុងស្រុកចំការលើ។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្តោតលើប្រធានបទ៖ «ការចងចាំជនរងគ្រោះស្លាប់ក្នុងរបបខ្មែរក្រហម និងបទពិសោធន៍មិនអាចបំភ្លេចបានរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន៥៥នាក់មកពីវិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ស្ពឺ ក្នុងស្រុកចំការលើ។ វេទិកាថ្នាក់រៀន ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់ចំណេះដឹងដល់សិស្សានុសិស្សអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងស្តាប់អំពីរឿងរ៉ាវនៃការបាត់បង់សាច់ញាតិជាទីស្រឡាញ់ក្នុងរបបខ្មែរក្រហម ព្រមទាំងបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។



ជាកិច្ចចាប់ផ្តើម លោក ស៊ាង ចិន្តា នាយកមជ្ឈ-មណ្ឌលឯកសារខេត្តកំពង់ចាម បានលើកឡើងអំពីព្រឹត្តិការណ៍នៅថ្ងៃទី២០ ខែឧសភា ដែលជាខែនៃ«ទិវាចងចាំ» ជនរងគ្រោះស្លាប់ក្នុងរបបខ្មែរក្រហម ដែលត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំដើម្បីរំឭកដល់អ្នកដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម។ ជាកិច្ចបន្តលោក ស៊ាង ចិន្តា ចាប់ផ្តើមធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលបានផ្តោតសំខាន់ទៅលើព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររួមមាន៖ រដ្ឋប្រហាររបស់ លន់ នល់ នៅឆ្នាំ១៩៧០, ការផ្ទុះឡើងនូវសង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម, ការឡើងកាន់អំណាចរបស់ខ្មែរក្រហម និងការកាប់សម្លាប់ទៅលើប្រជាជន។ បន្ថែមលើនេះ លោក ស៊ាង ចិន្តា បានចាក់បញ្ចាំងវីដេអូអំពីការជម្លៀសប្រជាជនដោយបង្ខំ និងការធ្វើការងារហួសកម្លាំងនៅតាមការដ្ឋានទំនប់។ ជាចុងបញ្ចប់នៃបទបង្ហាញ លោក ស៊ាង ចិន្តា លើកឡើងអំពីនិយមន័យ និងវិធីសាស្ត្រទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និងប្រល័យពូជសាសន៍។

បន្ទាប់ពីបទបង្ហាញបានបញ្ចប់ លោក ស៊ាង ចិន្តា ដឹកនាំសិស្សានុសិស្សពិភាក្សាទៅលើប្រធានបទ៖



នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្តោតលើប្រធានបទ៖ «ការចងចាំជនរងគ្រោះស្លាប់ក្នុងរបបខ្មែរក្រហម និងបទពិសោធន៍មិនអាចបំភ្លេចបានរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន៥៥នាក់មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ស្ទឹង ក្នុងស្រុកចំការលើ។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

«ការចងចាំជនរងគ្រោះស្លាប់ក្នុងរបបខ្មែរក្រហម និងបទពិសោធន៍មិនអាចបំភ្លេចបានរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ដោយបានបែងចែកសិស្សានុ-សិស្សជា១០ក្រុមដើម្បីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹងដែលទទួលពីការរៀនសូត្រ។ ក្រុមនីមួយៗទទួលបានឯកសាររួមមាន៖ សៀវភៅប្រវត្តិសាស្ត្រកម្ពុជា

ប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បោះពុម្ពជាលើកទី២, ទស្សនាវដ្តីស្វែងរកការពិត, និងបទសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងខេត្តកំពង់ចាម។ ក្រុមនីមួយៗមានរយៈពេល២០នាទីដើម្បីឡើងធ្វើបទបង្ហាញអំពីជនរងគ្រោះដែលត្រូវបានខ្មែរក្រហមសម្លាប់ បទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងការយល់ដឹងរបស់ខ្លួនអំពីទុក្ខលំបាករបស់ប្រជាជន។

កម្មវិធីពេលរសៀល គឺការចុះទៅកាន់ចេតិយរំឭកសម្រាប់សហគមន៍ដែលស្ថិតនៅកណ្ដាលវាលស្រែក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម ខេត្តកំពង់ចាម។ តុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាតំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានភូមិចំការសាមសិបជួបសិស្សានុសិស្ស និងចែករំលែកព័ត៌មានអំពីទីតាំងសម្លាប់ប្រជាជននៅក្នុងឃុំគគរក្នុងរបបខ្មែរក្រហម, បទពិសោធន៍ និងការបាត់បង់ឪពុកក្នុងរបបខ្មែរក្រហម។ កិច្ចសន្ទនាអន្តរជំនាន់រវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយ គឺជាផ្នែកដ៏សំខាន់មួយដើម្បីឲ្យយុវជន-យុវនារីយល់អំពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ឡេន រចនា រៀនថ្នាក់ទី១២ នៃវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ បង្ហាញទស្សនយល់ឃើញបន្ទាប់ពីបានចូលរួមវេទិកាថ្នាក់រៀនថា «ខ្ញុំពេញចិត្តចំពោះការចំណាយពេលវេលាចុងសប្ដាហ៍ដើម្បីចូលរួមវេទិកាថ្នាក់រៀននេះ។ ខ្ញុំទទួលបានចំណេះដឹងថ្មីពីរបបខ្មែរក្រហម និងដឹងបន្ថែមអំពីការរស់នៅរបស់ប្រជាជនខ្មែរក្នុងរបបខ្មែរក្រហមតាមរយៈបទបង្ហាញរបស់លោកគ្រូ ការស្ដាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងការឃើញជាក់ស្ដែងទីតាំងដែលមានការកាប់សម្លាប់ប្រជាជននាពេលនោះ។ ខ្ញុំពិតជាអាណិតអាសូរដល់ប្រជាជនខ្មែរដែលស្លាប់ទាំងនោះ»។

និត សុខនាថ រៀនថ្នាក់ទី១២នៃវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ លើកឡើងថា «ខ្ញុំយល់កាន់តែច្រើនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ក្នុងរបបខ្មែរក្រហមប្រជាជនទទួលរងទុក្ខវេទនា និងការកាប់សម្លាប់។ បទបង្ហាញរបស់លោកគ្រូបានផ្ដល់ចំណេះដឹងថ្មីៗទាក់ទងនឹងរបបខ្មែរក្រហម។ ការចុះទៅកាន់ទីតាំងសម្លាប់ និងជួបជាមួយអ្នករស់រានមានជីវិតគឺពិតជាមានសារសំខាន់ណាស់ដើម្បីបន្ថែមលើមេរៀនដែលខ្ញុំរៀនក្នុងថ្នាក់។ ការចងចាំពីការបាត់បង់ សាច់ញាតិនៅក្នុងរបបខ្មែរក្រហម និងការស្ដាប់រឿងរ៉ាវរបស់អ្នករស់រានមានជីវិត គឺពិតជាសំខាន់សម្រាប់ខ្ញុំដែលជាយុវជនជំនាន់ក្រោយ»។

អ៊ិន ស៊ីនាថ រៀនថ្នាក់ទី១២នៃវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ ចែករំលែកអ្វីដែលខ្លួនទទួលបានថា «ខ្ញុំពេញចិត្តចំពោះវេទិកាថ្នាក់រៀននេះ ពីព្រោះខ្ញុំទទួលបានចំណេះដឹងបន្ថែមពីប្រវត្តិសាស្ត្រខ្មែរក្រហម។ ខ្ញុំទើបតែដឹងអំពីសារសំខាន់នៃការចងចាំអ្នកដែលបានស្លាប់ក្នុងរបបខ្មែរក្រហម»។



នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំវេទិកាថ្នាក់រៀនចុងសប្ដាហ៍ស្ដីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្ដោតលើប្រធានបទ៖ «ការចងចាំជនរងគ្រោះស្លាប់ក្នុងរបបខ្មែរក្រហម និងបទពិសោធន៍មិនអាចបំភ្លេចបានរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន៥៥នាក់មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ស្ពឺ ក្នុងស្រុកចំការលើ។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)









នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានរៀបចំវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពីប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្តោតលើប្រធានបទ៖ «ការចងចាំជនរងគ្រោះស្លាប់ក្នុងរបបខ្មែរក្រហម និងបទពិសោធន៍មិនអាចបំភ្លេចបានរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន៥៥នាក់មកពីវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុន សែន ស្ដី ក្នុងស្រុកចំការលើ។ (លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សិស្សវិទ្យាល័យសម្តេច ហ៊ុន សែន សង្កើប

## ចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជា ប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)

***ទូច វណ្ណាក និង លី ដេវីត***




*នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្តោតទៅលើប្រធានបទ៖ «ការចងចាំជនរងគ្រោះស្លាប់ក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន ៦៦នាក់ មកពីវិទ្យាល័យ សម្តេច ហ៊ុន សែន សង្កើប ស្ថិតនៅស្រុកបាធាយ។*
*(លី ដេវីត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្តោតទៅលើប្រធានបទ៖ «ការចងចាំជនរងគ្រោះស្លាប់ក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន ៦៦នាក់ មកពីវិទ្យាល័យ សម្តេច ហ៊ុន សែន សង្កើប ស្ថិតនៅស្រុកបាធាយ។

លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ទទួលស្វាគមន៍និងរំឭកទៅកាន់សិស្សានុសិស្សចូលរួមអំពីខែឧសភា ដែលជាខែនៃការចងចាំជនរងគ្រោះស្លាប់ក្នុងរបបខ្មែរក្រហមថា «ថ្ងៃទី២០ ខែឧសភា គឺជាទិវានៃការចងចាំដែលត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំដើម្បីរំឭកដល់អ្នកដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម»។ លោក ស៊ាង ចិន្តា ចាប់ផ្តើមបទបង្ហាញរបស់ខ្លួនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដែលបានផ្តោតសំខាន់ទៅលើព្រឹត្តិការណ៍

ប្រវត្តិសាស្ត្ររួមមាន រដ្ឋប្រហារ លន់ នល់ នៅឆ្នាំ១៩៧០, ការផ្ទុះឡើងនូវសង្គ្រាមរវាងទាហានលន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម, ការឡើងកាន់អំណាចរបស់ខ្មែរក្រហម, និងការកាប់សម្លាប់ទៅលើប្រជាជន។ បន្ថែមលើនេះទៀត លោក ស៊ាង ចិន្តា បានចាក់បញ្ចាំងវីដេអូពីការជម្លៀសប្រជាជនដោយបង្ខំ និងការធ្វើការងារហួសកម្លាំងនៅតាមការដ្ឋានទំនប់។ ជាចុងបញ្ចប់បទបង្ហាញ លោក ស៊ាង ចិន្តា លើកឡើងអំពីនិយមន័យ និងវិធីសាស្ត្រទប់ស្កាត់ឧក្រិដ្ឋកម្មឃោរឃៅ និង អំពើប្រល័យពូជសាសន៍។

បន្ទាប់ពីបទបង្ហាញបានបញ្ចប់ សិស្សានុសិស្សត្រូវបានដឹកនាំពិភាក្សាទៅលើប្រធានបទ «ការចងចាំជនរងគ្រោះស្លាប់ក្នុងរបបខ្មែរក្រហម» និងបែងចែកសិស្សានុសិស្សចូលរួមទាំងអស់ជាក្រុមដើម្បីពិភាក្សា និងផ្លាស់ប្តូរចំណេះដឹងដែលទទួលបានទាក់ទងប្រធានខាងលើ។ ក្រុមនីមួយៗទទួលបានឯកសាររួមមាន សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) បោះពុម្ពលើកទី២, ទស្សនាវដ្តីស្វែងរកការពិត, និងបទសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងខេត្តកំពង់ចាម ដោយមានរយៈពេល១៥នាទីដើម្បីរៀបចំ



នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្តោតទៅលើប្រធានបទ៖ «ការចងចាំជនរងគ្រោះស្លាប់ក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន៦៦នាក់ មកពីវិទ្យាល័យ សម្តេច ហ៊ុន សែន សង្កើប ស្ថិតនៅស្រុកបាធាយ។
( លី ដេវីត/ មជ្ឈមណ្ឌលឯកសារកម្ពុជា )

បទបង្ហាញរបស់ខ្លួន។ ក្រុមនីមួយៗបានឡើងចែករំលែកអំពីជនរងគ្រោះដែលត្រូវបាន សម្លាប់និងការយល់ឃើញរបស់ខ្លួនអំពីទុក្ខលំបាកប្រជាជនក្នុងពេលនោះដូចខាងក្រោម៖

- **ក្រុមទី១** សរសេរសេចក្តីសង្ខេបអំពីការពិភាក្សា និងការយល់ឃើញរបស់ខ្លួនទាក់ទងប្រធានបទ «ការចងចាំជនរងគ្រោះស្លាប់ក្នុងរបបខ្មែរក្រហម» ថា «ក្នុងរបបខ្មែរក្រហម ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ខ្មែរក្រហមដឹកនាំប្រទេសជាតិធ្លាក់ចូលវិនាសកម្ម និងសោកនាដកម្មដែលធ្វើឲ្យប្រជាជនកម្ពុជាជិត២លាននាក់ស្លាប់បាត់បង់ជីវិត។ របបខ្មែរក្រហមមិនត្រឹមតែបន្សល់ទុកនូវការស្លាប់ប្រជាជនរាប់លាននាក់នោះទេ ប៉ុន្តែក៏បន្សល់ទុកក្មេងកំព្រាជាច្រើននាក់។ អ្នករួចផុតពីសេចក្តីស្លាប់នៅពេលនោះទទួលរងការចងចាំដ៏ឈឺចាប់ និងបទពិសោធន៍មិនអាចបំភ្លេចបាន ព្រមទាំងទុក្ខលំបាក និងការបាត់បង់សមាជិកគ្រួសារ។ ការចងចាំរបបខ្មែរក្រហមគឺមានសារសំខាន់ណាស់សម្រាប់យុវជនជំនាន់ក្រោយដើម្បីរៀនសូត្រពីមេរៀនប្រវត្តិសាស្ត្រនេះ»។
- **ក្រុមទី២** សរសេរសេចក្តីសង្ខេបអំពីការពិភាក្សា និងការយល់ឃើញរបស់ខ្លួនទាក់ទងប្រធានបទ «ការចងចាំជនរងគ្រោះស្លាប់ក្នុងរបបខ្មែរក្រហម» ថា «វេទិកាថ្នាក់រៀននេះផ្តល់ចំណេះដឹងថ្មីៗ និងសារសំខាន់នៃការចងចាំជនរងគ្រោះក្នុងរបបខ្មែរក្រហមដល់យើងខ្ញុំ។ ក្នុងរបបខ្មែរក្រហម ប្រជាជនកម្ពុជារស់នៅក្នុងស្ថានភាពលំបាកធ្វើការគ្មានពេលសម្រាក ការហូបចុកមិនគ្រប់គ្រាន់ការធ្វើទារុណកម្ម និងការចាប់យកទៅសម្លាប់ចោល។ តាមរយៈបទបង្ហាញរបស់លោកគ្រូ និងបទសម្ភាសន៍ជាមួយអ៊ំស្រី ម៉ៅ វណ្ណា ដែលរួចផុតពីការកាប់សម្លាប់ និងការបាត់បង់ឪពុកម្តាយ ព្រមទាំងបងប្អូន៣នាក់ ដោយសារតែការសម្លាប់របស់ខ្មែរក្រហម, ការចងចាំជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហមគឺពិតជាមានសារសំខាន់ណាស់ដើម្បីបន្តចងចាំរឿងរ៉ាវប្រវត្តិសាស្ត្រកុំឲ្យរបបនេះកើតឡើងម្តងទៀត»។

- **ក្រុមទី៣** សរសេរសេចក្ដីសង្ខេបអំពីការពិភាក្សា និងការយល់ឃើញរបស់ខ្លួនទាក់ទងប្រធានបទ «ការចងចាំជនរងគ្រោះស្លាប់ក្នុងរបបខ្មែរក្រហម» ថា «យើងខ្ញុំយល់ថា ការចងចាំអ្នកដែលបានស្លាប់ក្នុងរបបខ្មែរក្រហមគឺជាការល្អសម្រាប់ក្មេងជំនាន់ក្រោយដែលកើតក្រោយរបបខ្មែរក្រហម។ ប្រសិនបើមិនមានការចងចាំនេះទេពេលវេលាអាចធ្វើឲ្យក្មេងៗដូចយើងខ្ញុំផ្ទាល់ មិនដឹងថាប្រជាជនខ្មែរពិតជាទទួលរងទុក្ខលំបាក និងការកាប់សម្លាប់ក្នុងរបបខ្មែរក្រហម។ យើងនឹងយកចំណេះដឹងដែលទទួលបាននៅពេលនេះទៅចែករំលែកទៅកាន់មិត្តភក្តិផ្សេងទៀតដែលមិនបានមក និងសួរយាយតានៅផ្ទះថាតើមានរឿងអ្វីកើតឡើងចំពោះគាត់ក្នុងរបបខ្មែរក្រហម»។



កម្មវិធីពេលរសៀល គឺការចុះទៅកាន់ចេតិយរំឭកសម្រាប់សហគមន៍ដែលស្ថិតនៅកណ្ដាលវាលស្រែក្នុងភូមិចំការសាមសិប ឃុំគគរ ស្រុកកំពង់សៀម។ បន្ទាប់ពីចុះទៅដល់ទីតាំងចេតិយរំឭកសម្រាប់សហគមន៍ តុង សុភា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាតំណាងសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក្នុងមូលដ្ឋានភូមិចំការសាមសិប ទទួលជួបស្វាគមន៍ និងដឹកនាំសិស្សានុសិស្សទៅកាន់ចេតិយរំឭក។ តុង សុភា និយាយចែករំលែកអំពីទីតាំងសម្លាប់ប្រជាជននៅក្នុងឃុំគគរក្នុងរបបខ្មែរក្រហម រួមមានទំនប់គគរ, វត្តគគរ, ឡដុតថ្នាំជក់, បទពិសោធន៍ និងការបាត់បង់ឪពុកក្នុងរបបខ្មែរក្រហម។ ការជួបសន្ទនារវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយគឺជាផ្នែកដ៏សំខាន់មួយ ដើម្បីឲ្យយុវជន-យុវនារីកើតក្រោយរបបខ្មែរក្រហម ឈ្វេងយល់ដោយផ្ទាល់អំពីបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

នៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ផ្ដោតទៅលើប្រធានបទ៖ «ការចងចាំជនរងគ្រោះស្លាប់ក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីសិស្សានុសិស្សចំនួន ៦៦នាក់ មកពីវិទ្យាល័យសម្ដេច ហ៊ុន សែន សង្កើប ស្ថិតនៅស្រុកបាធាយ។ (លី ដេវីត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



# វេទិកាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-៧៩) ចុងសប្តាហ៍នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

*ភា រស្មី និង ផុន ស្រីពេជ្រ*



សិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវ និង វិទ្យាល័យព្រះអង្គឌួង ចូលរួមវេទិកាថ្នាក់រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

យុវជនអាយុក្រោម១៩ឆ្នាំ មានឪពុកម្តាយមិនធ្លាប់ឆ្លងកាត់របបខ្មែរក្រហម ចំនួន៣២នាក់ ក្នុងនោះស្រី២៥នាក់ បានចូលរួមកម្មវិធីវេទិកាថ្នាក់រៀនចុងសប្តាហ៍ រៀបចំដោយមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៣។ យុវជនទាំងនោះគឺជាសិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវ និងវិទ្យាល័យព្រះអង្គឌួង ក្នុងខេត្តព្រៃវែង។ តាមរយៈការបំពេញតារាងស្ទាបស្ទង់មតិមុនពេលធ្វើវេទិកាថ្នាក់រៀនឃើញថា ក្នុងចំណោមសិស្សានុសិស្សទាំងអស់សុទ្ធតែធ្លាប់បានដឹងពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ ក្នុងនោះ ក្មេងៗចំនួន ១៩ នាក់ ស្មើនឹង៥៥.៩% លើកឡើងថា ខ្លួនបានដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការសិក្សាជាមួយលោកគ្រូអ្នកគ្រូនៅតាមសាលារៀន។ សិស្សានុសិស្សចំនួន១៤នាក់ ស្មើនឹង៤១.២% ផ្សេងទៀតប្រាប់ថា ខ្លួនធ្លាប់ដឹងពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការស្តាប់ជីដូនជីតា ដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ មានតែសិស្ស



សិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវ និង វិទ្យាល័យព្រះអង្គឌួង ចូលរួមវេទិកាថ្នាក់រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ម្នាក់គត់ ឬស្មើនឹង៣% នៃចំនួនសិស្សទាំងអស់ឆ្លើយថា ខ្លួនបានដឹងប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការអានសៀវភៅ និងតាមដានប្រព័ន្ធផ្សព្វផ្សាយ ហ្វេសប៊ុក ទស្សនាវដ្តី កាសែត ទូរទស្សន៍ វិទ្យុ គេហទំព័រនានា និងយូធូប។ ចំពោះការយល់ដឹងអំពីនិយមន័យនៃអំពើប្រល័យពូជសាសន៍ យើងសង្កេតឃើញថា សិស្សានុសិស្សបានបង្ហាញពីចម្លើយខុសៗគ្នាតាមការយល់ឃើញរបស់ខ្លួន។ ក្នុងនោះសិស្សច្រើនជាង៦០% ឆ្លើយថា អំពើប្រល័យពូជសាសន៍គឺជា «អំពើទាំងឡាយណាដែលប្រព្រឹត្តឡើងក្នុងគោលបំណងបំផ្លិចបំផ្លាញចោលទាំងស្រុង ឬដោយផ្នែកចំពោះក្រុមជនជាតិ ជាតិពន្ធុ ពូជសាសន៍ ឬក្រុមសាសនា»។ សិស្សានុសិស្សទាំងអស់ត្រូវវាស់ស្ទង់ចំណេះដឹងមុន និង ក្រោយពេលធ្វើវេទិកាថ្នាក់រៀនថា តើអ្នកទាំងនោះយល់ដឹងអ្វីខ្លះពីវិធីសាស្ត្រទប់ស្កាត់អំពើប្រល័យពូជសាសន៍។



**សំរ៉ាំង ស្រីណែត** ភេទស្រី អាយុ១៦ឆ្នាំរៀបរាប់ថា ខ្ញុំគឺជាសិស្សថ្នាក់ទី១២B នៅវិទ្យាល័យ ហ៊ុន សែន កំពង់លាវ។ សព្វថ្ងៃ ខ្ញុំរស់នៅភូមិជើងទឹក សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង។ មុនពេលចូលរួមក្នុងវេទិកាថ្នាក់រៀន ខ្ញុំធ្លាប់រៀនក្រៅម៉ោងបន្ថែមអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យជាមួយលោកគ្រូនៅសាលារៀន។ ឪពុកម្តាយរបស់ខ្ញុំមិនដែលនិយាយអ្វីប្រាប់ខ្ញុំនោះទេ ដោយសារពេលរបបខ្មែរក្រហមគាត់នៅក្មេង។ លោកយាយលោកតារបស់ខ្ញុំស្លាប់អស់ហើយ។ ពេលរៀនជាមួយលោកគ្រូរួច ទើបខ្ញុំបានដឹងថា ប្រជាជននៅក្នុងសម័យខ្មែរក្រហមរស់នៅក្រោមការគាបសង្កត់របស់កម្មាភិបាលខ្មែរក្រហម ប្រជាជនរស់នៅរួមគ្នា ហូបចុករួមគ្នា និងមិនមានអ្នកមាន អ្នកក្រ។ ប្រជាជនក្នុងសម័យនោះធ្វើការលើសពី១២ម៉ោង ហើយហូបអាហារបានបន្តិចបន្តួច។ ប៉ុន្តែពេលខ្ញុំចូលរៀនជាមួយលោកគ្រូថ្ងៃនេះមក ខ្ញុំយល់ដឹងបន្ថែមទៀតទាក់ទងការរស់នៅរបស់ប្រជាជន ការសម្លាប់ប្រជាជន ហើយខ្ញុំពិតជាមិនចង់ឲ្យរបបមួយនេះកើតឡើងម្តងទៀតនោះទេ។ ដើម្បីទប់ស្កាត់អំពើប្រល័យពូជសាសន៍កុំឲ្យកើតឡើងម្តងទៀត ខ្ញុំយល់ថាយើងមិនត្រូវប្រើអំពើហិង្សា មិនត្រូវរើសអើងវណ្ណៈ ឬក៏ពណ៌

សម្បុរ និងការពារតាមរយៈការអប់រំ វប្បធម៌ សាសនា នៅក្នុងសហគមន៍។



**ឆុន សុភ័ក្ត្រ** ភេទស្រី អាយុ ១៦ឆ្នាំរៀបរាប់ថា ខ្ញុំគឺជាសិស្សថ្នាក់ទី១២B នៃវិទ្យាល័យសម្តេចតេជោ ហ៊ុន សែន កំពង់លាវ។ សព្វថ្ងៃ ខ្ញុំរស់នៅភូមិលេខ៨ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង។ មុនពេលចូលរួមក្នុងវេទិកាថ្នាក់រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ខ្ញុំធ្លាប់ដឹងរឿងរ៉ាវសម័យខ្មែរក្រហមតាមរយៈ លោកយាយ លោកតា និយាយប្រាប់ តាមរយៈគ្រូបង្រៀននៅសាលា និងចុះកម្មសិក្សាទៅមើលទីកន្លែងផ្ទាល់នៅគុកទួលស្លែងជាដើម។ លោកយាយលោកតា របស់ខ្ញុំនិយាយថា សម័យនោះលំបាកណាស់ រស់នៅដោយភាពភ័យខ្លាច ព្រោះត្រូវរត់គេចពីគ្រាប់បែក គ្រាប់ផ្លោង ហើយក្រុមគ្រួសារក៏មិនអាចរស់នៅជុំគ្នាបាន និងមិនមានអាហារគ្រប់គ្រាន់។ ពេលខ្ញុំស្តាប់លោកយាយដំបូងខ្ញុំមិនសូវជឿប៉ុន្មានទេ ប៉ុន្តែពេលបានរៀនជាមួយលោកគ្រូបន្ថែមទៀតទើបខ្ញុំយល់កាន់តែច្បាស់។ ការសិក្សានៅសាលារៀនធ្វើឲ្យខ្ញុំបានដឹងអំពីការរស់នៅរបស់ប្រជាជន ការដឹកនាំរបស់កម្មាភិបាលខ្មែរក្រហម ការកាប់សម្លាប់ប្រជាជនមានចំណេះដឹង និងយកអ្នកល្ងង់មកដឹកនាំប្រទេស។ ចំពោះវេទិកាថ្នាក់រៀនថ្ងៃនេះ ខ្ញុំពិតជាមានអារម្មណ៍ថាតក់ស្លុតខ្លាំងណាស់ ព្រោះលោកគ្រូបង្រៀននៅថ្ងៃនេះគឺដូចអ្វីដែល ខ្ញុំធ្លាប់ឃើញពីទីកន្លែងសម្លាប់ប្រជាជនខ្មែរ ការបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរបស់ខ្មែរដែលបន្សល់ពីសម័យខ្មែរក្រហម។ នៅក្នុងវេទិកាថ្នាក់រៀនព្រឹកនេះ មានចំណុចមួយដែលខ្ញុំចាប់អារម្មណ៍ខ្លាំងជាងគេ នៅពេលលោកគ្រូខទ្ទេសធ្វើបទបង្ហាញគឺ ខ្មែរក្រហមបានបង្កើតឲ្យមានអំពើប្រល័យពូជសាសន៍ទៅលើជនជាតិចាម និងសាសនាដទៃ។ ខ្ញុំដឹងថាខ្មែរក្រហមសម្លាប់ជនជាតិខ្មែរ ប៉ុន្តែមិនដឹងថា ខ្មែរក្រហមសម្លាប់ជនជាតិផ្សេងទៀតនោះទេ ជាពិសេសជនជាតិចាម។ ខ្ញុំពិតជាមិនចង់ឲ្យរបបនេះកើតឡើងម្តងទៀតនោះទេ។ ដូចនេះ ខ្ញុំយល់ថាដើម្បីការពារកុំឲ្យរបបនោះត្រឡប់មកវិញ យើងគួរតែមានការអប់រំទូន្មាន ដោះស្រាយបញ្ហាដោយសន្តិវិធី និងប្រឆាំងអំពើប្រល័យពូជសាសន៍តាមរយៈការមិនរើសអើងពូជសាសន៍ដទៃ។



**ទីន វេជទិជ** ភេទប្រុស អាយុ ១៧ឆ្នាំ គឺជាសិស្សរៀននៅវិទ្យាល័យព្រះអង្គឌួង ថ្នាក់ទី១២H រៀបរាប់ថា ចំពោះចំណាប់អារម្មណ៍ខ្ញុំនៅក្នុងថ្ងៃនេះ ខ្ញុំគិតថាល្អសម្រាប់ខ្ញុំ ព្រោះខ្ញុំបានដឹងបន្ថែមពីការចែករំលែករបស់លោកគ្រូ។ ខ្ញុំធ្លាប់បានស្រាវជ្រាវពីប្រវត្តិសាស្ត្រខ្មែរក្រហមដែរ ប៉ុន្តែខ្ញុំនៅពុំទាន់ច្បាស់ពីរបបនេះទេ នៅពេលខ្ញុំបានចូលរួមក្នុងវេទិកាព្រឹកនេះ ធ្វើឲ្យខ្ញុំចេះច្បាស់ជាងមុននូវមេរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ ថ្វីត្បិតតែនៅសាលារៀនមិនទាន់បង្រៀនដល់មេរៀននេះមែន ប៉ុន្តែខ្ញុំមានចំណេះដឹងមុនខ្លះ។ កាលពីក្មេង ខ្ញុំធ្លាប់មើលរឿងខ្មែរក្រហមតាមទូរទស្សន៍ និងមានលោកតាលោកយាយនៅផ្ទះនិយាយរឿងរ៉ាវរបស់គាត់ឲ្យខ្ញុំស្តាប់ ។ គាត់បានបន្ថែមថា មានម្តងនោះលោកតាលោកយាយ ខ្ញុំធ្វើខុស តែខ្ញុំមិនច្បាស់ថាពួកគាត់ធ្វើខុសរឿងអ្វីទេ អង្គការបានយកគាត់ទៅសួរចម្លើយ និងយកទៅកសាង ប៉ុន្តែជាសំណាងល្អ គាត់នៅមានជីវិតមកដល់សព្វថ្ងៃ។ ចំពោះកម្មវិធីវេទិកាថ្នាក់រៀន ខ្ញុំយល់ដឹងពីរបៀបគ្រប់គ្រងរបស់ខ្មែរក្រហម ដែលខុសប្លែកពីអ្នកគ្រប់គ្រងរបបមុនៗ ក្នុងប្រវត្តិសាស្ត្រកម្ពុជា។ ការគ្រប់គ្រងរបស់ខ្មែរក្រហម មានការសម្លាប់មនុស្ស និងជម្លៀសប្រជាជនចេញពីទីប្រជុំជនទៅទីជនបទ ព្រមទាំងធ្វើឲ្យគ្រួសារមួយចំនួនត្រូវបែកបាក់គ្នា។ អ្វីដែលគួរឲ្យសោកស្តាយបំផុត គឺខ្មែរក្រហមបានយកអ្នកដែលមានចំណេះដឹងជាច្រើនទៅសម្លាប់ចោល ធ្វើឲ្យប្រទេសជាតិបាត់បង់ធនធាន

មនុស្ស និងសោកស្តាយដែលប្រទេសកម្ពុជាបានធ្លាក់ទៅក្នុងរបបឃោរឃៅមួយនេះ។



**គន ស្រីទូច** ភេទស្រី អាយុ ១៧ឆ្នាំ គឺជាសិស្សមកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវថ្នាក់ទី១២C រៀបរាប់ថា ខ្ញុំបានដឹងរឿងរ៉ាវពីរបបខ្មែរក្រហមតិចតួច។ កាលដែលខ្ញុំបានចូលរួមនៅក្នុងវេទិកានេះ ខ្ញុំមានអារម្មណ៍ថាសប្បាយចិត្ត និងយល់ថាកម្មវិធីនេះល្អសម្រាប់ខ្ញុំ ព្រោះនឹងមានសារសំខាន់ចំពោះការប្រឡងរបស់ខ្ញុំនៅថ្ងៃខាងមុខ។ មួយវិញទៀត ការចូលរួមវេទិកាថ្នាក់រៀននេះគឺបន្ថែមចំណេះដឹងពីលើមេរៀនដែលលោកគ្រូបានបង្រៀននៅសាលា។ ខ្ញុំឈឺចាប់ខ្លួនណាស់ពីទុក្ខលំបាករបស់ប្រជាជននាសម័យនោះ ទោះបីជាខ្ញុំកើតមិនទាន់។ ចំពោះមេរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលខ្ញុំចង់ចាំជាងគេ គឺក្រោយរបបខ្មែរក្រហមដួលរលំ បានបន្សល់ទុកនូវស្ត្រីមេម៉ាយ ក្មេងកំព្រា ជនពិការ និងគ្រាប់មីនរាយពេញផ្ទៃប្រទេស។ ខ្ញុំជឿថារបបនេះពិតជាកើតមានមែននៅក្នុងប្រទេសកម្ពុជា ព្រោះមានភស្តុតាងដែលបានសរសេរនៅក្នុងសៀវភៅ និងសំអាងទៅលើការស្តាប់បទពិសោធន៍ពិតរបស់លោកតាលោកយាយ និងឪពុកម្តាយរបស់ខ្ញុំ។ ជាចុងក្រោយ ខ្ញុំនឹងខិតខំប្រឹងប្រែងរៀនសូត្រឲ្យមានចំណេះដឹងខ្ពង់ខ្ពស់ បញ្ឈប់ការរើសអើងជាតិសាសន៍ និងសូមសំណូមពរឲ្យប្រជាជនជួយរក្សាប្រទេសជាតិឲ្យមានសុខសន្តិភាព និងព្យាយាមទប់ស្កាត់មិនឲ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញសារជាថ្មីម្តងទៀត។



សិស្សានុសិស្សមកពីវិទ្យាល័យ ហ៊ុន សែន កំពង់លាវ និង វិទ្យាល័យព្រះអង្គឌួង ចូលរួមវេទិកាថ្នាក់រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅអន្លង់វែង

**ឈួន សុគង់**





សិស្សានុសិស្សមកពីវិទ្យាល័យតេជោសែន សំរោងចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពី«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សិស្សានុសិស្សវិទ្យាល័យតេជោសែនសំរោងចំនួន៣៨នាក់ ក្នុងនោះមានស្រីចំនួន២៦នាក់ និងប្រុសចំនួន៨នាក់ បានមកចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣។ វេទិកាថ្នាក់រៀននេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់ការយល់ដឹងដល់យុវជនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដែលជាផ្នែកមួយដ៏សំខាន់ដើម្បីការចងចាំ ការថែរក្សាសន្តិភាព និងការផ្សះផ្សា។ ការធ្វើបទបង្ហាញនិងការពិភាក្សាបានផ្តោតសំខាន់លើប្រធានបទនៃការបង្កើតក្រុមប្រវាស់ដៃ ក្រោយមកសហករណ៍រួម ការរៀបការដោយបង្ខំ ពលកម្មកុមារ និងបន្សុទ្ធកម្មជាដើម។ ដោយសារតែយុវនារីមានចំនួនច្រើនលើសលុប ចំណាប់អារម្មណ៍លើការរៀបការដោយបង្ខំ ដែលអង្គការខ្មែរក្រហមបានរៀបចំដោយមិនអាចប្រកែកបានឡើយ។ នៅក្នុងរបបខ្មែរក្រហមនោះ បើស្ត្រីណាម្នាក់ហ៊ានប្រកែកអ្នកទាំងនោះប្រាកដជារងទារុណកម្ម ឬសម្លាប់។ ហេតុការណ៍នេះបណ្តាលឲ្យយុវនារីនៅក្នុងវេទិកាថ្នាក់រៀនសម្តែងនូវអារម្មណ៍ផ្ទាល់ខ្លួន ដែលថាការបង្ខិតបង្ខំរបស់របបខ្មែរក្រហមគឺជាអំពើបំពារបំពាន

យ៉ាងធ្ងន់ធ្ងរលើសិទ្ធិសេរីភាពរបស់ប្រជាជន។ នៅក្នុងរបបខ្មែរក្រហម ការរៀបចំពិធីមង្គលការ (បុរពិធីបើកវគ្គ) ខុសពីទំនៀមទម្លាប់ប្រពៃណីខ្មែរទាំងស្រុង។ ការរៀបចំពិធីមង្គលការមួយតម្រូវឲ្យមានកូនកម្លោះកូនក្រមុំចំនួនពី៣ទៅ១០គូសម្រាប់ពិធីតូច ចំណែកពិធីធំចាប់ពី៣០គូទៅ៥០គូ ឬអាចមានរហូតដល់ទៅ១០០គូ។ អ្នកទាំងអស់នេះពុំមានសិទ្ធិជ្រើសរើសគូស្រករដោយខ្លួនឯងទេ គឺត្រូវគោរពតាមអង្គការរៀបចំឲ្យតែប៉ុណ្ណោះ។ ខាងក្រោមគឺជាការយល់ឃើញរបស់សិស្សានុសិស្សដែលបានចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍៖

ខ្ញុំឈ្មោះ ភួង ភាស់ ភេទប្រុស អាយុ១៩ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ វិទ្យាល័យតេជោសែនសំរោង។ បន្ទាប់ពីខ្ញុំបានចូលរួមក្នុងវេទិកាថ្នាក់រៀនចុងសប្តាហ៍រួចបានធ្វើឲ្យខ្ញុំយល់ដឹងបានច្រើនពីរបបខ្មែរក្រហម។ ខ្មែរក្រហមបានបង្ខំប្រជាជនឲ្យចូលជាសហករណ៍ បង្ខំកុមារឲ្យធ្វើការហួសកម្លាំង បង្ខំឲ្យប្រជាជនរៀបការដើម្បីបង្កើតកូនបន្តការងារបដិវត្តន៍។ ខ្ញុំក៏បានទៅទស្សនាសារមន្ទីរផ្ទះ តាម៉ុក ស្របពេលដែលមជ្ឈ-មណ្ឌលសន្តិភាពអន្លង់វែងសហការជាមួយរដ្ឋបាលស្រុកអន្លង់វែងកំពុងចាក់បញ្ចាំងការផ្សាយបន្តផ្ទាល់ការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ដែលធ្វើឲ្យខ្ញុំមានអារម្មណ៍សប្បាយរីករាយព្រោះប្រទេសយើងបានធ្វើជាម្ចាស់ផ្ទះ ហើយក៏មានមោទកភាពចំពោះប្រទេសកម្ពុជាដែរ។

ខ្ញុំឈ្មោះ ដួង ចាន់ ភេទស្រី អាយុ២០ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យតេជោសែនសំរោង បាននិយាយថា ក្រៅពីការយល់ដឹងអំពីការបង្កើតសហករណ៍ នៅសម័យខ្មែរក្រហមមានការរំលោភសិទ្ធិមនុស្សតាមរយៈការរៀបការដោយបង្ខំ។ ក្រោយពីបានចូលរួមវេទិកាថ្នាក់រៀនស្តីអំពីការអប់រំប្រវត្តិសាស្ត្រខ្មែរក្រហម ខ្ញុំក៏បានយល់ដឹងអំពីការប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ដែរ។ ប្រទេសកម្ពុជាបានធ្វើជាម្ចាស់ផ្ទះ ហើយមកដល់ពេលនេះប្រទេសកម្ពុជាមានឱកាសឈ្នះមេដាយ និងបានផ្សព្វផ្សាយអំពីការរីកចម្រើនរបស់ប្រទេសកម្ពុជា។

ខ្ញុំឈ្មោះ ហៀប វ៉ាឆាន់ ភេទប្រុស អាយុ២០ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ វិទ្យាល័យតេជោសែនសំរោង បាននិយាយថា បន្ទាប់ពីបានចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង បានធ្វើឲ្យខ្ញុំយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហមច្រើនជាងមុន ខ្ញុំយល់ដឹងពីការបង្កើតសហករណ៍ដើម្បីឲ្យប្រជាជនរស់នៅរួមគ្នា ធ្វើការងារជាមួយគ្នា ហូបជាមួយគ្នា និងចែករំលែកការកម្សាន្តជាសមូហភាព ព្រមទាំងបានដឹងអំពីការបង្ខំប្រជាជនឲ្យរៀបការ និងការរំលោភសិទ្ធិកុមារ។






សិស្សានុសិស្សមកពីវិទ្យាល័យតេជោសែនសំរោងចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពី«ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង កាលពីថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាអប់រំស្តីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅសហគមន៍ជនជាតិដើមភាគតិចស្ទៀង

ឡុង ដានី







នៅព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅសហគមន៍ជនជាតិដើមភាគតិចស្ទៀងភូមិបុស្សតាអឹម ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដោយមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនជាតិដើមភាគតិចស្ទៀង និងកូនចៅជំនាន់ក្រោយចូលរួមចំនួន ៤០ នាក់ (ស្រី២៨នាក់)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាអប់រំសហគមន៍ ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅសហគមន៍ជនជាតិដើមភាគតិចស្ទៀង ស្ថិតនៅភូមិបុស្សតាអឹម ឃុំដាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដោយមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមគឺជាជនជាតិដើមភាគតិចស្ទៀង និងកូនចៅជំនាន់ក្រោយចូលរួមចំនួន៤០នាក់។

ជាកិច្ចចាប់ផ្តើមលោកមេភូមិ កង យឺន បានរៀបរាប់ថា ចាស់ៗដែលរស់នៅក្នុងភូមិបុស្សតាអឹមបានដំណាលតៗមកថា កាលពីដើមឡើយមានក្រុមគ្រួសារជនជាតិដើមភាគតិចស្ទៀងមួយគ្រួសារ

មានកូនប្រុសបីនាក់ឈ្មោះថា អឹម,ពេជ្រ និង ម៉ៅ។ នៅពេលកូនប្រុសទាំងបីនាក់នៃគ្រួសារនេះធំដឹងក្ដីឡើងបានរៀបការនិងមានប្រពន្ធកូនរៀងៗខ្លួន។ កូនប្រុសៗទាំងបីនាក់បាននាំប្រពន្ធកូនទៅធ្វើស្រែចម្ការនៅកន្លែងផ្សេងៗពីគ្នា ប៉ុន្តែនៅមិនឆ្ងាយពីគ្នាប៉ុន្មានឡើយ។ ក្រុមគ្រួសារ ពេជ្របានទៅកាប់ឆ្ការព្រៃបុស្សធ្វើស្រែចម្ការ និងរស់នៅ បន្ទាប់មកទីកន្លែងនោះត្រូវបានហៅថាភូមិស្រែ តាពេជ្រ។ គ្រួសារ ម៉ៅ បានទៅរស់នៅធ្វើស្រែចម្ការនៅ ទីតាំងមួយបច្ចុប្បន្នប្រជាជនបានដាក់ឈ្មោះថា ភូមិជាំតាម៉ៅ ។ ចំណែកក្រុមគ្រួសារឈ្មោះ អឹម បានកាប់ឆ្ការព្រៃបុស្សធ្វើស្រែចម្ការនិងរស់នៅ ទីតាំងភូមិបុស្សតាអឹម សព្វថ្ងៃនេះ។ តាអឹម និងក្រុមគ្រួសារមានសន្ដានចិត្តល្អ និងជួយដល់ប្រជាជនជាច្រើននៅក្នុងភូមិ។ អំពើល្អនេះបានធ្វើឲ្យអ្នកភូមិស្រ ឡាញ់ចូលចិត្តនិងកោតសរសើរ តាអឹម។ នៅពេលតាអឹម ចាស់ជរាស្លាប់ទៅអ្នកភូមិបាននាំគ្នាហៅឈ្មោះភូមិនេះថា ភូមិបុស្សតាអឹម រហូតមកដល់សព្វថ្ងៃនេះ ដើម្បីជាការរំឭកនឹកដល់ តាអឹម ដែលបានកាប់ឆ្ការព្រៃបុស្សនៅក្នុងភូមិនេះមុនគេ និងសេចក្ដីល្អដែល តាអឹមបានធ្វើចំពោះអ្នកភូមិកាលពីពេលនោះ។ បច្ចុប្បន្នភូមិបុស្សតាអឹម មានប្រជាពលរដ្ឋរស់នៅចំនួន២៨៥គ្រួសារ សរុបចំនួន១០៦២នាក់ ស្រីមានចំនួន ៥៤៩ នាក់ ក្នុងនោះចាប់ពីអាយុ១៨ឆ្នាំឡើងមានចំនួន ៧០៥នាក់ ស្រីមានចំនួន ៣៥១នាក់ ។

បន្ទាប់មក លោក ឡុង ដានី នាយកមជ្ឈមណ្ឌលឯកសារកោះថ្ម មានប្រសាសន៍ថា នៅថ្ងៃទី២០ ខែឧសភា ខាងមុខនេះគឺជាទិវាជាតិនៃការចងចាំអំពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ជារៀងរាល់ឆ្នាំអាជ្ញាធរគ្រប់លំដាប់ថ្នាក់តែងតែដឹកនាំប្រារព្ធទិវាជាតិនៃការចងចាំ ២០ឧសភា ដើម្បីរំឭកដល់វិញ្ញាណក្ខន្ធជនរងគ្រោះដែលស្លាប់ និងការឈឺចាប់ពីឧក្រិដ្ឋកម្មរបបខ្មែរក្រហម និងទប់ស្កាត់កុំឲ្យរបបនេះវិលត្រឡប់មកវិញម្ដងទៀត។ យើងទាំងអស់គ្នាត្រូវចូលរួមថែរក្សាការពារសន្តិភាពឲ្យស្ថិតស្ថេរគង់វង្ស។

ចំពោះប្រវត្តិថ្ងៃ២០ឧសភានេះ លោក ឡុង ដានី បានបញ្ជាក់ជាសង្ខេបថា កាលពីថ្ងៃទី១៨ ខែសីហា ឆ្នាំ ១៩៨៣ សភានៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា បានកំណត់យកថ្ងៃ២០ឧសភា ជាទិវាចងកំហឹងលើរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ការកំណត់យកថ្ងៃ២០ ឧសភានេះ គឺដោយសារមេដឹកនាំខ្មែរក្រហមបានចាប់ផ្ដើមប្រព្រឹត្តអំពើប្រល័យពូជសាសន៍យ៉ាងចំហចំពោះប្រជាជនកម្ពុជា ដោយអនុវត្តនូវគោលនយោបាយមួយចំនួនដូចខាងក្រោម៖

**១)** បក្សកុម្មុយនីស្តកម្ពុជាបានអបអរសាទរនឹងកំណត់យកថ្ងៃ២០ ខែឧសភា ឆ្នាំ១៩៧៣ គឺជាថ្ងៃកំណើតសហករណ៍។ ការបង្កើតសហករណ៍នេះគឺមេដឹកនាំខ្មែរក្រហមបានបង្ខំប្រជាជនឲ្យលុបបំបាត់ចោលកម្មសិទ្ធិឯកជន និងរបបមូលធននិយម និងដើម្បីពង្រឹងវណ្ណៈកម្មករ និងកសិករ។ ការរស់នៅជាលក្ខណៈគ្រួសារខ្មែរអស់រយៈពេលរាប់ពាន់ឆ្នាំមកហើយនោះ ត្រូវបានលុបបំបាត់ចោលទាំងស្រុងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩)។ ខ្មែរក្រហមបង្កើតសហករណ៍មានន័យថាប្រជាជនត្រូវរស់នៅជាមួយគ្នា ធ្វើការជាមួយគ្នា ហូបចុកជាមួយគ្នា និងចែករំលែកការកម្សាន្តជាសមូហភាព។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ -១៩៧៩) មេដឹកនាំខ្មែរក្រហមបានរៀបចំជាសហករណ៍ជាពីរកម្រិត គឺសហករណ៍កម្រិតទាប ដែលមានសមាជិកចំនួន៣០០ទៅ៤០០គ្រួសារ ឬក៏មួយភូមិទាំងមូល និងសហករណ៍កម្រិតខ្ពស់ដែលរួមមានសមាជិក១ពាន់គ្រួសារ ឬក៏មួយឃុំទាំងមូល។ ក្រោយពេលឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានអនុវត្តនូវគោលនយោបាយសហករណ៍នេះ គឺបានប្រែក្លាយប្រជាជនទៅជាទាសករដាច់ថ្លៃរបស់អង្គការខ្មែរក្រហម ប្រជាជនត្រូវបានបង្ខំឲ្យធ្វើការងារពលកម្មធ្ងន់ធ្ងរហួសកម្លាំង ធ្វើទារុណកម្ម ឈឺគ្មានថ្នាំព្យាបាល និងសម្លាប់រង្គាលជាដើម។



២) ២០ ឧសភា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រកាសចេញនូវគោលនយោបាយរួមមាន៖ ការជម្លៀសប្រជាជន ការលុបបំបាត់ទីផ្សារ រូបិយប័ណ្ណ ដកយកក្រដាសប្រាក់ដែលខ្លួនបានបោះពុម្ពរួច ផ្សឹកព្រះសង្ឃ បង្កើតផ្ទះបាយរួម បណ្តេញជនជាតិវៀតណាម បញ្ជូនកងទ័ពទៅព្រំដែន បិទមន្ទីរពេទ្យនៅភ្នំពេញ បិទសាលាអនុវិទ្យាល័យ វិទ្យាល័យ និងមហាវិទ្យាល័យជាដើម ដូច្នេះថ្ងៃ ២០ឧសភា គឺជាថ្ងៃដែលខ្មែរក្រហមអនុវត្តគោលនយោបាយប្រល័យពូជសាសន៍នៅកម្ពុជា។

នៅអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៩០ ទិវាចងកំហឹងនេះត្រូវបានប្តូរមកជាទិវាចងចាំវិញពីព្រោះប្រទេសកម្ពុជាបានឈានចូលមកដល់ដំណាក់កាលនៃការបង្រួបបង្រួម និងផ្សះផ្សាជាតិ។ នៅឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកថ្ងៃទី២០ ខែឧសភា ជា «ទិវាជាតិនៃការចងចាំ»។ ការកំណត់យកថ្ងៃនេះធ្វើជាថ្ងៃបុណ្យជាតិផ្លូវការ សម្រាប់ជាការរំឭកដល់ជនរងគ្រោះ និងការឈឺចាប់ពីឧក្រិដ្ឋកម្មដែលកើតមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។



នៅព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅសហគមន៍ជនជាតិដើមភាគតិចស្ទៀងភូមិបុស្សតាអឹម ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដោយមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនជាតិដើមភាគតិចស្ទៀង និងកូនចៅជំនាន់ក្រោយចូលរួមចំនួន ៤០ នាក់ (ស្រី២៨ នាក់)។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**ញ៉ៃ ឆាន** ជនជាតិដើមភាគតិចស្ទៀង មានអាយុ ៦៦ឆ្នាំ ភេទប្រុស មានទីកន្លែងកំណើតនៅក្នុងភូមិបុស្សតាអឹម ស្រុកមេមត់ ខេត្តកំពង់ចាម បច្ចុប្បន្ននេះខេត្តត្បូងឃ្មុំ បានរៀបរាប់ថា ឪពុកម្តាយខ្ញុំបានស្លាប់អស់។ ខ្ញុំមានបងប្អូនចំនួន៣នាក់ ប្រុសចំនួន២នាក់

និងស្រីម្នាក់ៗ ខ្ញុំមានប្រពន្ធឈ្មោះ សាំង សមាន អាយុ ៦២ឆ្នាំ និងមានកូនចំនួន៤នាក់ គឺប្រុស២នាក់ និងស្រី២នាក់ៗ នៅឆ្នាំ១៩៧០ ពេលខ្ញុំនៅកុមារមានទាហានអាមេរិកាំង និងកងទ័ពវៀតកុងប្ដូយួនខាងជើងចូលមកនៅក្នុងភូមិៗ ពេលចូលឆ្នាំ១៩៧៣ ខ្មែរក្រហមរៀបចំជាសហករណ៍ ធ្វើចម្ការរួមគ្នា ហើយបានផលមកចែកគ្នា ព្រោះកាលនោះប្រជាជនហូបបាយនៅតាមផ្ទះនៅឡើយៗ ចូលដល់ឆ្នាំ១៩៧៥ ខ្ញុំត្រូវបានខ្មែរក្រហមចាត់ឲ្យទៅរៀននៅសាលាស ២០០ភូមិភាគបានរយៈពេលមួយខែ បន្ទាប់មកបញ្ជូនទៅធ្វើយោធានៅភ្នំពេញៗ ប៉ុន្តែដោយសារខាងសហជីពត្រូវការកម្មករ ខ្មែរក្រហមចាត់ក្រុមរបស់ខ្ញុំដែលមានសមាជិកប្រហែលជាចំនួន១០នាក់ឲ្យចូលធ្វើការនៅក្នុងសហជីពវិញៗ សម័យនោះគឺពិបាកខ្លាំងណាស់ព្រោះខ្មែរក្រហម ប្រើប្រជាជនឲ្យធ្វើការទាំងយប់ថ្ងៃលើសពីកម្លាំង ចំណែកការហូបចុកក៏មិនបានគ្រប់គ្រាន់ជាហេតុធ្វើឲ្យប្រជាជនបានស្លាប់ច្រើនៗ នៅឆ្នាំ១៩៧៩ ខ្មែរក្រហមបានជម្លៀសខ្ញុំឲ្យទៅរស់នៅខេត្តពោធិ៍សាត់ និងឲ្យទៅធ្វើជាកងចល័តប្រមូលស្រូវ និងអង្ករៗ នៅឆ្នាំ១៩៨០ ខ្ញុំធ្វើដំណើរមកជួបជុំបងប្អូននៅស្រុកកំណើតវិញ ហើយខ្ញុំបានយកប្រពន្ធនិងរស់នៅក្នុងភូមិបុស្សតាអឹមនេះរហូតមកៗ

**កង យឹន** មេភូមិបុស្សតាអឹម អាយុ៧១ឆ្នាំ

បានមានប្រសាសន៍ថា ការរៀបចំវេទិកាអប់រំប្រវត្តិសហគមន៍ស្ដីអំពីប្រវត្តិសាស្ត្រនេះ មានផលប្រយោជន៍ច្រើនចំពោះក្មេងៗជំនាន់ក្រោយបានដឹងអំពីប្រវត្តិសាស្ត្រ តាមរយៈការស្ដាប់រឿងរ៉ាវជីវិតដែលលោកតា លោកយាយ ក៏ដូចជារូបខ្ញុំផ្ទាល់ធ្លាប់ឆ្លងកាត់នៅក្នុងរបបខ្មែរក្រហមៗ ក្មេងៗជំនាន់ក្រោយគឺជាទំពាំងស្នងឫស្សីសម្រាប់ប្រទេសជាតិ និងបានដឹងពីការលំបាកវេទនារបស់ប្រជាជនដែលធ្លាប់រស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទម្រាំបានរស់មកដល់សព្វថ្ងៃៗ ជាចុងក្រោយខ្ញុំសូមអរគុណដល់ក្រុមការងារមជ្ឈ-មណ្ឌលឯកសារកោះថ្ម ដែលបានរៀបចំវេទិកាអប់រំប្រវត្តិសាស្ត្រសហគមន៍នៅក្នុងភូមិបុស្សតាអឹមនេះៗ វាគឺជាឱកាសល្អមួយ ដែលខ្ញុំ និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមផ្សេងទៀតមានពេលវេលាចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនដើម្បីឲ្យក្មេងៗជំនាន់ក្រោយបានដឹង ហើយម្យ៉ាងទៀតខ្ញុំគិតថាក្មេងៗគួរតែសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រនេះឲ្យបានច្រើនៗ

*នៅព្រឹកថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានរៀបចំវេទិកាអប់រំសហគមន៍ស្ដីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩) នៅសហគមន៍ជនជាតិដើមភាគតិចស្ទៀងភូមិបុស្សតាអឹម ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដោយមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាជនជាតិដើមភាគតិចស្ទៀង និងកូនចៅជំនាន់ក្រោយចូលរួមចំនួន ៤០ នាក់ (ស្រី២៨នាក់)ៗ*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*



# វេទិកាអប់រំសហគមន៍ស្តីពី

## «ការចងចាំនៃការបាត់បង់ជីវិតសមាជិកគ្រួសារ និងបទពិសោធន៍របស់ជនជាតិចាមក្នុងសហគមន៍កោះសូទិន ក្នុងរបបខ្មែរក្រហម»

*សាំង ចិន្តា*







នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ មជ្ឈមណ្ឌល លឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការចងចាំនៃជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម និងបទពិសោធន៍របស់ជនជាតិចាមក្នុងសហគមន៍កោះសូទិនក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីសិស្សានុសិស្សមកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ ចំនួន៥៤នាក់។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំសហគមន៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការចងចាំនៃជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម និងបទពិសោធន៍របស់ជនជាតិចាមក្នុងសហគមន៍កោះសូទិនក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមរបស់សិស្សានុសិស្សមកពីវិទ្យាល័យ ឈីន លាន ហាន់ជ័យ ចំនួន៥៤នាក់។ វេទិកាអប់រំសហគមន៍នេះត្រូវបានបង្កើតឡើងដើម្បីផ្តល់ចំណេះដឹងដល់សិស្សអំពីប្រវត្តិសាស្ត្រខ្មែរក្រហម តាមរយៈការធ្វើបទបង្ហាញការតាក់បញ្ចាំងវីដេអូឯកសារ និងបទពិសោធន៍របស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលរស់នៅក្នុងសហគមន៍ចាម ក្នុងរបបខ្មែរក្រហម។

ជាកិច្ចចាប់ផ្តើម លោក សាំង ចិន្តា នាយក

មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានស្វាគមន៍សិស្សានុសិស្សទាំងអស់ និងចាប់ផ្តើមធ្វើបទបង្ហាញស្តីអំពីប្រវត្តិសាស្ត្រ ចាប់តាំងពីរដ្ឋប្រហាររបស់ លន់ នល់ នៅឆ្នាំ១៩៧០, ការផ្ទុះឡើងនូវសង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម, ការឡើងកាន់អំណាចរបស់ខ្មែរក្រហម រហូតដល់ការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជនទៅកាន់ជនបទ។ ក្នុងបទបង្ហាញនេះ លោក ស៊ាង ចិន្តា បានផ្តោតសំខាន់ទៅលើការកំណត់ និងការបែងចែកប្រជាជនរបស់ខ្មែរក្រហមរួមមាន៖ ប្រជាជនចាស់(ឬហៅថា ប្រជាជន៧០) គឺជាប្រជាជនរស់នៅតំបន់ដែលខ្មែរក្រហមបានរំដោះចាប់តាំងពីឆ្នាំ១៩៧០។ ប្រជាជនកណ្តាល (ឬហៅថា ប្រជាជន៧៣) គឺជាប្រជាជនរស់នៅតំបន់ដែលខ្មែរក្រហមបានរំដោះនៅឆ្នាំ១៩៧៣ និង ប្រជាជន៧៥ ឬប្រជាជន១៧មេសា គឺជាប្រជាជនដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ និងទីរួមខេត្តមកកាន់ភូមិនានា បន្ទាប់ពីខ្មែរក្រហមបានឡើងកាន់កាប់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

ការកំណត់ និងការបែងចែកប្រជាជន គឺជាចំណុចសំខាន់មួយដើម្បីឲ្យសិស្សានុសិស្សយល់ដឹងអំពីប្រជាជនដែលត្រូវបានកំណត់អត្តសញ្ញាណក្នុងពេលវេលាមួយ និងទទួលរងបទពិសោធន៍ និងទុក្ខលំបាកផ្សេងៗរបស់ជនរងគ្រោះក្នុងរបបខ្មែរក្រហម។

បន្ទាប់ពីបទបង្ហាញត្រូវបានបញ្ចប់ លោក ស៊ាង ចិន្តា បានបន្តដឹកនាំសិស្សពិភាក្សាក្រោមប្រធានបទ៖ «ការចងចាំនៃការបាត់បង់ជីវិតសមាជិក និងបទពិសោធន៍របស់ជនជាតិចាមនៅសហគមន៍កោះសូទិន ក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីអ៊ំស្រី ណើស រំតះ និងអ៊ំស្រី ម៉ាត់ វី ដែលត្រូវបានខ្មែរក្រហមជម្លៀសចេញពីភូមិទៅលត់ដំនៅខេត្តបាត់ដំបងក្នុងឆ្នាំ១៩៧៦ និងបានបាត់បង់បងប្អូន និងឪពុកម្តាយនៅពេលនោះ។ អ៊ំស្រី ណើស រំតះ និង ម៉ាត់ វី ត្រូវបានដឹកជញ្ជូនតាមស្រឡាង តាមរថយន្ត និងតាមរថភ្លើង រហូតដល់ខេត្តបាត់ដំបង។ បទពិសោធន៍នៃការធ្វើដំណើរដ៏វែងឆ្ងាយ និងមិនអាចវិលត្រឡប់មកភូមិកំណើតក្នុងរបបខ្មែរក្រហម គឺនៅតែស្ថិតក្នុងការចងចាំរបស់អ៊ំស្រីទាំង២ដែលបានចែករំលែកបទពិសោធន៍ និងការបាត់បង់សមាជិកគ្រួសារ ទៅកាន់សិស្សានុសិស្សដូចខាងក្រោម៖

ណើស រំតះ អាយុ៧២ឆ្នាំ រស់នៅភូមិទី១៣ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម គឺជាជនជាតិចាមដែលត្រូវបានជម្លៀសចេញពីស្រុកកោះសូទិន ទៅកាន់ខេត្តបាត់ដំបង រៀបរាប់អំពីបទពិសោធន៍ក្នុងកងចល័តនារី និងការបាត់បង់បងប្រុសស្រីក្នុងរបបខ្មែរក្រហម៖

«ខ្ញុំមិនបានរៀនសូត្រទេដោយសារជីវភាពគ្រួសារមានការលំបាក។ នៅឆ្នាំ១៩៧០ មានរដ្ឋប្រហារទម្លាក់សម្តេចឪកើតឡើង។ បាតុកម្មបានផ្ទុះឡើង ហើយបាតុករដង្ហែក្បួនតវ៉ាទៅកាន់ទីរួមខេត្តកំពង់ចាម។ នៅពេលនោះគ្រួសារខ្ញុំរត់ទៅរស់នៅម្តុំរការកោង និងក្រោយមកវិលត្រឡប់មករស់នៅភូមិវិញ។ នៅឆ្នាំ១៩៧៦ គ្រួសារខ្ញុំត្រូវបានជម្លៀសទៅខេត្តបាត់ដំបងតាមផ្លូវទឹក (ជិះស្រឡាង) និងផ្លូវដែក (ជិះរទេះភ្លើង)។ ខ្ញុំត្រូវបានដាក់ឲ្យធ្វើការនៅកងចល័តនារី ធ្វើការងារដកស្ទូង រែកដី និងលើកទំនប់។ ខ្ញុំត្រូវទៅធ្វើការចាប់ពីម៉ោង៦ដល់ម៉ោង១១ទើបបានឈប់សម្រាកថ្ងៃត្រង់ និងបន្តទៅធ្វើការងារ ចាប់ពីម៉ោង១ដល់ម៉ោង៥ល្ងាច។ នៅពេលនោះ ខ្ញុំត្រូវស្ទូងស្រូវ។ ប្រសិនបើខ្ញុំស្ទូងស្រូវអណ្តែតមួយដើម ខ្ញុំនឹងត្រូវបានចាប់វាយធ្វើបាប ឬសម្លាប់ចោល។ បងស្រីរបស់ខ្ញុំបានដួលដោយសារតែភ្លៀងខ្យល់ខ្លាំង និងត្រូវបានចាប់យកទៅធ្វើទារុណកម្មដោយការក្របួចសក់ឡើងលើដើម្បីវាយ និងបន្ទាប់មកត្រូវបានយកទៅសម្លាប់។ ខ្ញុំធ្វើការនៅការដ្ឋានរាំងក្រោល ដែលមានប្រធានកងចល័តឈ្មោះ ណុច និងប្រពន្ធឈ្មោះ ចាន់។ ប្រធានកងចល័ត និងប្រពន្ធមានចរិតកាចសាហាវខ្លាំងណាស់។ បងប្រុសស្រីរបស់ខ្ញុំចំនួន៣នាក់ត្រូវបានសម្លាប់នៅការដ្ឋាន។ ខ្ញុំរួចផុតពីការកាប់សម្លាប់ និងការអត់ឃ្លាននៅពេលនោះ។ ខ្ញុំនៅតែចងចាំបងប្រុសស្រីរបស់ខ្ញុំដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម»។



នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំសហគមន៍ស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការចងចាំនៃជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម និងបទពិសោធន៍របស់ជនជាតិចាមក្នុងសហគមន៍កោះសូទិនក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីសិស្សានុសិស្សមកពីវិទ្យាល័យឈើន លាន ហាន់ជ័យ ចំនួន៥៨នាក់។
(លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ម៉ាត់ វី អាយុ៦២ឆ្នាំ រស់នៅភូមិទី១៥ ឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម គឺជាជនជាតិចាមដែលត្រូវបានជម្លៀសចេញពីស្រុកកោះសូទិន ទៅកាន់ខេត្តបាត់ដំបង រំឭកអំពីបទពិសោធន៍ក្នុងកងចល័តនារី និងការបាត់បង់បងប្រុសស្រីក្នុងរបបខ្មែរក្រហម ៖

«ខ្ញុំកើតនៅភូមិទី១៥ ឃុំកោះសូទិន ស្រុកកោះសូទិន។ នៅវ័យកុមារ ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាវត្តចុងកោះ។ នៅឆ្នាំ១៩៧១ ខ្ញុំឈប់រៀនពីព្រោះនៅពេលនោះមានការប្រយុទ្ធគ្នារវាងទាហានលន់នល់ និងកងទ័ពរំដោះខ្មែរក្រហម។ សង្គ្រាមរវាងទាហាន លន់ នល់ និងកងទ័ពរំដោះខ្មែរក្រហម ផ្ទុះកាន់តែខ្លាំងឡើងៗ រហូតដល់ ឆ្នាំ១៩៧៣។ នៅឆ្នាំ១៩៧៤ ឪពុកម្ដាយខ្ញុំនាំកូនៗរត់ភៀសខ្លួនទៅស្នាក់នៅម្ដុំមហាលាភ និងបន្ទាប់មកបានវិលត្រឡប់មករស់នៅភូមិកំណើតវិញ។ នៅឆ្នាំ១៩៧៥ ឪពុកម្ដាយខ្ញុំត្រូវបានដាក់ឲ្យធ្វើការកងប្រវាស់ដៃ ដើម្បីជួយច្រូត ស្រូវ និងប្រមូលផលដំណាំផ្សេងៗចែកគ្នាហូប។ នៅឆ្នាំ១៩៧៦ គ្រួសាររបស់ខ្ញុំត្រូវបានជម្លៀសទៅខេត្តបាត់ដំបង ដោយជិះស្រឡាង២ជាន់ដែលពោលពេញទៅដោយប្រជាជនជម្លៀស។ គ្រួសារខ្ញុំបានទៅដល់ឃ្លាំងស្បែក និងត្រូវបានដាក់ឲ្យជិះរថយន្តរហូតដល់ស្ថានីយរទេះភ្លើង។ គ្រួសារខ្ញុំបន្តឡើងជិះរទេះភ្លើងរហូតមកដល់ខេត្តបាត់ដំបង។ នៅពេលនោះ ម្ដាយខ្ញុំបានសួរខ្មែរក្រហមថា តើទៅដល់កន្លែងហើយឬនៅ? ខ្មែរក្រហមបានតបមកវិញថា មិនទាន់ទៅដល់កន្លែងស្នាក់នៅទេ គឺត្រូវជិះរទេះគោទៅស្រះកែវបន្តទៀត។ ខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅកងចល័តដែលត្រូវដកសំណាប និងរែកសំណាបដើម្បីស្ទូងស្រូវ។ ខ្ញុំអាណិតប្អូនខ្ញុំខ្លាំងណាស់ ពីព្រោះប្អូនខ្ញុំបានស្លាប់ដោយសារតែជំងឺ និងការអត់ឃ្លាន។ ខ្ញុំធ្វើការនៅការដ្ឋានបឹងពើតនៅខេត្តបាត់ដំបង។ បឹងនោះគឺធំណាស់ ដែលមើលទៅ

គឺសុទ្ធតែវាលស្រែ។ សមាជិកគ្រួសារខ្ញុំជាច្រើននាក់បានស្លាប់បាត់បង់ជីវិតនៅពេលនោះ។ ខ្ញុំបានរួចផុតពីសេចក្ដីស្លាប់ និងនៅតែនឹករឭកគ្រួសារជាទីស្រលាញ់ជានិច្ច»។

សិស្សឈ្មោះ ស៊ុន នីតា ថ្នាក់ទី១០-អេ (A) ផ្នែកវិទ្យាសាស្ត្រពិត មកពីវិទ្យាល័យ ឈឹន លានហាន់ជ័យ ដែលបានចូលរួមវេទិកាអប់រំសហគមន៍នេះ លើកឡើងថា «ថ្ងៃនេះ ខ្ញុំទទួលបានឱកាសចូលរួមវេទិកាអប់រំសហគមន៍នៅក្នុងឃុំកោះសូទិន រៀបចំដោយមជ្ឈមណ្ឌលឯកសារ ខេត្តកំពង់ចាម។ ខ្ញុំទទួលបានចំណេះដឹងជាច្រើន និង បទពិសោធន៍ពីប្រវត្តិសាស្ត្រខ្មែរក្រហម ដែលប្រទេសកម្ពុជាធ្លាក់ក្នុងអន្លង់នៃភាពវឹកវរក្នុងរបបប្រល័យពូជសាសន៍ និងសង្គ្រាម។ បន្ថែមលើនេះទៀត ខ្ញុំបានយល់ដឹងអំពីបទពិសោធន៍លំបាក និងការបាត់បង់របស់ជនជាតិចាមក្នុងរបបខ្មែរក្រហម។ អ្វីដែលខ្ញុំចាប់អារម្មណ៍បន្ថែមទៀតនោះគឺ ក្នុងរបបខ្មែរក្រហម មិនមានការលេងកីឡា ប៉ុន្តែនៅពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានសុខសន្តិភាព និងកំពុងធ្វើជាម្ចាស់ផ្ទះក្នុងការប្រកួតកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ដែលធ្វើឲ្យអ្នកលេងកីឡាកាន់តែមានច្រើនឡើង ហើយកីឡារបស់យើងខ្លះត្រូវបានដាក់បញ្ចូលក្នុងការប្រកួតផងដែរ ដូចជាគុនល្បុក្កតោខ្មែរ។ ដូច្នេះ ក្នុងនាមជាយុវជនជំនាន់ក្រោយ ខ្ញុំយល់ថា ការសិក្សាពីប្រវត្តិសាស្ត្រគឺពិតជាមានសារសំខាន់ណាស់»។

សិស្សឈ្មោះ គ្រេង ស៊ាងអ៊ី ថ្នាក់ទី១០-អេ(A) ផ្នែកវិទ្យាសាស្ត្រពិត មកពីវិទ្យាល័យ ឈឹន លានហាន់ជ័យ លើកឡើងថា «ខ្ញុំទទួលបានចំណេះដឹងបន្ថែម និងការយល់ដឹងអំពីរបបខ្មែរក្រហម រួមមានការរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ភាពលំបាកវេទនា ការធ្វើការងារគ្មានពេលសម្រាក និងការហូបចុកមិនគ្រប់គ្រាន់។ ខ្ញុំក៏ធ្លាប់ស្ដាប់រឿងរ៉ាវជីវិត និងបទពិសោធន៍ជីវិតរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែរ។ ខ្ញុំពិតជាអាណិតគាត់ខ្លាំងណាស់។ ក្រៅពីរឿងរ៉ាវខាងលើ ខ្ញុំដឹងថាក្នុងរបបខ្មែរក្រហមមិនមានការលេងកីឡាទេ គឺមានតែការបង្ខំឲ្យប្រជាជនធ្វើការងារហួសកម្លាំង។ ប៉ុន្តែនៅពេលបច្ចុប្បន្ននេះ ប្រទេសយើងមានសន្តិភាព ដូច្នេះ កីឡាមួយចំនួនបានរស់ឡើងវិញ»។

សិស្សឈ្មោះ ដេង យូរីម ថ្នាក់ទី១០-អេ(A) ផ្នែកវិទ្យាសាស្ត្រពិត មកពីវិទ្យាល័យ ឈឹន លានហាន់ជ័យ និយាយថា «នៅថ្ងៃនេះ ខ្ញុំចូលរួមវេទិកាអប់រំសហគមន៍នៅឃុំកោះសូទិន នឹងយល់ដឹងអំពីរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ក្នុងរបប ប៉ុល ពត ចាស់ទុំដែលនៅរស់រានមានជីវិតបានចែករំលែកប្រាប់ខ្ញុំអំពីការលំបាកវេទនា ការបង្ខំឲ្យធ្វើការងារធ្ងន់ធ្ងរ ការហូបចុកមិនគ្រប់គ្រាន់ ការបែកចេញពីគ្រួសារ និងការចាប់យកទៅសម្លាប់ ដែលបន្សល់ទុកនូវការស្លាប់ប្រជាជនជិត២លាននាក់។ ចាស់ទុំដែលជាជនជាតិចាម និងជនជាតិខ្មែរ ទទួលរងការធ្វើបាប និងការលំបាកមិនខុសគ្នានោះទេក្នុងរបប ប៉ុល ពត។ អ្វីដែលធ្វើឲ្យខ្ញុំអាណិតអាសូរគាត់ជាខ្លាំងនោះគឺ គាត់និយាយបណ្ដើរ យំបណ្ដើរដើម្បីប្រាប់ខ្ញុំអំពីរឿងរ៉ាវមិនអាចបំភ្លេចបានដែលគាត់បានឆ្លងកាត់»។



នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាអប់រំសហគមន៍ស្ដីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ក្រោមប្រធានបទ «ការចងចាំនៃជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម និងបទពិសោធន៍របស់ជនជាតិចាមក្នុងសហគមន៍កោះសូទិនក្នុងរបបខ្មែរក្រហម» ដោយមានការចូលរួមពីសិស្សានុសិស្សមកពីវិទ្យាល័យ ឈឹន លានហាន់ជ័យ ចំនួន៥៨នាក់។
( លី ដេវីត/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# វេទិកាអប់រំសហគមន៍ស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) នៅខេត្តព្រៃវែង

ថុន ស្រីពេជ្រ



មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានធ្វើវេទិកាអប់រំសហគមន៍ ដើម្បីពិភាក្សាអន្តរជំនាន់រវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុចាប់ពី៥០ឆ្នាំ ជាមួយសិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយមកពីអនុវិទ្យាល័យ និងវិទ្យាល័យផ្សេងគ្នាក្នុងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង កាលពីព្រឹកថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ទិវានៃការចងចាំអំពើប្រល័យពូជសាសន៍នៅកម្ពុជា ខិតជិតចូលមកដល់ ហើយរដ្ឋាភិបាលកំពុងតែរៀបចំទីកន្លែងដើម្បីរំឭកនៃការចងចាំជាណ្ដើរៗនៅស្តូបនៃខេត្តព្រៃវែង។ ប្រជាជនដែលមានអាយុចាប់ពី៥០ឆ្នាំឡើង នៅចងចាំមិនភ្លេចចំពោះរបប ៣ឆ្នាំ៨ខែ២០ថ្ងៃនេះ។ ដូច្នេះហើយបានជាមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានធ្វើកម្មវិធីវេទិកាអប់រំសហគមន៍នេះឡើង ដើម្បីពិភាក្សាអន្តរជំនាន់រវាងអ្នករស់រានមានជីវិត ដែលមានអាយុចាប់ពី ៥០ឆ្នាំ ជាមួយសិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយមកពីអនុវិទ្យាល័យ និងវិទ្យាល័យផ្សេងគ្នាក្នុងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង។ វេទិកានេះបានផ្តោតសំខាន់ទៅលើការរំឭកឡើងវិញពី



មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានរៀបចំធ្វើវេទិកាអប់រំសហគមន៍ ដើម្បីពិភាក្សាអន្តរជំនាន់រវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុចាប់ពី៥០ឆ្នាំឡើងទៅ ជាមួយសិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយមកពីអនុវិទ្យាល័យ និងវិទ្យាល័យផ្សេងគ្នាក្នុងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង កាលព្រឹកថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

«ការបង្កើតសហករណ៍ខ្មែរក្រហម និងឈ្លើយយល់ពីទុក្ខលំបាក ការសម្លាប់ និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងសម័យនោះ ដែលជាផលប៉ះពាល់បន្ទាប់ពីការបង្កើតសហករណ៍»។ វេទិកានេះត្រូវបានរៀបចំឡើង នាព្រឹកថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣ក្នុងបរិវេណវត្តពន្លៃភូមិពន្លៃឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង ដោយមានអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមចំនួន១០នាក់ និងសិស្សដែលជាយុវជនជំនាន់ក្រោយចំនួន២០នាក់ មកចូលរួម។

នៅវេលាម៉ោង៩៖៣០នាទីព្រឹក លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំអំពើប្រល័យពូជសាសន៍នៅកម្ពុជា បានណែនាំខ្លួនក្រុមការងារ និងបង្ហាញអំពីការិយាល័យមជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាកន្លែងតម្កល់ទុកឯកសារខ្មែរក្រហមជិត១លានទំព័រដែលជាឯកសារក្រដាស ។ ក្រៅពីនេះមាន ឯកសារសម្ភាសន៍អ្នករស់រានមានជីវិតនៅតាមស្រុកភូមិ ឯកសាររូបថតនៅក្នុងសម័យខ្មែរក្រហម ឯកសារទាក់ទងរណ្តៅសាកសព ទីតាំងសម្លាប់ និងឯកសារខ្សែភាពយន្តនៅក្នុងរបបខ្មែរក្រហម និងក្រោយសម័យខ្មែរក្រហម។ បន្ទាប់មកលោក នាយ ឆ្លូយ ប្រធានភូមិពន្លៃមានមតិស្វាគមន៍ និងបើកដំណើរការកម្មវិធី។

ជាកិច្ចបន្តលោក ផេង ពង្សរ៉ាស៊ី បានធ្វើបទបង្ហាញខ្លីស្តីអំពីការបង្កើតសហករណ៍ ឬជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជនក្នុងរបបខ្មែរក្រហម។ ការបង្កើតសហករណ៍នេះ គឺជាការបង្កើតឲ្យមានការកាប់សម្លាប់ ការធ្វើទារុណកម្ម ការអត់ឃ្លាន ការធ្វើការងារពលកម្មធ្ងន់ធ្ងរ ការបាក់កម្លាំង ការបែកបាក់ក្រុមគ្រួសារ ការខ្វះខាតថ្នាំសង្កូវដើម្បីព្យាបាល ការបំបិទសិទ្ធិសេរីភាព និងការដកហូតទ្រព្យសម្បត្តិឯកជន។

ជាមួយគ្នានេះដែរ អ្នករស់រានមានជីវិតឈ្មោះ ស្រី សំអាន បានឡើងមានប្រសាសន៍អំពីទំនាក់ទំនងគ្នារវាងសម័យខ្មែរក្រហម និងសម័យបច្ចុប្បន្ន ដែលជាសង្គមពីរខុសប្លែកគ្នា។ «បច្ចុប្បន្នប្រជាជនរស់នៅមានសិទ្ធិសេរីភាពអាចដើរទៅណាមកណាបានដោយសេរី ហើយរស់នៅដោយមិនមានភាពភ័យខ្លាច។ ងាកមកមើលសម័យខ្មែរក្រហម ក្នុងរយៈពេល៣ឆ្នាំ៨ខែ២០ថ្ងៃ បានសម្លាប់មនុស្សជាង២លាននាក់។ សំអាន បានបន្ថែមថា ប្រទេសដទៃក៏បានធ្វើបដិវត្តន៍ដូចប្រទេសកម្ពុជាយើងដែរ ដូចជា ប្រទេសវៀតណាម ប៉ុន្តែមិនបានសម្លាប់មនុស្សដូចរបបនេះឡើយ។ សព្វថ្ងៃនេះប្រទេសកម្ពុជាមានសន្តិភាពពេញលេញ មានទីផ្សារ និងមានការលក់ដូរ។ ចំណែកវិស័យសំណង់ និងប្រព័ន្ធអប់រំក៏មានការរីកចម្រើនដែរ។ សិស្សានុសិស្សសម័យឥឡូវរៀនបានខ្ពង់ខ្ពស់ខុសប្លែកពីសិស្សសម័យខ្មែរក្រហម ដែលមិនបានរៀនសូត្រ។ នៅក្នុងរបបខ្មែរក្រហមសិស្សានុសិស្សណាចង់បានសញ្ញាបត្រត្រូវទៅយកនៅវាលស្រែ។ ដូច្នេះចៅៗទាំងអស់គ្នាគួរចងចាំ និងត្រូវមានស្មារតីកុំយកគំរូតាមសម័យកាលនៃរបបខ្មែរក្រហម»។

អ៊ំប្រុសប៊ិនតូមបានមានប្រសាសន៍ថា«នៅពេលដែល ប៉ុល ពត ចូលមកភូមិ ខ្ញុំត្រូវបានបញ្ជូនឲ្យទៅលើកដីនៅកំចាយមារ ដែលកាលនោះមិនទាន់ហូបបាយរួមទេ។ អស់រយៈពេល៤ខែ ទើបអង្គការរំសាយអង្គភាពរបស់ខ្ញុំ និងឲ្យខ្ញុំវិលត្រឡប់មកផ្ទះ

វិញ។ ពេលមកដល់ផ្ទះ ខ្ញុំបានដឹងថាប្អូនស្រីរបស់ខ្ញុំបានស្លាប់ ហើយម្តាយបានឈឺ។ ខ្ញុំមិនអាចសម្រាកនៅផ្ទះបានយូរថ្ងៃទេ ព្រោះអង្គការបានប្រើខ្ញុំឲ្យធ្វើការងារបន្តទៀត។ លើកនេះ ខ្ញុំត្រូវបែកពីឪពុកម្តាយ និងគ្រួសារទៀត។ ខ្មែរក្រហមប្រើខ្ញុំដូចគោដូចក្របី ប៉ុន្តែមិនបានផ្តល់អាហារឲ្យហូបចុកគ្រប់គ្រាន់ឡើយ។ មួយថ្ងៃៗ ខ្ញុំហូបតែសម្លគល់ចេក។ ដូច្នេះ សូមឲ្យចៅៗចងចាំជានិច្ចថា របប៣ឆ្នាំ ៨ខែ២០ថ្ងៃ នេះមិនបានចម្រើនដល់ប្រទេសយើងទេ មានតែការកាប់សម្លាប់ប្រជាជនអស់ជាច្រើននាក់។

អ៊ំស្រី ហែម សៀ បានរៀបរាប់ថា ដូចជារូបខ្ញុំ អង្គការបានហៅឲ្យទៅច្រូតស្រូវ។ ខ្ញុំហូបបាយរួមជាមួយប្រជាជនឯទៀត។ នៅសម័យនោះគឺតឹងតែងខ្លាំងណាស់។ បើយើងឈឺគ្រុនផ្តាសាយ គឺមិនមានថ្នាំអ្វីគ្រប់គ្រាន់ដើម្បីព្យាបាលទេ ហើយត្រូវបានអង្គការលួចតាមដានទៀតថា យើងឈឺពិតមែនឬអត់។ អង្គការបានធ្វើទុក្ខបុកម្នេញមកលើបងប្អូនយើង។ ជួនកាលយើងមិនបានបង្កើតឲ្យមានកំហុសផង ក៏អង្គការចោទថាមានទោសកំហុសដែរ ហើយយកទៅរៀនសូត្រ និងសម្លាប់ដោយគ្មានញញើតដៃ។

ក្រោយស្តាប់ការចែករំលែកពីអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមរួចមក លោក ផេង ពង្សរ៉ាស៊ី បានលើកទឹកចិត្តឲ្យសិស្សានុសិស្សទាំងអស់ ពេលដែលត្រឡប់ទៅផ្ទះវិញ សូមអានសៀវភៅប្រវត្តិ-





មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានរៀបចំធ្វើវេទិកាអប់រំសហគមន៍ ដើម្បីពិភាក្សាអន្តរជំនាន់រវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុចាប់ពី៥០ឆ្នាំឡើងទៅ ជាមួយសិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយមកពីអនុវិទ្យាល័យ និងវិទ្យាល័យផ្សេងគ្នាក្នុងឃុំអង្គរស ស្រុកមេសាង ខេត្តព្រៃវែង កាលព្រឹកថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សាស្ត្រខ្មែរក្រហមឲ្យបានច្រើន និងសួរនាំបទពិសោធន៍លោកតាលោកយាយរបស់ខ្លួនដែលឆ្លងកាត់របបខ្មែរក្រហមបន្ថែមទៀត។ មុននឹងបញ្ចប់ ការពិភាក្សាជាអន្តរជំនាន់បានបញ្ចប់នៅវេលាម៉ោង១១៖៣០នាទីព្រឹក លោក ផេង ពង្សរ៉ាស៊ី ក៏បានលើកឡើងអំពីកីឡាប្រកួតស៊ីហ្គេម លើកទី៣២ ដែលប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះ ។ លោក ផេង ពង្សរ៉ាស៊ី បានបន្ថែមថា រាល់ប្រភេទកីឡាទាំងអស់នៅស៊ីហ្គេម និងនៅក្នុងប្រទេសដទៃ ប្រទេសកម្ពុជារបស់យើងក៏មានប្រភេទកីឡានោះដែរ។ ប្រទេសកម្ពុជាយើងទើបតែរួចផុតពីរបបខ្មែរក្រហម ប៉ុន្តែវិស័យកីឡាហាក់មានការរីកចម្រើន។ ប្រទេសយើងអាចយកបានមេដាយមាសជូនជាតិគួរជាទីពេញចិត្ត និងមានមោទកភាព។ រហូតមកដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣នេះ ប្រទេសកម្ពុជា ឈរនៅលេខរៀងទី២បន្ទាប់ពីប្រទេសវៀតណាម។

លោកអាចារ្យនៃវត្តពន្លៃដែលជាអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមក៏បានទៅមើលកីឡាប្រកួត ស៊ីហ្គេម នៅទីលានផ្ទាល់ ព្រោះគាត់យល់ថាកីឡាស៊ីហ្គេម ពិតជាមានសារសំខាន់ចំពោះប្រទេសរបស់យើង។ គាត់គិតថានេះជាឱកាសតែម្តងគត់សម្រាប់គាត់។ ដូច្នេះ សូមប្រជាជនទាំងអស់ចូលរួមទស្សនាការផ្សាយបន្តផ្ទាល់រហូតដល់ចប់កម្មវិធី ព្រោះជាមុខជាមាត់នៃប្រទេសរបស់យើង និងលើកទឹកចិត្តដល់កីឡាកររបស់យើងទាំងអស់គ្នា។

ជាចុងក្រោយ លោក នាយ ឆួយ ប្រធានភូមិពន្លៃឡើងនិយាយបិទកម្មវិធី និងផ្តាំផ្ញើទៅកាន់សិស្សានុសិស្សទាំងអស់ឲ្យយកចិត្តទុកដាក់ចំពោះការរៀនសូត្រ និងអានសៀវភៅដែល មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែងចែកឲ្យ ដូចជា សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងទស្សនាវដ្តីស្វែងរកការពិត។

## ចំណាប់អារម្មណ៍សិស្ស

ខ្ញុំឈ្មោះ សុភ័ក្ត្រ ស្រីពេជ្រ ភេទស្រី អាយុ១៨ឆ្នាំ គឺជាសិស្សនៃវិទ្យាល័យអន្លង់រស ថ្នាក់ទី១២C។ ខ្ញុំមានអារម្មណ៍ថាសប្បាយចិត្ត នៅពេលបានឃើញលោកតាលោកយាយដែលជាសាក្សីរស់បានមកចែករំលែកបទពិសោធន៍ទៅកាន់ក្មេងៗជំនាន់ក្រោយដូចជារូបខ្ញុំ។ ខ្ញុំមានអារម្មណ៍អាណិតអាសូរ និងយល់ពីទុក្ខលំបាករបស់គាត់ក្នុងរបប ប៉ុល ពត។ ជាចុងក្រោយ ខ្ញុំសូមសំណូមពរឲ្យមានការបន្តបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហម ដើម្បីកុំឲ្យកូនខ្មែរជំនាន់ក្រោយភ្លេច និងចងចាំពីរបបនេះជារៀងរហូត។ ខ្ញុំនឹងយកចំណេះដឹងពីការរៀនសូត្រនេះ ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិនាពេលខាងមុខ និងទប់ស្កាត់កុំឲ្យរបបកម្ពុជាប្រជាធិបតេយ្យកើតឡើងសាជាថ្មីម្តងទៀត។



មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង បានរៀបចំធ្វើវេទិកាអប់រំសហគមន៍ ដើម្បីពិភាក្សាអន្តរជំនាន់រវាងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលមានអាយុចាប់ពី៥០ឆ្នាំ ជាមួយឡើងទៅសិស្សានុសិស្សដែលជាក្មេងជំនាន់ក្រោយមកពីអនុវិទ្យាល័យ និងវិទ្យាល័យផ្សេងគ្នាក្នុងឃុំអន្លង់រស ស្រុកមេសាង ខេត្តព្រៃវែង កាលព្រឹកថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាថ្នាក់រៀនរំឭកអំពីទិវាជាតិនៃការចងចាំ២០ឧសភា

ភា វស្ទី



សិស្សានុសិស្សចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅសល់តែប៉ុន្មានថ្ងៃទៀតប៉ុណ្ណោះ នឹងដល់ថ្ងៃទី២០ឧសភា ការប្រារព្ធធ្វើពិធីសាសនា និងពិធីរំឭកការចងចាំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ នឹងធ្វើឡើងនៅទូទាំងប្រទេសកម្ពុជា។ កាលពី៥០ឆ្នាំមុន គឺខែឧសភា ឆ្នាំ១៩៧៣ អង្គការបដិវត្តន៍ខ្មែរក្រហម បានបង្កើតសហករណ៍ដើម្បីបង្ហាញពីសាមគ្គីភាពជាធ្លុងមួយ របស់ប្រជាជនមូលដ្ឋានក្នុងការគាំទ្រដល់កម្លាំងបដិវត្តន៍មហាលោតផ្លោះមហាអស្ចារ្យ។ នៅក្នុងសម័យខ្មែរក្រហម ការបង្កើតសហករណ៍កាន់តែមានលក្ខណៈរីកចម្រើនទៅមុខជាលំដាប់ ពីសហករណ៍កម្រិតទាបទៅសហករណ៍កម្រិតខ្ពស់។ ភាពរីកចម្រើនទៅមុខនេះ កាន់តែធ្វើឲ្យជីវិតប្រជាជនរស់នៅជួបប្រទះទុក្ខលំបាកវេទនាគ្រប់បែបយ៉ាង និងឈានដល់ការបាត់បង់ជីវិតមនុស្សជាងពីរលាននាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម។

វេទិកាថ្នាក់រៀនស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នាខែឧសភា ឆ្នាំ២០២៣ បានលើកប្រធានបទ «ការបង្កើតសហករណ៍ខ្មែរក្រហម និងផលប៉ះពាល់បន្ទាប់មកទៀត» មកធ្វើការពិភាក្សា និងពន្យល់ពីព្រឹត្តិការណ៍ឃោរឃៅនានា ដែលជាលទ្ធផលបានមកពីការបង្កើតសហករណ៍របស់ខ្មែរក្រហម។ សិស្សានុសិស្សមកពីវិទ្យាល័យមេសាង ចំនួន៣៣នាក់ ស្រី១៥នាក់ និងគ្រូដឹកនាំសិស្សចំនួន២នាក់ បានមកចូលរួមនៅក្នុងវេទិកាថ្នាក់រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ គ្រូខ្មេស ដេង ពង្សរ៉ាស៊ី បានលើកយកជំពូកទី៨ នៃ



សិស្សានុសិស្សចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

សៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ មានចំណងជើង «ជីវិតរស់នៅប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យ» មកធ្វើបទបង្ហាញ និងពន្យល់យ៉ាងក្បោះក្បាយពីចំណុចសំខាន់ៗ មួយចំនួនដូចជា ៖ ការបង្កើតសហករណ៍, វណ្ណៈសង្គមថ្មីពីរ, ពិធីរៀបមង្គលការ ការរំលោភលើសិទ្ធិ, និងពលកម្មរបស់កុមារ, ការបង្ខំឲ្យធ្វើការងារជាទម្ងន់, បន្សុទ្ធកម្ម និងការសម្លាប់រង្គាល។ សិស្សានុសិស្សទាំងអស់បានដឹងពីការរស់នៅរបស់ប្រជាជនក្នុងសម័យខ្មែរក្រហមជាពិសេស ទុក្ខលំបាករបស់ប្រជាជនក្នុងការបង្កើតសហករណ៍ និងការសម្លាប់មនុស្សយ៉ាងព្រៃផ្សៃ។

ចុងបញ្ចប់នៃកម្មវិធីវេទិកាថ្នាក់រៀនចុងសប្តាហ៍ សិស្សានុសិស្សទាំងអស់ត្រូវបានវាស់ស្ទង់ពីចំណេះដឹងទាក់ទងនឹងការបង្កើតសហករណ៍ តាមរយៈការសួរសំណួរ «តើការបង្កើតសហករណ៍របស់ខ្មែរក្រហមបណ្តាលឲ្យមានមនុស្សស្លាប់ច្រើនដែរឬទេ? មូលហេតុអ្វី?»។ សំណួរនេះ ត្រូវបានផ្តល់ឲ្យតាមរយៈការបំពេញតារាងស្ទាបស្ទង់មតិក្រោយការធ្វើបទបង្ហាញវេទិកាថ្នាក់រៀន ហើយសិស្សានុសិស្សទាំងអស់បានបំពេញសំណួរនេះគ្រប់គ្នា។ តាមរយៈចម្លើយដែលសិស្សានុសិស្សបានឆ្លើយ យើងអាចសន្និដ្ឋានបានថា សិស្សានុសិស្សទាំងអស់ពិតជាបានផ្តល់ចម្លើយស្រដៀងគ្នាថា ការបង្កើតសហករណ៍ គឺពិតជានាំឲ្យប្រជាជនស្លាប់ច្រើន ព្រោះប្រជាជនត្រូវធ្វើការហួសកម្លាំង, គ្រោះអត់ឃ្លាន, បាត់បង់ស្មារតី និងវិញ្ញាណ, បែកបាក់ក្រុមគ្រួសារ, ទារុណកម្ម និងការជម្លៀស។ ចម្លើយរបស់សិស្សានុសិស្សចំនួន៤នាក់ដំបូង ត្រូវបានយកមកភ្ជាប់ជាមួយនឹងសំណេរ ដូចខាងក្រោម៖



សិស្សានុសិស្សចូលរួមវេទិកាថ្នាក់រៀនចុងសប្តាហ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ធន់ សុខឃាង ភេទប្រុស អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យមេសាង បានលើកឡើងថា ការបង្កើតសហករណ៍របស់ខ្មែរក្រហមនាំឲ្យមានការសម្លាប់មនុស្ស ព្រោះនៅក្នុងរបបខ្មែរក្រហមគឺជារបបមួយពោរពេញទៅដោយការរើសអើងគ្នា។ អ្នកមានទ្រព្យសម្បត្តិ និងអ្នកចេះដឹង ត្រូវបានអង្គការចាប់យកទៅសម្លាប់ចោល។ លើសពីនេះទៅទៀត អង្គការបានបង្ខំឲ្យប្រជាជនខ្មែរទូទាំងប្រទេសនាំគ្នាទៅទីជនបទ ដើម្បីធ្វើស្រែចម្ការ និងធ្វើការហួសកម្លាំងលើសរយៈពេល១២ម៉ោងក្នុងមួយថ្ងៃ។ ប្រជាជនត្រូវបានបង្ខំឲ្យធ្វើការពេលយប់បន្ថែមទៀតចាប់ពីម៉ោង៦ ដល់ម៉ោង១០យប់ ធ្វើឲ្យមានជំងឺ បាក់កម្លាំងស្លាប់ជាច្រើននាក់។ អង្គការបានឲ្យប្រជាជនហូបបបរបន្តិចបន្តួចក្នុងមួយថ្ងៃ ហើយប្រជាជនមួយចំនួនដាច់ពោះស្លាប់ និងខ្លះទៀតហ៊ានលួចអាហារហូប។ ចំពោះប្រជាជនដែលហ៊ានលួចអាហារហូបអង្គការចាត់ទុកថាជាជនក្បត់ និងយកទៅសម្លាប់ចោល។

ម៉ៅ ស្រីពៅ ភេទស្រី អាយុ១៩ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យមេសាងយល់ថា ការបង្កើតសហករណ៍របស់ខ្មែរក្រហមនាំឲ្យមានការសម្លាប់មនុស្ស ដោយសារមនុស្សមួយចំនួនរស់នៅមិនចេះយោគយល់គ្នា មានតែការចងកំហឹងទៅលើគ្នា និងមានការឈ្លោះទាស់ទែងគ្នា ឈានដល់ការប្រើអំពើហិង្សា។ នៅគ្រប់ការដ្ឋានការងារទាំងអស់តែងតែមានអ្នកតូច អ្នកធំ នៅគ្រប់កន្លែងសម្បូរអង្គការភ្នែកម្នាស់ ថ្នាក់លើយកព័ត៌មានមិនពិត ហើយចុះមកសម្លាប់មនុស្សដោយគ្មានហេតុផល។ ប្រជាជនរស់នៅក្នុងភាពភ័យខ្លាច ព្រោះមានការកាប់សម្លាប់ ការធ្វើពលកម្មធ្ងន់ធ្ងរ ជួបជុំគ្នាអង្គការចោទថាក្បត់ បេះផ្លែឈើតិចតួចចោទថាខ្មាំង រស់នៅគ្មានសិទ្ធិសេរីភាព មិនចេះសាមគ្គីគ្នា និងកាប់សម្លាប់ធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ។

រ៉ុម សារាយ ភេទប្រុស អាយុ១៨ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យមេសាងយល់ឃើញថា ការបង្កើតសហករណ៍របស់ខ្មែរក្រហមនាំឲ្យមានការសម្លាប់មនុស្ស ព្រោះប្រជាជនរស់នៅដោយមិនមានការទុកចិត្តគ្នាទៅវិញទៅមក ប្រជាជនដែលលួចលាក់ទ្រព្យសម្បត្តិ ចំណីអាហារត្រូវបានអង្គការចោទជាខ្មាំង នឹងត្រូវយកទៅសម្លាប់ចោល។ ឪពុកម្តាយប្រពន្ធកូនត្រូវយកការណ៍ពីគ្នាទៅវិញទៅមក។ ប្រសិនបើធ្វើខុសនឹងត្រូវយកទៅសម្លាប់។ នៅពេលមានការសម្តែងសិល្បៈ ប្រជាជនត្រូវទៅមើលទាំងអស់គ្នា ប្រសិនបើប្រកែកមិនទៅនឹងត្រូវចោទជាខ្មាំង។

ហ៊ាប សំណាង ភេទប្រុស អាយុ១៧ឆ្នាំ គឺជាសិស្សថ្នាក់ទី១២ នៃវិទ្យាល័យមេសាងយល់ឃើញថា ការបង្កើតសហករណ៍របស់ខ្មែរក្រហមនាំឲ្យមានការសម្លាប់មនុស្ស ពីព្រោះប្រជាជនហូបមិនគ្រប់គ្រាន់ ធ្វើការជាទម្ងន់ ហួសកម្លាំង និងធ្វើការលើសម៉ោង។ ប្រជាជនម្នាក់ទទួលបានបបរមួយចានប៉ុណ្ណោះសម្រាប់មួយពេល និងមានការតាមដានគ្នាទៅវិញទៅមក ចោទគ្នាឯងថាជាខ្មាំងរបស់អង្គការ។ ដើម្បីសម្រេចផែនការ អង្គការបានធ្វើបន្សុទ្ធកម្ម មានការបែងចែកប្រជាជន បណ្តុះស្មារតីឲ្យមនុស្សលែងទុកចិត្តគ្នា មេដឹកនាំផ្តាច់ការមិនទុកចិត្តប្រជាជនថ្មី អនុវត្តលទ្ធិកុម្មុយនីស្តផ្តាច់ការ និងសម្លាប់មេដឹកនាំរបបមុនៗ។

ថ្ងៃទី២០ឧសភា ក្លាយជា «ថ្ងៃទិវាការចងចាំ» ពីប្រវត្តិសាស្ត្រខ្មែរក្រហមនាពេលបច្ចុប្បន្ន។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅថ្ងៃទី២០ឧសភា គឺជា «ទិវាចងកំហឹង» ចំពោះបនប្រល័យពូជសាសន៍ប៉ុល ពត អៀង សារី។ នៅថ្ងៃ២០ឧសភានេះ រូបតំណាងប៉ុល ពត និង អៀង សារី ធ្វើពីចំបើង តែងតែត្រូវបានដុតនៅមុខមហាជនដែលបានចូលរួមនៅក្នុងទិវានេះ។ ក្រោយមក រាជរដ្ឋាភិបាលកម្ពុជាបានផ្លាស់ប្តូរពី «ទិវាចងកំហឹង» ដោយជំនួសមកវិញនូវ «ទិវាជាតិនៃការចងចាំ»។ ប្រជាជនមន្ត្រីរាជការ ព្រះសង្ឃ និងមនុស្សគ្រប់ជាន់ថ្នាក់ បានមកជួបជុំគ្នាធ្វើពិធីបង្សុកូល ឧទ្ទិសកុសល្យ និងបួងសួងដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ក្នុងរបបខ្មែរក្រហម ឲ្យបានដល់សុគតិភព។

# បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង
















បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន សិស្ស និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ អង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍អំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង គឺជាកន្លែងប្រមូលផ្តុំ និងតម្កល់ឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅបណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយ គឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបី គឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួន គឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈបណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។



## បណ្ណាល័យកងពលតូចថ្មើរជើងលេខ ៨១

បណ្ណាល័យប្រវត្តិសាស្ត្រយោធា ស្ថិតនៅក្នុងកងពលតូចថ្មើរជើងលេខ ៨១ ក្នុងស្រុកអន្លង់វែង ខេត្តបន្ទាយមានជ័យ។

បណ្ណាល័យមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង មានទីតាំងនៅភូមិអូរចិញ្ចៀន ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពី ថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង២៖០០ដល់ម៉ោង៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង តាមរយៈទូរសព្ទលេខ៖ ០១២ ៥៧០ ៨៦៥ ឬ អ៊ីម៉ែល ៖

truthlysokkheang@dccam.org

សូមអរគុណ!











# ពុំ វី ៖ បែកបាក់ឪពុកម្ដាយ និងប្អូនៗទាំងពីរនាក់ ដោយមិនដឹងថានៅរស់ឬស្លាប់រហូតមកដល់សព្វថ្ងៃ

**ពុំ ខណ្ណាឌី**



ពុំ វី រស់នៅភូមិពស់ពង ឃុំនរាយណ៍ ស្រុកឈូក ខេត្តកំពត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ពុំ វី កើតនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧០ នៅភូមិឈូក ស្រុកឈូក ខេត្តកំពត។ ឪពុករបស់ខ្ញុំឈ្មោះ ញ៉ែរ និងម្ដាយឈ្មោះ ស៊ុម។ ខ្ញុំគឺជាកូនទីមួយក្នុងចំណោមបងប្អូនបង្កើតចំនួនបីនាក់។ កាលពីកុមារ ខ្ញុំមានឈ្មោះ ម៉ាប់។ ចំណែកឯឈ្មោះ ពុំ វី ទើបតែប្ដូរក្រោយរបបខ្មែរក្រហម។ ប្អូនប្រុសបន្ទាប់ពីខ្ញុំ ឈ្មោះ មឿន និងប្អូនស្រីពៅមិនចាំឈ្មោះ ព្រោះខ្ញុំបែកពីឪពុកម្ដាយតាំងពីប្អូនស្រីទើបកើតបាន១៥ថ្ងៃ។

ខ្ញុំចាំបានថា នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច បានចាត់តាំងខ្ញុំនិងប្អូនប្រុសឲ្យទៅធ្វើការងារនៅក្នុងកងកុមារក្នុងភូមិ។ ពីដំបូងខ្មែរក្រហមមិនសូវប្រើខ្ញុំឲ្យធ្វើការងារទេ ព្រោះខ្ញុំនិងប្អូននៅតូចៗ ខ្មែរក្រហមគ្រាន់តែបញ្ជូនខ្ញុំនិងប្អូនប្រុសរបស់ខ្ញុំ ឲ្យមករស់នៅ ហូបរួមដេករួមក្នុងសហករណ៍តែប៉ុណ្ណោះ។ បន្ទាប់ពីខ្ញុំរស់នៅកងកុមារជាមួយម៉ែដោះមួយរយៈ ក៏មានអារម្មណ៍នឹកដល់ឪពុកម្ដាយ ខ្ញុំក៏បាននាំប្អូនលួចរត់ទៅលេងឪពុកម្ដាយនៅខុមស្បូវក្នុងភូមិ។ ក្រោយពីខ្ញុំលួចមកជួបឪពុកម្ដាយរយៈពេលពីរថ្ងៃ អង្គការបានបញ្ជូនខ្ញុំនិងប្អូនត្រឡប់ទៅកងកុមារវិញ។ ខ្ញុំរស់នៅក្នុងកងកុមារអស់រយៈពេលកន្លះឆ្នាំ អង្គការប្រើខ្ញុំឲ្យដើរប្រមូលទន្រ្ទានខែត្រដែលកាប់រួចតែម្ដងគត់។

ក្រោយមក អង្គការបានជម្លៀសខ្ញុំ និងក្រុមគ្រួសារទៅច្បារអំពៅ។ ខ្ញុំនិងឪពុកម្ដាយរួម ទាំងប្អូនៗបានលួចរត់ត្រឡប់មកស្រុកកំណើតវិញ ប៉ុន្តែត្រូវខ្មែរក្រហមចាប់បាននៅខាងមុខព្រះបរមរាជវាំងសព្វថ្ងៃ។ អង្គការចាប់បញ្ជូនខ្ញុំនិងគ្រួសារ ទាំងកណ្ដាលយប់តាមស្រឡាងទៅកាន់ភូមិ៩ ស្រុកកោះធំ ខេត្តកណ្ដាល។ ខ្ញុំរស់នៅជាមួយក្រុមគ្រួសារនៅស្រុកកោះធំបានរយៈពេលមួយខែក៏ធ្លាក់ខ្លួនឈឺ។ អង្គការបានបញ្ជូនខ្ញុំមកព្យាបាលនៅមន្ទីរពេទ្យមណ្ឌលគិរី ដែលមានទីតាំងនៅខាងត្បូងទីក្រុងភ្នំពេញ។ ពេលនោះ ខ្ញុំមានជំងឺរាករូស ហើយខ្ញុំពុំទទួលបានថ្នាំពេទ្យសម្រាប់ព្យាបាលឡើយ គឺមានតែផ្លែសូដា និងផ្លែមង្ឃុតយក

មកដាំទឹកផឹកដើម្បីព្យាបាលជំងឺ។ មន្ទីរពេទ្យមណ្ឌលគិរីស្ថិតនៅភូមិដាច់ស្រយាល និងមានផ្ទះប្រជាជនមួយៗ ប៉ុន្តែគ្មានមនុស្សរស់នៅទេ។ នៅជុំវិញផ្ទះហ៊ុមព័ទ្ធទៅដោយព្រៃទន្ទ្រានខែត្រ។

ខ្ញុំដេកពេទ្យអស់រយៈពេលកន្លះខែក៏មានអារម្មណ៍នឹកម្តាយជាខ្លាំង ហើយគាប់ជួនពេលនោះស្រាប់តែម្តាយរបស់ខ្ញុំក៏មកសួរសុខទុក្ខខ្ញុំ។ ខ្ញុំបានវិលត្រឡប់ទៅកោះធំជាមួយម្តាយខ្ញុំវិញ។ ខ្ញុំដេកជាមួយម្តាយនៅកោះធំបានមួយយប់ ម្តាយខ្ញុំក៏ជូនខ្ញុំត្រឡប់មកមន្ទីរពេទ្យវិញដើម្បីព្យាបាលជំងឺ ប៉ុន្តែគ្រូពេទ្យមិនទទួលឡើយ។ នៅពេលនោះ អង្គការក៏បានបញ្ជូនខ្ញុំមកព្យាបាលនៅមន្ទីរពេទ្យនៅភ្នំពេញតែម្នាក់ឯង ចំណែកម្តាយរបស់ខ្ញុំត្រូវត្រឡប់ទៅកោះធំវិញ។ ដោយសារតែខ្ញុំនៅតូច ខ្ញុំមិនស្គាល់ឈ្មោះទីកន្លែងទេ ពេលមកដល់ទីក្រុងភ្នំពេញដំបូង គឺគ្រាន់តែខ្ញុំចាំបានថា មន្ទីរពេទ្យនោះឈ្មោះ «ពេទ្យកងនារី»។ នៅពេលខ្ញុំមកដល់មន្ទីរពេទ្យភ្នំពេញ ពុំទាន់បានលេបថ្នាំផង ខ្ញុំក៏បានជាសះស្បើយពីជំងឺ។ ក្រោយពីដឹងថា ខ្ញុំបានជាសះស្បើយ អង្គការមិនបានបញ្ជូនខ្ញុំឲ្យទៅរស់នៅជាមួយឪពុកម្តាយវិញទេ។ ចាប់តាំងពីពេលនោះមក ខ្ញុំបែកពីឪពុកម្តាយ និងប្អូនៗរហូតមក។ ខ្ញុំរស់នៅជាមួយក្រុមគ្រូពេទ្យនៅទីនោះ រយៈពេលប្រហែលជិតពីរខែ។

ក្រោយមក កងទ័ពវៀតណាមបានចូលមកដល់ទីក្រុងភ្នំពេញនៅដើមខែមករា ឆ្នាំ១៩៧៩។ ខ្មែរក្រហមបានជម្លៀសខ្ញុំនិងក្រុមគ្រូពេទ្យចេញពីមន្ទីរពេទ្យមកកាន់ចំណតរថភ្លើង ហើយធ្វើដំណើរឆ្ពោះទៅកាន់ខេត្តកំពង់ឆ្នាំង និងបានស្នាក់នៅទីនោះរយៈពេលមួយខែ។ ក្រោយមក មានអ្នករាយការណ៍ថាកងទ័ពវៀតណាមបានចូលមកដល់ហើយ។ ខ្ញុំ និងក្រុមគ្រូពេទ្យ៧ នាក់ផ្សេងទៀតនាំគ្នាប្រមូលអីវ៉ាន់ធ្វើដំណើរឆ្ពោះទៅកាន់ខេត្តពោធិ៍សាត់ តាមរយៈឡានដឹកទឹករបស់ទាហានខ្មែរក្រហម។ ឡានទាហានខ្មែរក្រហមបានដាក់ខ្ញុំនិងគ្រូពេទ្យ នៅតាមផ្លូវភ្នំខេត្តពោធិ៍សាត់ក្បែរផ្លូវរទេះភ្លើង។ នៅក្បែរកន្លែងនោះ មានរោងវែងមួយ ហើយគ្រប់គ្នាក៏បានស្នាក់នៅទីនោះអស់រយៈពេលមួយខែ។ ការហូបចុកនៅទីនោះ ពីដំបូងក្រុមគ្រូពេទ្យបានស្នើសុំដាំបាយហូបរួមម្តងបួនប្រាំឆ្នាំង ហូបជាមួយម្ហូបត្រីសាច់។ លុះនៅបានរយៈពេលមួយខែក៏ចាប់ផ្តើមខ្វះអាហារ ថ្ងៃខ្លះក៏មានបាយហូប ថ្ងៃខ្លះក៏គ្មាន។ ពេលអត់បាយហូប ខ្ញុំរកបានទឹកដោះគោដុំប៉ុនៗមេដៃមកឆុងផឹក។ មានអ្នកជំងឺពីរបីនាក់នៅទីនោះឈឺដេកហើមប្រេះដៃប្រេះជើង ដោយសារអត់បាយ។

នៅពាក់កណ្តាលយប់មួយ ខ្ញុំនិងអ្នកផ្សេងទៀតត្រូវបន្តដំណើរទៅ ឡាក់ ទាំងកណ្តាលយប់ ដោយសារមានអ្នកប្រាប់ថា កងទ័ពវៀតណាមជិតមកដល់ទៀតហើយ។ ខ្ញុំធ្វើដំណើរជិតមួយខែទម្រាំទៅដល់ ឡាក់ ដោយឈប់សម្រាកតាមផ្លូវជាច្រើនកន្លែង។ ការធ្វើដំណើរតាមរថភ្លើងបានជួបប្រទះនឹងគ្រោះថ្នាក់ ដោយសារខ្មែរក្រហមបោកគ្រាប់បែកចំប្រឡោះភ្លៅរបស់ខ្ញុំ។ អ្នកនៅពីក្រោយខ្ញុំមិនរងរបួសអ្វីទេ។ រីឯខ្ញុំត្រូវអំបែងគ្រាប់ចំដៃ និងក្តោងច្រមុះ។ ចំណែកអ្នកនៅសងខាងខ្ញុំរងរបួសធ្ងន់ប្រហែល១០នាក់ ក្នុងនោះមានអ្នកខ្ទាក់ភ្នែកទាំងសងខាង, ដាច់ដៃ, ដាច់ជើង, អំបែងគ្រាប់ខ្ទាតចូលពោះវៀន, ខ្លះទៀតដាច់កែងជើងកែងដៃជាដើម និងត្រូវអំបែងគ្រាប់ពេញខ្លួនបណ្តាលឲ្យសន្លប់។ ខ្ញុំមានសំណាងដោយសារទឹកដោះម្តាយថ្លៃ ទើបមិនស្លាប់និងមិនរងរបួសធ្ងន់។ អំឡុងពេលនោះ អ្នកនៅលើរថភ្លើងក៏ចាប់បានទាហានខ្មែរក្រហមម្នាក់និងរត់រួចម្នាក់។ រថភ្លើងបានបន្តដំណើរទៅដល់ជិត ឡាក់ និងឈប់សម្រាកនៅក្នុងរោងមួយក្បែរទីនោះរយៈពេលប្រហែល២០ថ្ងៃ។ ពេលនោះ ខ្ញុំនិងអ្នកផ្សេងទៀតមិនមានបាយហូបទេ គឺមានតែទឹកដោះគោម្នាក់បួនប្រាំដុំទុកសម្រាប់ឆុងផឹក។ កុមារៗកាលជំនាន់នោះមានរូបរាងស្គមស្គាំងដោយសារតែអត់អាហារ។

ខ្ញុំនិងក្រុមគ្រូពេទ្យចេញដំណើរទៅមុខទៀតដោយថ្មើរជើង។ យើងដើរបណ្តើរ ឈប់បណ្តើរ ដើម្បីស្តាប់សភាពការណ៍ថា អាចបន្តទៅមុខទៀតបានឬអត់។ ខ្ញុំដើរកាត់ព្រៃកាត់វាលស្រែក៏ជួបចម្ការអំពៅ

មួយ ហើយដោយសារតែហេវហត់ខ្លាំងក៏នាំគ្នាចូលទៅកាច់អំពៅ ហូប។ ខ្ញុំរវល់ហូបអំពៅបណ្ដើរ ដើរបណ្ដើរ ក្រុមគ្រូពេទ្យនិងអ្នករួមដំណើរបានទៅមុនអស់។ អ្នកទៅដល់មុនបានហូបបាយជាមួយសាច់គោដែលចុងភៅបានកាប់ធ្វើម្ហូប។ ចំណែកខ្ញុំមកដល់ក្រោយអស់បាយហូប។ បន្ទាប់ពីហូបបាយឆ្អែតអ្នកទាំងនោះក៏នាំគ្នាដេកតម្រៀបជាជួរនៅលើកន្ទេលក្រោមដើមឈើ។ ក្រោយពីសម្រាករយៈពេលមួយម៉ោងទៅពីរម៉ោង អ្នកខ្លះក៏ប្រកាច់ស្លាប់ ហើយនៅសល់ពីរបីនាក់ដេកគ្រវីក្បាលចុះឡើងត្រដាក់ចុងដៃត្រដាក់ចុងជើងមិនទាន់ស្លាប់។ ខ្ញុំមិនដឹងថា នៅក្នុងបាយម្ហូបនោះមានដាក់អ្វីទេ គ្រាន់តែពួកអ្នកនៅជុំវិញខ្ញុំនិយាយថា ហល់បាយស្លាប់ ព្រោះតែឃ្លានហូបបាយយូរ។ នៅពេលហូបឆ្អែតពេកទើបបណ្ដាលឲ្យហល់ស្លាប់។ រីឯក្រុមគ្រូពេទ្យមិនមាននរណាម្នាក់ស្លាប់ទេ ប៉ុន្តែខ្ញុំមិនដឹងថា ក្រុមគ្រូពេទ្យនោះបានហូបបាយដែរឬយ៉ាងណាទេ។ ខ្ញុំមិនស្គាល់កន្លែងនោះទេ ខ្ញុំគ្រាន់តែឃើញមានទីស្នាក់ការនិងកងទ័ពយាមពីរបីនាក់។ ពេលខ្ញុំមកដល់កន្លែងប្រជាជនហូបបាយនោះពេលព្រឹក ហើយពេលល្ងាចចុងភៅនោះដាំបាយឲ្យយើងហូបម្ដងទៀត។ ប្រជាជនហូបបាយចាប់ពីម៉ោង៧ព្រឹករហូតដល់ម៉ោង៣រសៀល។ នៅទីនោះ មានមនុស្សជាច្រើនមិនដឹងមកពីទីណាខ្លះទេ បានមកហូបបាយជុំគ្នា។ គ្រាន់តែអ្នកដេកស្លាប់ប្រហែល៥០០នាក់ ឬក៏អាចលើសពីនេះ ខ្ញុំមិនបានដឹងចំនួនច្បាស់ទេ។

នៅរសៀលថ្ងៃដដែល យើងមិនទាន់បានហូបបាយសម្រាប់ពេលល្ងាចផង ស្រាប់តែមានអ្នកស៊ើបការណ៍មកប្រាប់ថា កងទ័ពវៀតណាមមកដល់ហើយ។ ប្រជាជនក៏នាំគ្នារត់បន្តទៅមុខទៀត ពេលនោះខ្ញុំបានបែកពីក្រុមគ្រូពេទ្យដែលខ្ញុំរស់នៅជាមួយតាំងពីនៅភ្នំពេញ។ ខ្ញុំឃើញមីងម្នាក់ដែលខ្ញុំមិនចាំឈ្មោះនៅអង្គុយកន្លែងហូបបាយ ដោយគាត់មិនបានហូបបាយនោះទេ ទើបគាត់នៅរស់រានមានជីវិតជាមួយកូនតូចម្នាក់។ ខ្ញុំទៅតាមគាត់ ហើយក៏នាំគ្នាទៅអង្គុយលើកន្ទេលនៅកន្លែងអ្នកស្លាប់។ ភ្លាមនោះកងទ័ពវៀតណាមមកដល់បានហៅខ្ញុំនិងមីងម្នាក់នោះឡើងជិះឡានឆ្ពោះទៅកាន់ទីតាំងមួយកន្លែង នៅក្បែរបន្ទាយកងទ័ពវៀតណាមស្ថិតក្នុងខេត្តសៀមរាប។ ខ្ញុំនិងមីងបានរស់នៅក្នុងផ្ទះតូចមួយនៅក្បែរបន្ទាយកងទ័ពវៀតណាមអស់រយៈពេលប្រហែលកន្លះខែ។ ថ្ងៃខ្លះ មីងទៅរកអាហារបាន ខ្ញុំក៏ហូបជាមួយគាត់។ រីឯថ្ងៃខ្លះទៀត ខ្ញុំនិងគាត់មិនមានអាហារហូប ក៏នាំគ្នាផឹកទឹកហើយដេក។ ថ្ងៃមួយ មីងបានដើរទៅបន្ទាយកងទ័ពវៀតណាម ដោយសារគាត់ជាអ្នកខេត្តព្រៃវែង ចេះនិយាយភាសាវៀតណាមបានខ្លះ ទើបគាត់សុំបាយទាហានបានមួយចានយកមកហូប។ ថ្ងៃខ្លះទៀត ខ្ញុំនិងមីងបានដើរទៅរើសត្រីឆ្អើរដែលជ្រុះនៅតាមផ្លូវយកមកហូប។

ប៉ុន្មានថ្ងៃក្រោយមក កងទ័ពវៀតណាមចេញទៅប្រយុទ្ធអស់ ហើយមានយន្តហោះមួយចុះចតនៅទីនោះ។ គ្រប់គ្នាក៏បានឡើងយន្តហោះ ប៉ុន្តែខ្ញុំមិនដឹងថាយន្តហោះនោះទៅណាទេ។ ខ្ញុំរត់ទៅជិតដល់យន្តហោះហើយ ស្រាប់តែមីងបានស្រែកប្រាប់ខ្ញុំឲ្យត្រឡប់ក្រោយទៅយកកន្ទេល និងធុងទឹកកកដែលគាត់ទុកនៅខ្ទមមក។ ខ្ញុំរត់ទៅយកកន្ទេល និងធុងទឹកកកបានហើយរត់ត្រឡប់មកឡើងយន្តហោះវិញ ដោយសល់ចម្ងាយប្រហែល៣០ម៉ែត្រទៀតតែប៉ុណ្ណោះដល់យន្តហោះ ស្រាប់តែអ្នកបើកបរយន្តហោះចេញដំណើរទៅបោលបាត់។ មីងនិងកូនរបស់គាត់រួមជាមួយខ្ញុំក៏នាំគ្នាធ្វើដំណើរបន្តទៅមុខរហូតដល់ខាងកើតទីរួមខេត្តសៀមរាប។ នៅកន្លែងនោះមានបន្ទាយកងទ័ពវៀតណាម និងមានខ្ទមតូចមួយនៅជិតផ្លូវ ខ្ញុំ មីង និងកូនរបស់គាត់បានចូលសម្រាកក្នុងខ្ទមនោះ។

បន្ទាប់មក មានបុរសចំណាស់ម្នាក់ឈ្មោះ រីង បានមកសុំខ្ញុំពីមីងយកទៅនៅជាមួយគាត់ និងដើម្បីជួយឃ្វាលគោឲ្យគាត់។ រីង និយាយទៅកាន់មីងថា «បើនាំក្មេងម្នាក់នេះដើរពីសៀមរាបទៅព្រៃវែងមិនដល់ទេ ព្រោះគ្មានអីជិះឆ្ងាយណាស់។ បើមីងចង់ដើរៗទៅពីរនាក់កូនហ្នឹងក៏បានដែរ។» ពេលនោះមីងក៏ប្រគល់ខ្ញុំឲ្យទៅរស់នៅជាមួយ រីង ដោយមីងនិយាយថា បើទោះបីជាយ៉ាងណាក៏គាត់ត្រូវដើរឲ្យដល់ស្រុកកំណើត

របស់គាត់ដែរ។ ពេលនោះ ខ្ញុំសម្រេចចិត្តថានៅជាមួយ វឹង ដោយសារខេត្តព្រៃវែងនៅឆ្ងាយ ខ្ញុំដើរមិនដល់នោះទេ។ ខ្ញុំធ្វើដំណើរជាមួយ វឹង តាមរទេះគោទៅកាន់ផ្ទះរបស់គាត់។ នៅតាមផ្លូវធ្វើដំណើរ ខ្ញុំបានឃើញសាកសពមនុស្សពីរនាក់ដាច់ក្បាលនៅក្បែរគម្ពោតព្រៃ ដោយមិនដឹងថានរណាកាត់ក្បាលយកទៅណាបាត់។ ខ្ញុំមិនដឹងថាសាកសពទាំងពីរជាមនុស្សស្រីឬប្រុសទេ ព្រោះខ្ញុំឃើញបានតែមួយភ្លែត ដោយសារ វឹង យកដៃគាត់មកក្តោបមុខរបស់ខ្ញុំមិនឲ្យមើលតទៅទៀត។ ខ្ញុំបានរស់នៅជាមួយ វឹង អស់រយៈពេល១ឆ្នាំ។ ក្រោយមក ខ្ញុំរស់នៅមិនចុះសម្រុងគ្នាជាមួយកូនរបស់គាត់ ដោយសារក្មេងនោះចេះតែវាយធ្វើបាបខ្ញុំស្ទើរគ្រប់ពេល។ កាលនោះខ្ញុំនៅក្មេងទ្រាំមិនបានក៏ឈ្លោះជាមួយកូនគាត់វាយគ្នាទៅវិញទៅមក។ វឹង ខឹងខ្ញុំវាយគ្នាជាមួយកូន គាត់ក៏បានយកខ្ញុំទៅបំបរបង់ចោលនៅផ្សារសៀមរាប។ ពេលនោះគាត់បាននាំខ្ញុំទៅផ្សារសៀមរាប ហើយបានយកខ្ញុំទៅផ្ញើនឹងមីងម្នាក់នៅក្នុងផ្សារដោយគាត់និយាយថា «អ៊ីអើយអ៊ីសុំផ្ញើក្មេងមួយភ្លែត»។

បន្ទាប់មកវឹងក៏ត្រឡប់ទៅផ្ទះគាត់វិញបាត់ដោយទុកឲ្យខ្ញុំនៅជាមួយមីងម្នាក់នោះ។ អំឡុងពេលនោះ ខ្ញុំមានអាយុប្រហែល១១ឆ្នាំ។ ខ្ញុំរស់នៅជាមួយមីងនៅក្បែរផ្សារសៀមរាបបានប្រហែលបួនទៅប្រាំថ្ងៃ។ មីងនោះមិនមានលក់ដូរអ្វីទេនៅតូបរបស់គាត់ ហើយកាលនោះខ្ញុំឃើញមានតែតូបលក់តូចៗ។ ពេលព្រឹកមីងតែងតែចេញទៅក្រៅបាត់រហូតដល់ល្ងាចទើបគាត់ត្រឡប់មកវិញ។ ចំណែក ខ្ញុំនៅអង្គុយតែក្នុងផ្ទះរបស់គាត់មួយកន្លែងមិនហ៊ានដើរចេញទៅណាទេព្រោះមិនស្គាល់។ នៅពេលមីងត្រឡប់មកវិញពេលល្ងាច គាត់បានឲ្យបាយខ្ញុំហូប ប៉ុន្តែមិនឆ្អែតឡើយ។

បន្ទាប់ពី ខ្ញុំរស់នៅជាមួយមីងបាន៤ទៅ៥ថ្ងៃ ក៏មានលោកតាម្នាក់ដែលជាអ្នកស្គាល់គ្នាជាមួយមីងឈ្មោះ តាគយ។ តាគយ បានសុំខ្ញុំពីមីងយកទៅចិញ្ចឹម។ ខ្ញុំបាននៅជាមួយ តាគយ បានរយៈពេល១ឆ្នាំ។ ក្រោយមក តាវឹង ដឹងថា តាគយ យកខ្ញុំមកចិញ្ចឹមក៏តាមរករឿងឈ្លោះជាមួយ តាគយ រហូតគាត់មិនហ៊ានឲ្យខ្ញុំនៅជាមួយតទៅទៀត។ តាគយ និយាយថា «កូនអើយកូន កូនឯងទៅនៅវត្តសិនចុះព្រោះនៅទីនេះតាវឹង ចេះតែរករឿងពុកពេក ពុកមិនហ៊ានចិញ្ចឹមកូនឯងតទៀតទេ»។

បន្ទាប់ពីនោះ ខ្ញុំក៏បានមកនៅវត្តគគីរនៅខេត្តសៀមរាប ដោយរស់នៅជាមួយលោកសង្ឃក្នុងវត្ត។ ខ្ញុំក៏ចាប់ផ្តើមរៀនអក្សរ, រៀនធម៌ជាមួយលោក។ ពេលរៀនធម៌ គឺខ្ញុំទៅសួរលោកម្តងមួយពាក្យៗយកមកទន្ទេញ។ លោកតាអាចារ្យវត្តបង្រៀនអក្សរដល់ចៅរបស់គាត់និងខ្ញុំរួមគ្នា។ ក្រោយពី ខ្ញុំស្នាក់នៅវត្តបានប្រហែល៣ឆ្នាំ ព្រះចៅអធិការបានឲ្យខ្ញុំសាងផ្នួស។ ជិតដល់ថ្ងៃសាងផ្នួសទៅហើយ ស្រាប់តែថ្ងៃមួយ លោកនេនបួនប្រាំអង្គបានឲ្យខ្ញុំទៅឈរចាំចាប់ផ្លែខ្នុរទុំ ដែលលោកនេនឡើងកាត់ទម្លាក់ពីលើចុង។ ដោយសារតែផ្លែខ្នុរនោះធំហើយដើមរបស់វាខ្ពស់ ពេលដែលផ្លែខ្នុរធ្លាក់ជិតដល់ដីខ្ញុំក៏រត់ចេញធ្វើឲ្យខ្នុរធ្លាក់មកបែកអស់ ជាហេតុនាំឲ្យលោកនេនបួនប្រាំអង្គព្រួតវាយខ្ញុំ។ ពេលនោះ ខ្ញុំស្មានថាលោកនេនវាយខ្ញុំលេង ខ្ញុំក៏តដៃវិញហើយត្រូវលោកនេនទាំងបួនប្រាំអង្គវាយផងទាត់ផងធ្វើឲ្យខ្ញុំទ្រោមខ្លួននៅនឹងកន្លែង។ ក្រោយមក រឿងនេះក៏ជ្រាបដល់ព្រះចៅអធិការវត្ត។

ពេលនោះ ព្រះចៅអធិការវត្តក៏បានឲ្យខ្ញុំចេញពីវត្តទៅនៅជាមួយកូនរបស់គាត់ឈ្មោះ ពុំ និងប្រពន្ធឈ្មោះរិក។ តាពុំនិងយាយរិកមានកូនស្រីម្នាក់ឈ្មោះ ហ្វីម។ បង ហ្វីម គាត់ចង់បានខ្ញុំធ្វើជាកូនរបស់គាត់ ប៉ុន្តែដោយសារគាត់មិនទាន់មានប្តី ទើបគាត់យកខ្ញុំធ្វើជាប្អូនប្រុសរបស់គាត់។ ពេល ខ្ញុំនៅជាមួយតាពុំ យាយរិក និង បង ហ្វីម គាត់មិនដែលធ្វើបាបខ្ញុំទេ។ មិនយូរប៉ុន្មាន បង ហ្វីម រៀបការហើយក៏បានរស់នៅជុំគ្នាទាំងអស់។ បន្ទាប់ពីរស់នៅជាមួយគ្នាបានមួយរយៈបងថ្លៃក៏ចាប់ផ្តើមធ្វើបាបខ្ញុំ ដោយប្រើខ្ញុំឲ្យធ្វើការងារទាំងអស់ក្នុងផ្ទះ។ នៅរដូវប្រាំង ខ្ញុំត្រូវក្រោកពីព្រឹកព្រលឹមស្រោចទឹកបន្លែ៥០ទៅ៦០អម្រែក។ បន្ទាប់មក ខ្ញុំត្រូវដឹកគោចងស៊ីស្មៅ រួចបានទៅរៀន

នៅសាលាត្រពាំងត្រាវ ដែលមានចម្ងាយប្រហែល ៣០០ម៉ែត្រពីផ្ទះ។ នៅរដូវវស្សាខ្ញុំមិនបានទៅរៀនទេ ខ្ញុំត្រូវក្រោកម៉ោង៣ទៀបភ្លឺ ទឹមគោបង្ហួសនង្គ័លទៅស្រែដោយសារខ្ញុំនៅតូចលីនង្គ័លមិនរួច។ ស្របពេលគ្នានេះដែរខ្ញុំត្រូវដឹកគោមួយនឹមទៀតនៅពីក្រោយ។ នៅតាមផ្លូវគោក្នុងនឹមដល់គ្នារញ៉េរញ៉ៃពេញផ្លូវ។

នៅរដូវដកស្ទូងនិងច្រូតកាត់ក្រុមគ្រួសារ បងហ៊ីម មកធ្វើស្រែបានមួយទៅពីរថ្ងៃតែប៉ុណ្ណោះ។ ចំណែកខ្ញុំដើរស្ទូងច្រូតយកដៃអ្នកជិតខាង។ ពេលស្ទូងច្រូតផ្ទះខ្លួនឯងរួចក៏ដើរសងដៃអ្នកជិតខាងតែម្នាក់ឯង។ ដល់ពេលប្រមូលផលស្រូវ ខ្ញុំត្រូវដឹកគោមកជាន់ស្រូវហើយរោយយកគ្រាប់ស្រូវ បោលអង្កាមរួចក៏យកស្រូវមកដាក់ជង្រុកតែម្នាក់ឯង។ នៅពេលដែលប្រមូលផលបន្លែដែលខ្ញុំដាំ ក្រុមគ្រួសារគាត់យកទៅលក់មិនបានឲ្យកម្រៃខ្ញុំទេ។ ប្រសិនបើខ្ញុំចង់ទិញខោអាវថ្មីពាក់ ទាល់តែខ្ញុំសន្សំលុយពីការលេងគប់វង់នៅសាលារៀនឈ្នះទើបបានទិញ ហើយលុយដែលសន្សំបានពីការលេងគប់វង់នោះបើគាត់ឃើញគាត់ដកយកទៀត អញ្ចឹងមានតែលាក់កុំឲ្យឃើញ។ ពេលទៅមើលគោ ខ្ញុំឆ្លៀតអានសៀវភៅ។ ថ្ងៃខ្លះខ្ញុំដេកលក់បងថ្លៃមកទាន់ក៏វាយធ្វើបាបខ្ញុំ។ ថ្ងៃខ្លះទៀត ខ្ញុំទៅចងគោរួចខ្ញុំទៅឈរមើលក្មេងៗលេងនៅក្បែរនោះ បងថ្លៃមកទាន់ក៏វាយខ្ញុំ។ ខ្ញុំពិបាកទ្រាំនឹងការធ្វើបាបពីសំណាក់បងថ្លៃមិនល្អសថ្ងៃបែបនេះ ខ្ញុំក៏បានលួចរត់ចេញពីផ្ទះពីរបីលើកទៅនៅជាមួយអ្នកភូមិក្បែរនោះ។ ពេលក្រុមគ្រួសារ បងហ៊ីម ឃើញខ្ញុំក៏យកមកផ្ទះវិញ។ ចុងក្រោយខ្ញុំក៏បានរត់ទៅនៅជាមួយក្រុមគ្រួសារបងជីដូនមួយនៅភូមិផ្សេងគ្នាម្នាក់ទៀតឈ្មោះ រ៉ែត។ ខ្ញុំរស់នៅជាមួយគាត់បានរយៈពេលពីឆ្នាំ។ ថ្ងៃមួយ បងហ៊ីម ឃើញខ្ញុំក៏នាំមកផ្ទះគាត់វិញ។ ពេលខ្ញុំមករស់នៅជាមួយ បងហ៊ីម វិញ ខ្ញុំដើរទិញស្រូវ ទិញស្វាយយកមកលក់ដើម្បីបានលុយទៅរៀន។ បន្ទាប់ពីខ្ញុំលក់ចំណេញសន្សំលុយសល់ខ្លះក៏ទិញកង្កែប និងជ្រូកមកចិញ្ចឹម។ នៅពេលជ្រូកនិងកង្កែបធំ តាពុំ លក់យកលុយទៅឲ្យប្រពន្ធចុងរបស់គាត់អស់ដោយសារពេលនោះ យាយរិក ស្លាប់បាត់ហើយ។ ចំណែកដីស្រែរបស់ខ្ញុំដែលរដ្ឋចែកឲ្យ៧១អា តាពុំ ប្រមូលលក់យកលុយឲ្យប្រពន្ធចុងគាត់ទាំងអស់ទៀត។ ពេលនោះ ខ្ញុំបានសម្រេចចិត្តចាកចេញទៅធ្វើការនៅស្រុកឆ្ងាយ ដើម្បីសន្សំលុយ និងតាមស្វែងរកឪពុកម្តាយបងប្អូនបង្កើតរបស់ខ្ញុំ ដែលបែកគ្នាតាំងពីរបបខ្មែរក្រហម។

ខ្ញុំខំស្វែងរកឪពុកម្តាយបងប្អូនបង្កើតរបស់ខ្ញុំតាមអ្វីដែលខ្ញុំចងចាំ និងអាចធ្វើបានដោយជួលមនុស្សឲ្យជួយរក និងដើររកខ្លួនឯងគ្រប់ទិសទីផង ប៉ុន្តែនៅតែមិនបានជួប។ មកដល់សព្វថ្ងៃខ្ញុំនៅតែបន្តស្វែងរកក្រុមគ្រួសារខ្ញុំដដែល បើទោះបីជាបាត់ដំណឹងគាត់អស់រយៈពេល៤០ឆ្នាំជាងមកហើយ។ ខ្ញុំរៀបការនៅឆ្នាំ១៩៩៥ និងមានកូនបីនាក់កូនទី១ ឈ្មោះ ពុំ ដាន់ណា, កូនទី២ ឈ្មោះ ពុំ វណ្ណឌី និងកូនស្រីពៅឈ្មោះ ពុំ ដានី។ សព្វថ្ងៃ ខ្ញុំរស់នៅជាមួយប្រពន្ធនិងកូននៅភូមិពស់ពង ឃុំនរាយណ៍ ស្រុកឈូក ខេត្តកំពត ដោយប្រកបមុខរបរធ្វើស្រែចម្ការដើម្បីចិញ្ចឹមគ្រួសារ។ រឿងរ៉ាវដែលខ្ញុំនៅឈឺចាប់និងចងចាំមិនភ្លេចពីរបបខ្មែរក្រហម គឺការបែកបាក់ពីឪពុកម្តាយនិងប្អូនៗទាំងពីរនាក់ដោយមិនដឹងថានៅរស់ឬស្លាប់រហូតមកដល់សព្វថ្ងៃ។



ពុំ វី រស់នៅភូមិពស់ពង ឃុំនរាយណ៍ ស្រុកឈូក ខេត្តកំពត។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# «ទួលពិឃាដ» (ត)

# ១៣. ឆាកជីវិតក្រោយព្យុះសង្ឃរាបដិវត្តន៍ (ត)

## ផ្លែបាំងមែក

*ទំនប់ព្រែកដបង*

...ខ្ញុំថា មិនអីទេ ព្រោះបានធ្លាក់ចូលក្នុងថ្លុកក្របី បើមិនអ៊ីចឹងគ្រោះថ្នាក់ដល់ជីវិតហើយ។

ជីវិតពិតជាថ្លៃមែន! ពិតជាសំណាងក្នុងគ្រោះថ្នាក់មែន! ក្នុងរដូវថ្ងៃរះៗ ខ្ញុំជឿថា ផ្លែបាំងមែក គឺព្រលឹងឪពុកម្ដាយនៅតាមថែរក្សាកូនជានិច្ច ព្រោះរទេះគោដាច់ជាពីរ ពិតជាមិនធម្មតាទេ។ បន្ទាប់មកបងស្រីលើកដៃសំពះឡើងលើលាយទឹកភ្នែករហាម "អរគុណដល់ម្ចាស់ទឹកម្ចាស់ដីថែរក្សាទីនេះ" ហើយបងស្រីយកក្រមាជូតភក់ចេញពីមុខមាត់ខ្ញុំ ហើយក៏ដឹកដៃខ្ញុំធ្វើដំណើរទៅផ្ទះទាំងអស់គ្នា។

ខ្ញុំមើលមុខបងស្រីប្រហែលជាគាត់ចង់និយាយថា ឲ្យបងសុំទោសផងដែលបណ្ដោយឲ្យប្អូនបររទេះគោនៅក្មេងខ្ចីទាំងគ្មានបទពិសោធ។

មកដល់ផ្ទះគាត់នាំខ្ញុំទៅងូតទឹកពាងដើម្បីជម្រះកាយក្នុងភាពតក់ស្លុតរន្ធត់គ្រប់ៗគ្នា។ នឹកស្ដាយនឹងពេលវេលាដែលខំតស៊ូហែលឆ្លងដីលំបាកស្ទើរកកឈាមជាដុំឲ្យរួចផុតជីវិតក្នុងលំហគុកកម្ម។ មិនគួរឡើយណាធ្វើឲ្យយើងធ្វេសប្រហែសស្ទើរអស់ជីវិតតែមួយប៉ប្រិចភ្នែកក្នុងវិប្បដិសារីដេរស្ដីឥតឈប់នេះ។

## ស្រណោះកេរមរតក

*ហោ ហិតឯកា*

ពេលវេលាមិនរង់ចាំយើងទេ ពីមួយថ្ងៃទៅមួយថ្ងៃអ្វីៗតែងតែទៅមុខជានិច្ច រដូវវស្សាចូលមកដល់ដែលជារដូវធ្វើស្រែ។

បងប្រុសគាត់ដំឡើងជង្រុំផ្ដិបាននង្គ័លរនាស់ចាស់ដើម្បីមកភ្ជួរស្រែតែយើងខ្វះមធ្យោបាយអូសទាញដូចជាគោ ក្របី។ បងស្រីដាច់ចិត្តយកមាសដែលម្ដាយបានផ្ដាំឲ្យបងទុកចែកប្អូនៗ ក្រោយពីម្ដាយមិនបានជួបប្រធានកងសហ ហើយឲ្យធំហុងរក្សាទុកដាក់មុនពេលគេយកគាត់ទៅសម្លាប់នៅទួលស្វាំង។

បងស្រីពិតជាពិបាកគិតណាស់ មួយបណ្ដាំម្ដាយ មួយតម្រូវការដើម្បីចិញ្ចឹមជីវិត។ តើឲ្យគាត់គិតសម្រេចចិត្តយ៉ាងណា? បងកាន់ថង់ក្រណាត់មួយកញ្ចប់តូចដែលទើបទទួលពីធំហុងប្រគល់មកវិញមកឱបនឹងដើមទ្រូងដែលមានភ្ជួយដេករុំក្រមានៅក្បែររួចសម្លឹងមើលមុខប្អូនៗ មានទឹកភ្នែករលីងរលោង មួយស្ដាយកេរមរតកមួយបណ្ដាំម្ដាយ ខ្លាចខុសបណ្ដាំ តើយកមួយណា? រូបភាពទាំងនេះ ពេលបងស្រីយកកញ្ចប់នោះមកឱបនឹងទ្រូង គឺមិនខុសពីកាលឃើញម្ដាយខ្ញុំឱបកញ្ចប់នេះនឹងដើមទ្រូងមុននឹងទៅជួបមេកងសហ។ មកដល់ត្រឹមនេះបងស្រីគិតស្ទើរបែកទ្រូង អារម្មណ៍ដែលគាត់ពិតជាវិលវល់មិនឈប់សោះ

នឹកគិតដល់បណ្ដាំព្រលឹងឪពុកម្ដាយ។

ក្នុងរាត្រីមួយដែលគាត់កំពុងលង់លក់បានសុបិនឃើញម្ដាយកំពុងសម្រាន្តក្នុងអង្រឹងកំប្លោកលើផ្ទះ ដូចកាលគាត់នៅរស់ សម្លៀកបំពាក់ពណ៌ខ្មៅ។ ពេលនោះវិញ្ញាណសុបិនរបស់បងស្រីបានសួរទៅម្ដាយថា "ម៉ែ! កូនយករបស់ម៉ែទុកឲ្យទៅប្ដូរយកក្របីមួយនឹម និងដូរយកអង្ករ ចានឆ្នាំងមកប្រើប្រាស់ តើអ្នកម្ដាយមានខឹងនឹងកូនឬទេ?" បន្ទាប់មកព្រលឹងម្ដាយបានងាកមកនិយាយជាមួយបងស្រីថា "មិនអីទេ! ធ្វើម្ដេចបើកូនគ្មានអ្វីហូបហើយ។ ពេលនោះបងស្រីមើលទៅមុខនិងខ្លួនម្ដាយមានពណ៌ខ្មៅ ដូចផ្សែងរោល សក់កន្ទ្រើងខុសពីកាលគាត់នៅមានជីវិតរស់។

យោងតាមការសុបិន ព្រលឹងម្ដាយមិនបានខឹងសម្បារនឹងបងស្រីទេ។ ស្អែកឡើងបងស្រីដាច់ចិត្តនិយាយមកកាន់ខ្ញុំថា "បងយករបស់ម្ដាយទុកឲ្យទៅប្ដូរយកក្របីមួយនឹម ដើម្បីយកមកធ្វើស្រែ"។ ខ្ញុំពិតជាយល់អារម្មណ៍ពិបាកក្នុងចិត្តរបស់បងស្រី រួចក៏ងក់ក្បាលដិតដាមដោយទឹកភ្នែក។ ពេលល្ងាចខ្ញុំឃើញបងប្រុសបានដឹកក្របីញីមួយនឹមមកចូលក្នុងក្រោលក្រោមផ្ទះ។

ដោយសារមានការស្រលាញ់និងចូលចិត្តសត្វ ខ្ញុំបានចូលទៅមើលនិងអង្អែលក្បាលវាទាំងពីរ។ បងប្រុសបាននិយាយជាមួយខ្ញុំថា "ចាប់ពីស្អែកទៅយើងមានក្របីមួយនឹមនេះមកទឹមភ្ជួរស្រែដូចគេហើយ"។ ខ្ញុំបានតបទៅបងប្រុសថា "បង ក្របីនេះមួយធំមួយតូច ដូច្នេះយើងដាក់ឈ្មោះវាមីធំមីតូចទៅ។" បងញញឹមមករកខ្ញុំនិយាយថា "ហ្នឹងហើយ ហៅវាយ៉ាងម៉េចក៏បាន"។

# កសិករកុមារលើគន្លងនង្គ័ល

## សំណុំបាយកញ្ចប់ បំពង់ទឹកត្នោត

ព្រឹកព្រលឹមស្រាងៗ បន្ទាប់ពីខ្ញុំដាក់ទឹកត្នោតពីដើម នៅឯត្រពាំងផ្អែវិញ យើងចាប់ផ្ដើមទៅភ្ជួរស្រែជម្រៅកេររបស់ដូនតានៅខាងត្បូងភូមិក្បែរមាត់បឹង។

បងពីរនាក់ ខ្ញុំចាប់ផ្ដើម ទឹមក្របីជាមួយនង្គ័លនិងគាវឫស្សី។ មកដល់ស្រែជម្រៅ បងចាប់ផ្ដើមភ្ជួរ ហើយប្រាប់ខ្ញុំថាប្អូនដើរតាមក្រោយមើលរបៀបភ្ជួរ ព្រោះស្អែកបងមិនបាននៅទេ ត្រូវដើរទិញអង្ករដើម្បីដូរយកចានឆ្នាំងស្លាបព្រាមកប្រើប្រាស់។

ដោយមានការស្រលាញ់និងចូលចិត្ត ស្អែកព្រលឹមឡើង ខ្ញុំទឹមក្របីទៅភ្ជួរតែម្នាក់ឯង នេះជាលើកដំបូងហើយសម្រាប់ជីវិតខ្ញុំភ្ជួរស្រែ។ ខ្ញុំមាឌតូចយាមនង្គ័លនៅគាបនឹងក្លៀក នង្គ័លវាត់ដួលត្រលប់ត្រលិន ម្ដងទៅឆ្វេងម្ដងទៅស្ដាំតែនៅតែព្យាយាមមិនរួញរា។

ថ្ងៃរះពាក់កណ្ដាលដើមត្នោត ខ្ញុំឃើញបងស្រីនិងប្អូនរាំយួរម្ហូបមួយកាតូ បងស្រីស្រែកពីភ្លឺស្រែម្ខាងថា "ឈប់ភ្ជួរសិនទៅ មកហូបបបរសិន។" ខ្ញុំក៏ដោះក្របីចេញពីនឹមនង្គ័លមកចងនឹងគល់ត្នោតឲ្យវាស៊ីស្មៅ។ បងស្រីបានហុចស្លាបព្រាកញ្ចស់មួយមកឲ្យខ្ញុំ ហើយប្រាប់ថា "ប្អូនហូបបបរនេះជាមួយត្រសក់ផ្អក។"

ខ្ញុំចាប់ផ្ដើមដួសបបរនឹងស្លាបព្រាដាក់ចូលមាត់លួចមើលមុខបងស្រី គាត់ក៏មើលមកខ្ញុំក្នុងក្ដីអាណិតក្ដុកក្ដួលអារម្មណ៍។ គាត់យកដៃមកបេះភក់ចេញពីមុខមាត់ និងអង្អែលក្បាលខ្ញុំរួចគាត់ចាក់ទឹកពីកំសៀវចូលត្រឡោកហុចឲ្យខ្ញុំផឹក ដោយពោលថា "ប្អូនភ្ជួរបង្ហើយមួយងាររួចទៅផ្ទះចុះ"។ ខ្ញុំញញឹមដាក់បងស្រីក្នុងន័យបង្កប់មនោសញ្ចេតនារវាងបងនឹងប្អូនហើយចាប់ផ្ដើមភ្ជួរបន្តទៅទៀត។

បងស្រីគាត់មិនទាន់ត្រលប់ទៅវិញទេ ឈរកាន់ដៃប្អូនប្រុសមើលខ្ញុំភ្ជួរ ខ្ញុំលួចមើលគាត់ម្ដងៗដែរ។ ខ្ញុំយល់ពីទឹកចិត្តបងស្រីអាណិតដល់រូបខ្ញុំមាឌតូចពិបាកទប់ដងនង្គ័ល។ ខ្ញុំភ្ជួរបានពីរ បី គន្លង បងនិងប្អូនកាន់ដៃគ្នាដើរចូលក្នុងភូមិវិញ ប្អូនរាំដើរបណ្ដើរងាកមើលមកក្រោយបណ្ដើរ ហើយលើកដៃញញឹមពីចម្ងាយប្រហែលជាចង់និយាយថា បន្តិចទៀតលេងបិទពួនជាមួយគ្នា ខ្ញុំក៏លើកដៃជាសញ្ញាដែរ។ ភ្ជួររួចមួយងារ ខ្ញុំដោះក្របីចេញពីនឹមរួចដឹកវាទៅត្រាំទឹកបឹងក្បែរនោះ ហើយបរវាចូលភូមិ។

មកដល់ផ្ទះខ្ញុំដោះក្របីចេញពីនឹម ប្អូនរាំបានជួយដឹកវាទៅចងនឹងសសរផ្ទះ ខ្ញុំទៅងូតទឹកពាងដើម្បីសម្អាតភក់ដែលប្រឡាក់ពេញខ្លួន

ហើយ ហូបបាយជុំគ្នាជាមួយយាយ បងស្រី និងប្អូនៗ

ពេលហូបបាយរួចរាល់ហើយ ខ្ញុំដឹកក្របីមួយនឹមនេះទៅឃ្វាលនៅឯដើមប្រនៀងតាកុក ស្ថិតនៅមាត់ព្រៃរនាមមាត់ស្ទឹងគ្រៀង ដែលខ្ញុំធ្លាប់ហែលឆ្លងកាត់ជាមួយបងប្រុសពេលត្រលប់ពីការកៀរវិញៗ

ខ្ញុំស្រាយចំណងវាចេញពីសសរផ្ទះ បងស្រីហុចបាយសំណុំមួយកញ្ចប់ និងជ្រក់ល្ហុងខ្ចប់នឹងស្លឹកចេកដាក់ក្នុងថ្នក់ក្រមា ហើយពោលថា នេះបាយសំណុំប្អូនទុកហូបពេលឃ្លានៗ ខ្ញុំឡើងជិះមីធំ និងដឹកមីតូចពីក្រោយ ខ្លួនស្ពាយខ្សែចំណងនិងកឡោបំបាចទឹក ហើយចេញដំណើរទៅក្នុងចិត្តសប្បាយរីករាយ នឹងការរស់ររបរចិញ្ចឹមជីវិតនេះណាស់ៗ

ថ្ងៃណាក៏ដូចថ្ងៃណាដែរ ក្នុងរដូវវស្សានេះពេលព្រឹកចេញមកភ្ជួរស្រែ ពេលថ្ងៃដឹកក្របីទៅឃ្វាលនៅឯព្រៃរនាមមាត់ស្ទឹងគ្រៀង ហើយបងស្រីនិងប្អូនវាតែងតែយកបាយបុបបរឲ្យនៅពេលព្រឹកជារៀងរាល់ពេលខ្ញុំទៅភ្ជួរស្រែៗ

ព្រឹកនេះពេលខ្ញុំកំពុងភ្ជួរឮសំឡេងស្រែកពីភ្លឺស្រែម្ខាងថា “បងៗ ឈប់សិនទៅ ខ្ញុំយកបាយមកឲ្យបងហូបៗ” ខ្ញុំងាកក្រោយឃើញប្អូនឈរម្នាក់ឯងយួរកាតូ ខ្ញុំស្រែកប្រាប់ប្អូនវិញថាចាំភ្ជួរបានពីរបីគន្លងទៀតសិនៗ ប្អូនឈរវង់ចាំនិងមើលមក ខ្ញុំក្នុងចិត្តបន្តប់ដោយក្តីអាណិតៗ ភ្ជួរមកដល់ដើមស្រែក៏បញ្ឈប់ក្របី ប្អូនបានមកប្រាប់ខ្ញុំថា បងហូបបាយចុះ ខ្ញុំជួយដោះក្របីចេញពីនឹមៗ ខ្ញុំនិយាយទៅវិញថា ប្អូនមិនចេះដោះទេ ហើយខ្ញុំឈរទ្រដងនង្គ័ល ប្អូនក៏ជួយស្រាយខ្សែទាមចេញពីកក្របីយកទៅចងនឹងដើមត្នោត រួចអង្គុយចោងហោងហូបបាយៗ

ខ្ញុំនិយាយទៅកាន់ប្អូនថា ប្អូនហូបបាយហើយឬនៅ ប្អូនតបថាហើយៗៗ ប្អូនមើលមុខខ្ញុំទំពាបាយ ខ្ញុំលេបបាយស្ទើរស្រក់ទឹកភ្នែក នឹកឃើញពីជីវិតតស៊ូបីនាក់បងប្អូនហើយនិយាយទៅកាន់ប្អូនថា សុខភាពបងស្រីយ៉ាងម៉េចដែរ ប្អូនឆ្លើយថាធម្មតាទេៗ ខ្ញុំបន្តទៀត ចុះក្មួយប្រុសយំទេ មិនអីទេព្រោះបានយាយ ជួយមើល នេះជាសម្តីប្អូនប្រាប់ខ្ញុំៗ បងស្រីឆ្លងទន្លេពីម្សិលមិញដូច្នេះមិនបានយកបាយមកឲ្យខ្ញុំៗ

ខ្ញុំកំពុងតែស្ងួតអារម្មណ៍ស្ទើរភ្លឹកវិញ្ញាណ ប្អូនបានហុចត្រសក់ចាវឲ្យខ្ញុំមួយចំណិត ហើយសួរថាបងឆ្ងាញ់ទេៗ ខ្ញុំភ្ញាក់ខ្លួនហើយឆ្លើយ ទាំងអួលដើមកថា ឆ្ងាញ់ណាស់ រួចមើលទៅមុខប្អូនហាក់ដូចជាបន្តប់នូវរឿងកម្សត់ក្នុងវង្វង់បងប្អូនបីនាក់នេះដែរ ហើយចង់បញ្ចេញមនោសញ្ចេតនាភក្តីភាពនៃនិស្ស័យជាបងប្អូនដែលស្ថិតលើបន្ទងកំពុងយំស្រែកៗ

ខ្ញុំខំបន្ទប់ប្អូនថាបានហើយបងទៅបន្តភ្ជួរទៀត ប្អូនទៅផ្ទះចុះ តែប្អូនតបមកវិញថាបងស្រីឲ្យមកជួយដឹកក្របីលាងទឹកហើយចាំទៅផ្ទះទាំងអស់គ្នាៗ ជីវិតតស៊ូបងប្អូនបីនាក់លេបថ្នលេបក្រួសស្ថិតក្នុងអាណាព្យាបាលដោយឯង សមាជិកគ្រួសារក៏ខ្លួនឯងៗ

**ធ្លុង វង្សសមិទ្ធ**

**(តនៅលេខក្រោយ)**



ទិដ្ឋភាព៖ ពេលព្រឹកបងស្រី និងប្អូនវាយកបបរមកឲ្យខ្ញុំនៅឯស្រែជម្រៅមាត់បឹងដែលខ្ញុំកំពុងភ្ជួរៗ ( ធ្លុង វង្សសមិទ្ធ/មជ្ឈមណ្ឌលឯកសារកម្ពុជា )

*រូបក្របមុខ៖*

*កញ្ញា ប៊ូ សំណាង គឺជាអត្តពលិកក្នុងវិញ្ញាសារត់ចម្ងាយ ៥០០០ម៉ែត្រ កី ឡាអាស៊ីអាគ្នេយ៍លើកទី៣២ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*រូបក្របក្រោយ៖*

*កញ្ញា ប៊ូ សំណាង គឺជាអត្តពលិកក្នុងវិញ្ញាសារត់ចម្ងាយ ៥០០០ម៉ែត្រ កីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ១១ ផ្លូវ២៥៦ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #11 ◆ Street 256 ◆ Sangkat Chatomuk ◆ Khan Daun Penh ◆ Phnom Penh ◆ Cambodia 12200

Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 281, May 2023 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.